# ភាពរងគ្រោះនៅក្នុងវិស័យកាត់ដេរ៖ វិបត្តិជំងឺ COVID-19 បានធ្វើឱ្យកម្មករនិយោជិតកាត់ដេរនៅប្រទេសបង់ក្លាដែស និងកម្ពុជាធ្លាក់ចូលទៅក្នុងវិបត្តិ



## តារាងមាតិកា

1. សេចក្តីផ្តើម……………………………………………………………………………………………3

**2. អនុសាសន៍**........................................................................................................................ 4

**ក្រុមហ៊ុនម៉ាកឃីហោ**..........................................................................................................4

**រដ្ឋាភិបាលក្នុងប្រទេសបង់ក្លាដែស និងកម្ពុជា**.................................................................... 4

**រដ្ឋាភិបាលអូស្ត្រាលី**........................................................................................................ 5

**3. លទ្ធផលនៃការស្រាវជ្រាវ**...................................................................................................6

ប្រទេសបង់ក្លាដែស........................................................................................................ 6

ប្រទេសកម្ពុជា..................................................................................................................14

**4. សេចក្តីសន្និដ្ឋាន**.....................................................................................................................
21

# 1. សេចក្តីផ្តើម

*អត្ថបទសំខាន់៖ នៅពេលជំងឺរាតត្បាត COVID-19 ធ្វើឱ្យប៉ះពាល់ទៅដល់វិស័យកាត់ដេរក្នុងខែធ្នូ ឆ្នាំ2019 ម៉ាកសម្លៀកបំពាក់អន្តរជាតិត្រូវប្រឈមមុខនឹងការដាច់ខ្សែច្រវាក់ផ្គត់ផ្គង់ និងការបិទហាង ដែលបានគំរាមកំហែងទៅដល់ផ្នែកខាងក្រោមនៅក្នុងវិស័យនេះ។ រយៈពេលពីរឆ្នាំក្រោយមកទៀត កម្មការិនីកាត់ដេរនៅក្នុងប្រទេសនានា ដូចជា បង់ក្លាដែស និងកម្ពុជា ជាអ្នកខាតបង់ដ៏ធំបំផុត ខណៈដែលម៉ាកសម្លៀកបំពាក់ឈានមុខគេមួយចំនួនរបស់ពិភពលោកដាក់បន្ទុកចំណាយលើកម្មករនិយោជិតដែលផលិតសម្លៀកបំពាក់របស់យើង។*

ជំងឺ COVID-19 បានបង្កឱ្យមានវិបត្តិមនុស្សធម៌ដ៏ធំបំផុតរបស់ពិភពលោក នៅពេលដែលប្រទេសនានាជុំវិញពិភពលោកធ្វើការប្រយុទ្ធប្រឆាំងផលប៉ះពាល់ផ្នែកសុខភាព សង្គម និងសេដ្ឋកិច្ចដ៏សែនធ្ងន់ធ្ងរដោយសារតែជំងឺរាតត្បាតនេះ។ ដោយយោងលើការពិតជាក់ស្តែងនៃវិសមភាពជាសាកលដែលបង្ហាញឱ្យឃើញយ៉ាងច្បាស់នោះ គឺប្រទេសមានប្រាក់ចំណូលទាបដែលកំពុងរងគ្រោះខ្លាំងបំផុត ខណៈដែលករណីជំងឺបន្តកើនឡើង ហើយការស្តុកទុកវ៉ាក់សាំងដោយប្រទេសអ្នកមានបានធ្វើឱ្យសហគមន៍ក្រីក្របំផុតរបស់ពិភពលោកពុំបានទទួលវ៉ាក់សាំងគ្រប់គ្រាន់ដើម្បីការពារអាយុជីវិតពលរដ្ឋរបស់ខ្លួន។ ប្រជាជនដែលប្រកបការងារប្រាក់កម្រៃទាប និងពុំមានសុវត្ថិភាព ជាពិសេស កម្មករនិយោជិតជាស្ត្រី កំពុងប្រឈមមុខនឹងវិបត្តិសេដ្ឋកិច្ចដែលបង្កឡើងដោយជំងឺរាតត្បាត។

គ្មានការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចពិភពលោកណាធំជាងស្ថានភាពដែលកម្មករនិយោជិតកាត់ដេរជួបប្រទះនៅក្នុងអំឡុងពេលជំងឺរាតត្បាតឡើយ។ នៅពេលដែល COVID-19 ផ្ទុះឡើងជាលើកដំបូងនៅទីក្រុង Wuhan ប្រទេសចិនកាលពីខែធ្នូ ឆ្នាំ2019 ការផ្គត់ផ្គង់វត្ថុធាតុដើមដល់ប្រទេសផលិតសម្លៀកបំពាក់ដូចជាបង់ក្លាដែស និងកម្ពុជាត្រូវអាក់ខានភ្លាមៗ។ ក្នុងរយៈពេលប៉ុន្មានខែបន្ទាប់ ហាងលក់សម្លៀកបំពាក់នៅទូទាំងទ្វីបអឺរ៉ុប និងសហរដ្ឋអាមេរិកត្រូវបានបិទទ្វារយ៉ាងឆាប់រហ័ស។ ដោយសារ ប្រឈមមុខនឹងការខាតបង់ ការឆ្លើយតបពីក្រុមហ៊ុនម៉ាកយីហោអន្តរជាតិមានភាពឆាប់រហ័ស ហើយបានជួបប្រទះវិសមភាព និងការកេងប្រវ័ញ្ចនៅចំកណ្តាលបេះដូងនៃវិស័យកាត់ដេរសកល។

ក្រុមហ៊ុនម៉ាកយីហោនានាបានចាត់វិធានការភ្លាមៗដើម្បីកាត់បន្ថយការផលិត ដោយលុបចោលការបញ្ជាទិញ ពន្យារពេលការទូទាត់ និងរហូតដល់បដិសេធទាំងស្រុងនូវការទូទាត់សម្រាប់ការបញ្ជាទិញដែលបានផលិតរួចហើយផងដែរ។ ផលប៉ះពាល់មកលើកម្មករនិយោជិតកាត់ដេរគឺជាផលវិបាកដ៏សែនអាក្រក់មួយ។ គេប៉ាន់ប៉ាន់ប្រមាណថា រោងចក្រកាត់ដេរបានបញ្ឈប់ ឬផ្អាកការងារកម្មករនិយោជិតកាត់ដេរចំនួនមួយលាននាក់កាលពីខែមីនា ឆ្នាំ2020 គ្រាន់តែនៅក្នុងប្រទេសបង់ក្លាដែសតែមួយ។ ដោយសារមានលទ្ធភាពតិចតួចក្នុងការទទួលបានការគាំពារសង្គម កម្មករនិយោជិតកាត់ដេរប្រមាណ 80 ភាគរយជាស្ត្រី បានធ្លាក់ចូលទៅក្នុងភាពក្រីក្រ និងគ្រោះអត់ឃ្លានបន្ថែមទៀត។ អ្នកដែលមានសំណាងគ្រប់គ្រាន់ក្នុងការរក្សាការងាររបស់ខ្លួនមិនបានទទួលការហូបចុកល្អប្រសើរឡើយ ដោយសារថៅកែរោងចក្រកាត់ប្រាក់ឈ្នួល និងម៉ោងធ្វើការ ហើយការប្រឈមនឹងការឆ្លងជំងឺ COVID-19 នៅក្នុងរោងចក្រកាត់ដេរ បានកើនឡើងយ៉ាងឆាប់រហ័ស ដោយសារពុំមានឧបករណ៍ការពារគ្រប់គ្រាន់។

ស្ថានការណ៍ដែលបានកើតឡើងនៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ គឺការកើតឡើងនូវវិបត្តិផ្ទួនៗគ្នាច្រើន។ ជីវភាពរបស់កម្មករនិយោជិតកាត់ដេរត្រូវជួបប្រទះការលំបាកដោយសារការបិទខ្ទប់ប្រទេសនៅពេលជំងឺ COVID-19 បានផ្ទុះឡើង និងការឆ្លើយតបរបស់ម៉ាកយីហោអន្តរជាតិចំពោះការធ្លាក់ចុះតម្រូវការពីអ្នកប្រើប្រាស់ក្នុងប្រទេសអ្នកមាន រួមទាំងប្រទេសអូស្ត្រាលីផងដែរ។ ការស្រាវជ្រាវនេះផ្តល់នូវបច្ចុប្បន្នភាពអំពីស្ថានភាពដែលកម្មករនិយោជិតកាត់ដេរបានជួបប្រទះនៅក្នុងរយៈពេលពីរឆ្នាំបន្ទាប់ពីជំងឺរាតត្បាតបានកើតឡើង។

តាមរយៈការសម្ភាសន៍ជាមួយកម្មករនិយោជិតកាត់ដេរចំនួន 218 នាក់នៅក្នុងប្រទេសបង់ក្លាដែស និងកម្ពុជា របាយការណ៍នេះផ្តល់នូវការយល់ដឹងថាតើជំងឺ COVID-19 បានប៉ះពាល់យ៉ាងដូចម្តេចខ្លះដល់ការងារ និងប្រាក់ចំណូលរបស់កម្មករ សុវត្ថិភាព និងសិទ្ធិនៅកន្លែងធ្វើការ ក៏ដូចជាការរស់នៅរបស់ពួកគាត់នៅក្នុងផ្ទះផងដែរ។ ការស្រាវជ្រាវនេះបង្ហាញអំពីរូបភាពដ៏រំខានចិត្តមួយ គឺការលាតត្រដាងអំពីការពិតប្រចាំថ្ងៃសម្រាប់កម្មករនិយោជិតកាត់ដេរនៅក្នុងពេលកើតឡើងនូវជំងឺរាតត្បាត និងលើកបង្ហាញអំពីការកេងប្រវ័ញ្ចនៅក្នុងវិស័យកាត់ដេរនេះតែម្តង។ ឧស្សាហកម្មកាត់ដេរសាកលត្រូវការកំណែទម្រង់ជាយូរយារណាស់មកហើយហើយ ស្ថានភាពជំងឺ COVID-19 បានធ្វើឱ្យកិច្ចការនេះកាន់តែមានភាពបន្ទាន់ថែមទៀត។

## 2. អនុសាសន៍

**ដោយអភិវឌ្ឍបន្ថែមទៅលើការទាមទាររបស់កម្មការិនីរោងចក្រកាត់ដេរនៅក្នុងប្រទេសបង់ក្លាដែស និងប្រទេសកម្ពុជា អង្គការ ActionAid និងដៃគូនានាកំពុងអំពាវនាវឱ្យក្រុមហ៊ុនម៉ាកយីហោ និងរដ្ឋាភិបាលនានាប្តេជ្ញាអនុវត្តសកម្មភាពដូចខាងក្រោម៖**

### ក្រុមហ៊ុនម៉ាកយីហោ

**1. តម្លាភាព**

- ផ្សព្វផ្សាយ និងរក្សាបញ្ជីឈ្មោះពេញលេញរបស់រោងចក្រផ្គត់ផ្គង់ដែលជាប្រភពនៃការផ្គត់ផ្គង់របស់ខ្លួនពីខ្សែសង្វាក់ផ្គត់ផ្គង់គ្រប់កម្រិតទាំងអស់ រួមទាំងអ្នកផ្គត់ផ្គង់មៅការបន្តផងដែរ។

**2. ប្រាក់ឈ្នួលទ្រទ្រង់ជីវភាព**

- ប្តេជ្ញាផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតទាំងអស់នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់របស់ខ្លួននូវប្រាក់ឈ្នួលទ្រទ្រង់ជីវភាព និងបញ្ចេញផែនការលម្អិតដែលបញ្ជាក់អំពីពេលវេលា និងវិធានការដែលត្រូវអនុវត្តដើម្បីធានាថារោងចក្រទាំងអស់ដែលខ្លួនសហការជាមួយកំពុងផ្តល់ប្រាក់ឈ្នួលទ្រទ្រង់ជីវភាពដល់កម្មករនិយោជិត។
- ផ្សព្វផ្សាយគោលការណ៍នីតិវិធីទិញប្រកបដោយការទទួលខុសត្រូវ ស្របតាមកាតព្វកិច្ចរបស់ក្រុមហ៊ុនម៉ាកយីហោនៅក្រោមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងការណែនាំស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវ (Due Diligence Guides) OECD សម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ដែលទទួលខុសត្រូវក្នុងវិស័យកាត់ដេរ និងស្បែកជើង។
    - នីតិវិធីទិញរបស់ក្រុមហ៊ុនម៉ាកយីហោគួរតែផ្តល់ជូនរោងចក្រផ្គត់ផ្គង់នូវស្ថេរភាពនៃបញ្ជាទិញ និងពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើផែនការ និងការអនុវត្តការបញ្ជាទិញ។ ការទូទាត់គួរតែទាន់ពេលវេលា ហើយគំរូនៃការចំណាយដែលប្រើប្រាស់ដោយក្រុមហ៊ុននានា គួរតែអនុញ្ញាតឱ្យមានការទូទាត់ប្រាក់ឈ្នួលទ្រទ្រង់ជីវភាព និងអត្ថប្រយោជន៍ ផ្តល់កិច្ចគាំពារសង្គម និងការអនុវត្តការការពារសុវត្ថិភាពកម្មករ។

**3. ជំងឺ COVID-19**

- ទូទាត់ប្រាក់សម្រាប់ការបញ្ជាទិញទាំងអស់ដែលបានធ្វើឡើងក្នុងអំឡុងពេលជំងឺរាតត្បាត និងមិនស្នើសុំការពន្យារពេលទូទាត់ ការផ្លាស់ប្តូរបញ្ជាទិញនៅនាទីចុងក្រោយ និង/ឬការបញ្ចុះតម្លៃដោយសារការទាមទារទាំងនេះនឹងជះឥទ្ធិពលអវិជ្ជមានដល់កម្មករនិយោជិតកាត់ដេរ។
- ប្តេជ្ញាចិត្តជាសាធារណៈក្នុងការធានាប្រាក់ឈ្នួល និងចរចាដោយផ្ទាល់ជាមួយសហជីពលើកិច្ចព្រមព្រៀងដែលអាចអនុវត្តបានលើការធានាប្រាក់ឈ្នួល និងមូលនិធិធានាប្រាក់បំណាច់ ដើម្បីធានាថា

កម្មករនិយោជិតទាំងអស់ដែលធ្វើការក្នុងអំឡុងពេលវិបត្តិ COVID-19 ទទួលបានប្រាក់បៀវត្សពេញលេញរបស់ខ្លួន និង/ឬប្រាក់បំណាច់អំឡុងពេលជំងឺរាតត្បាត។

- ដោះស្រាយជាបន្ទាន់នូវវិវាទប្រាក់បំណាច់នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ដើម្បីឱ្យកម្មករនិយោជិតកាត់ដេរ ទទួលបានប្រាក់បំណាច់ពេញលេញ និងសិទ្ធិស្របច្បាប់ផ្សេងទៀត ជាបន្ទាន់។
- រៀបចំផែនការសុវត្ថិភាព និងសុខភាពការងារជំងឺ COVID-19 សម្រាប់រោងចក្រទាំងអស់ ដែលបង្ហាញពីសកម្មភាពដែលត្រូវអនុវត្ត ដើម្បីស្វែងរក និងទប់ស្កាត់ការរីករាលដាលជំងឺ COVID-19 រួមទាំងការផ្តល់ឧបករណ៍ការពារដល់កម្មករនិយោជិត និងសិទ្ធិឈប់សម្រាកពេលឈឺ ប្រសិនបើកម្មករឆ្លងជំងឺ COVID-19។

### 4. សិទ្ធិការងារ

- ធានាថាអ្នកផ្គត់ផ្គង់ទាំងអស់ការពារសិទ្ធិរបស់កម្មករនិយោជិតចំពោះសេរីភាពក្នុងការបង្កើតសមាគម និងការចរចាជាសមូហភាព។
- ស្វែងរកសេវាសវនកម្មសង្គមឯករាជ្យដើម្បីវាយតម្លៃ និងឆ្លើយតបទៅនឹងហានិភ័យសិទ្ធិមនុស្សនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ ដោយមានការចូលរួមពីកម្មករនិយោជិត និងសហជីព។ សវនកម្មសង្គមគួរៈ
    - ឆ្លុះបញ្ចាំងអំពីកាតព្វកិច្ចរបស់ក្រុមហ៊ុនម៉ាកយីហោក្រោមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស និងការណែនាំស្តីពីការត្រួតពិនិត្យភាពត្រឹមត្រូវ (Due Diligence Guides) OECD សម្រាប់ខ្សែសង្វាក់ផ្គត់ផ្គង់ដែលទទួលខុសត្រូវក្នុងវិស័យកាត់ដេរ និងស្បែកជើង។
    - ធ្វើឡើងដោយភាគីទីបីឯករាជ្យ ហើយគួរមានការសម្ភាសន៍ក្រៅ កន្លែងជាមួយកម្មករនិយោជិត និងសហជីព។
    - ដាក់បញ្ចូលការវិភាគមូលហេតុដើមដើម្បីកំណត់ថាតើ នីតិវិធីកំណត់តម្លៃ និងទិញប៉ះពាល់យ៉ាងដូចម្តេចដល់អនុលោមភាពសិទ្ធិការងារ។ និង
    - ត្រូវបានផ្សព្វផ្សាយជាសាធារណៈបានទាន់ពេលវេលា។
- ចាត់វិធានការដើម្បីធានាថា មេដឹកនាំសហជីព ឬអ្នករាយការណ៍មិនត្រូវបានកំណត់គោលដៅនៅក្នុងការព្យួរ និងការបញ្ឈប់ការងារដោយមូលហេតុជំងឺរាតត្បាត។

### 5. សិទ្ធិស្ត្រី និងសមភាពយេនឌ័រ

- ផ្សព្វផ្សាយអំពីគោលនយោបាយយេនឌ័រលម្អិតអំពីវិធានការនានាដែលត្រូវអនុវត្តដើម្បីសម្រេចបានប្រាក់ឈ្នួលស្មើភាពគ្នាសម្រាប់កម្មករនិយោជិតជាស្ត្រី និងធានាថា ការបៀតបៀនផ្លូវភេទ និងអំពើហិង្សាលើស្ត្រីមិនត្រូវបានអត់ឱនជាដាច់ខាតនៅកន្លែងធ្វើការ ក៏ដូចជាបង្កើតយន្តការដោះស្រាយសម្រាប់កម្មករនិយោជិតស្ត្រីដែលជួបប្រទះការរើសអើងយេនឌ័រផងដែរ។

## រដ្ឋាភិបាលក្នុងប្រទេសបង់ក្លាដែស និងកម្ពុជា

### 1. កែសម្រួលប្រាក់ឈ្នួលអប្បបរមាជាមួយនឹងប្រាក់ឈ្នួលទ្រទ្រង់ជីវភាព

- បង្កើនប្រាក់ឈ្នួលអប្បបរមាស្របតាមស្តង់ដារប្រាក់ឈ្នួលទ្រទ្រង់ជីវភាពអន្តរជាតិដែលអាចទុកចិត្តបាន ដើម្បីធានាថា ប្រាក់បៀវត្សនៅទូទាំងឧស្សាហកម្មកាត់ដេរមានកម្រិតគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការជាមូលដ្ឋានដូចជា អាហារ លំនៅឋាន និងឧបករណ៍ប្រើប្រាស់។

2. ធានាឱ្យមានការគាំទ្រគ្រប់គ្រាន់សម្រាប់កម្មករនិយោជិតក្នុងអំឡុងពេលជំងឺរាតត្បាត

- ធានាថាមានគោលនយោបាយច្បាស់លាស់ដើម្បីដឹកនាំវិធានការឆ្លើយតបចំពោះផលប៉ះពាល់បច្ចុប្បន្ន និងអនាគតនៃជំងឺរាតត្បាត។
- ត្រូវធានាថា ច្បាប់ការងារត្រូវបានអនុវត្តចំពោះកម្មករនិយោជិតកាត់ដេរទាំងអស់ និងចាត់វិធានការដើម្បីធានាថា និយោជកទាំងអស់នៅក្នុងឧស្សាហកម្មកាត់ដេរធ្វើអាជីវកម្មដោយអនុលោមតាមច្បាប់ការងារ។
- ធានាថា កិច្ចគាំពារសង្គមជាសកលសម្រាប់បុគ្គលទាំងអស់ដែលបាត់បង់ការងារក្នុងអំឡុងពេលជំងឺរាតត្បាត មានជំនួយហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីគ្របដណ្តប់លើថ្លៃចំណាយសម្រាប់ការរស់នៅ។

3. ដោះស្រាយអំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការ

- ផ្តល់សច្ចាប័នលើអនុសញ្ញាលេខ 190 របស់អង្គការពលកម្មអន្តរជាតិស្តីពីអំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការ និងអនុវត្តអនុសាសន៍ភ្ជាប់លេខ 206 ព្រមទាំងវិនិយោគទៅលើការផ្សព្វផ្សាយជាសាធារណៈនូវបទដ្ឋានទាំងនេះ។
- នៅប្រទេសកម្ពុជា ការផ្តល់សច្ចាប័នលើអនុសញ្ញាលេខ 144 របស់អង្គការពលកម្មអន្តរជាតិលើការពិគ្រោះយោបល់ត្រីភាគីក៏ត្រូវបានផ្តល់អនុសាសន៍ផងដែរ ដើម្បីធានាថាកំណែទម្រង់នីតិបញ្ញត្តិត្រូវមានការពិគ្រោះយោបល់ជាមុនប្រកបដោយប្រសិទ្ធភាពជាមួយកម្មករនិយោជិត និងសហជីព។

## រដ្ឋាភិបាលអូស្ត្រាលី

1. តម្លាភាព

- ធ្វើបច្ចុប្បន្នភាពច្បាប់ទាសភាពសម័យទំនើបឆ្នាំ2018 ដើម្បីកំណត់ឱ្យមានការបង្ហាញអំពីខ្សែសង្វាក់ផ្គត់ផ្គង់។ បញ្ជីអ្នកផ្គត់ផ្គង់គួរមាននូវព័ត៌មានដែលអាចអានដោយម៉ាស៊ីនអំពីគ្រឿងបង្គុំផលិតកម្ម និងបរិក្ខារកែច្នៃទាំងអស់ ព្រមទាំងឈ្មោះ អាសយដ្ឋាន ប្រភេទផលិតផលដែលផលិត ក្រុមហ៊ុនមេនៃអាជីវកម្មនៅទីតាំងផ្ទាល់ និងចំនួនកម្មករនៅតាមទីតាំងនីមួយៗ។
- ច្បាប់ស្តីពីទាសភាពសម័យទំនើបគួរធ្វើបច្ចុប្បន្នភាពដើម្បីដាក់បញ្ចូលក្របខណ្ឌអនុវត្តដ៏រឹងមាំ ដែលដាក់បញ្ចូលនូវការពិន័យសម្រាប់ក្រុមហ៊ុនអាជីវកម្មដែលមិនរាយការណ៍ ឬផ្តល់ព័ត៌មានមិនគ្រប់គ្រាន់ មិនពិត ឬបំភាន់។

2. បង្កើតច្បាប់ដើម្បីការពារសិទ្ធិកម្មករនិយោជិត

- សេចក្តីព្រាង និងរៀបចំច្បាប់ ដែលកំណត់ឱ្យក្រុមហ៊ុនអូស្ត្រាលីដែលកំពុងប្រតិបត្តិការនៅក្រៅប្រទេសអនុវត្តការត្រួតពិនិត្យភាពត្រឹមត្រូវផ្នែកសិទ្ធិមនុស្សឆ្លើយតបចំពោះយេនឌ័រ និងការពារកាតព្វកិច្ចរបស់ពួកគេស្របតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស៖
  - ច្បាប់នេះគួរបង្កើតឱ្យមានយន្តការដោះស្រាយអាចទទួលបានដែលមានលក្ខណៈឯករាជ្យមានធនធានសំបូរបែប គណនេយ្យភាព និងតម្លាភាព ដែលមានសិទ្ធិអំណាចក្នុងការស៊ើបអង្កេត និងផ្តល់នូវដំណោះស្រាយអាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព។
- កែតម្រូវកិច្ចព្រមព្រៀងពាណិជ្ជកម្មអូស្ត្រាលីឱ្យស្របតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ និងសមភាពយេនឌ័ររបស់យើង។ បទប្បញ្ញត្តិស្តីពីសិទ្ធិការងារដែលភ្ជាប់កាតព្វកិច្ចគួរដាក់បញ្ចូលទៅក្នុងកិច្ចព្រមព្រៀង ហើយបទប្បញ្ញត្តិទាំងអស់ដែលប៉ះពាល់ដល់សិទ្ធិកម្មករនិយោជិតដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងប្រទេសអូស្ត្រាលី ឬនៅក្នុងប្រទេសដៃគូ គួរតែត្រូវបានដកចេញ។

   - កិច្ចព្រមព្រៀងពាណិជ្ជកម្មគួរដាក់បញ្ចូលយន្តការដោះស្រាយដែលអាចឱ្យកម្មករនិយោជិតទទួលបានសំណង ជាការឆ្លើយតបចំពោះករណីនៃការរំលោភសិទ្ធិមនុស្ស។

**3. ដោះស្រាយអំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការ**

- ដឹកនាំនៅក្នុងការផ្តល់សច្ចាប័នលើអនុសញ្ញា ILO 190 ស្តីពីអំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការ និងអនុវត្តអនុសាសន៍ភ្ជាប់លេខ 206 និងលើកកម្ពស់អនុសញ្ញាក្នុងវិស័យការទូតបរទេស។

**4. បរិបទជំងឺ COVID-19**

- ធានាឱ្យមានការវិនិយោគទៅលើការស្តារឡើងវិញនូវវិបត្តិជំងឺ COVID-19 នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ផ្តល់អាទិភាពដល់កម្មករនិយោជិតស្ត្រីទុរគតដែលត្រូវបានបោះបង់ដោយសារវិបត្តិ រួមទាំងកម្មករនិយោជិតក្នុងឧស្សាហកម្មកាត់ដេរ ដោយផ្តោតលើការកសាងឡើងវិញឱ្យកាន់តែប្រសើរឡើង ដើម្បីធានាឱ្យមានការងារសមរម្យ ប្រាក់ឈ្នួលទ្រទ្រង់ជីវភាព និងកិច្ចគាំពារសង្គម។

# 3. លទ្ធផលនៃការស្រាវជ្រាវ

## ប្រទេសបង់ក្លាដែស

### ទិដ្ឋភាពទូទៅនៃឧស្សាហកម្មកាត់ដេរបង់ក្លាដែស

ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់រួចជាស្រេចរបស់បង់ក្លាដែស គឺជាឧស្សាហកម្មផ្តោតលើការនាំចេញដ៏ធំបំផុតរបស់ប្រទេស និងបានរួមចំណែកយ៉ាងសំខាន់ដល់កំណើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័សរបស់ប្រទេសបង់ក្លាដែសក្នុងរយៈពេលប៉ុន្មានទសវត្សរ៍កន្លងមកនេះ។ ដោយមានរោងចក្រចំនួន 4,600 កន្លែងនៅទូទាំងប្រទេស និងមានកម្មករនិយោជិតចំនួន 4.22 លាននាក់ ដែលក្នុងនោះប្រមាណ 60 ភាគរយគឺជាស្ត្រី[1] ឧស្សាហកម្មកាត់ដេរមានចំនួន 11.2 ភាគរយនៃ GDP របស់ប្រទេសបង់ក្លាដែស។[2]

នៅរយៈពេលប៉ុន្មានឆ្នាំមុនកើតមានជំងឺរាតត្បាត វិស័យកាត់ដេរមានកំណើនដ៏រឹងមាំ ដោយការនាំចេញកើនឡើងពី 2.54 ពាន់លានដុល្លារ ក្នុងឆ្នាំ2015 ទៅដល់ 3.4 ពាន់លានដុល្លារ ក្នុងឆ្នាំ2019 ដែលជាការកើនឡើងចំនួន 33.9 ភាគរយ។[3] ទីផ្សារនាំចេញសំខាន់ៗរបស់វិស័យនេះ គឺសហភាពអឺរ៉ុប (62 ភាគរយ) និងអាមេរិកខាងជើង (21 ភាគរយ) [4] ដោយប្រទេសអូស្ត្រាលីគឺជាទីផ្សារនាំចេញធំបំផុតទី 11។[5] វិបត្តិជំងឺ COVID-19 បានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់វិស័យកាត់ដេរ ដោយប្រាក់ចំណូលពីការនាំចេញបានធ្លាក់ចុះជិត 18 ភាគ

---

[1] Shahjahan et al (2020) *Demystifying the Worker's Ratio of Export Oriented RMG Industry*, Mapped in Bangladesh, https://mappedinbangladesh.org/wp-content/uploads/2021/08/Working-Paper_Worker-Ratio.pdf

[2] Textile Focus (2020) *Review and Outlook, 2020 Bangladesh Garments and Textile Industry,* http://textilefocus.com/review-outlook-2020-bangladesh-garments-textile-industry/

[3] The Business Standard (2021), *Why 300,000 new RMG jobs mask a grave reality about employment growth in the sector*, 6 October, https://www.tbsnews.net/features/panorama/why-300000-new-rmg-jobs-mask-grave-reality-about-employment-growth-sector-312124

[4] Asian Development Bank (2021) *COVID-19 and the Readymade Garments Industry in Bangladesh,* https://www.adb.org/sites/default/files/linked-documents/54180-001-sd-04.pdf

[5] World Integrated Trade Solutions (2021) *Bangladesh Textiles and Clothing Exports,* https://wits.worldbank.org/CountryProfile/en/Country/BGD/Year/2015/TradeFlow/Export/Partner/all/Product/50-63_TextCloth/Show/Partner%20Name;XPRT-TRD-VL;XPRT-PRDCT-SHR;/Sort/XPRT-TRD-VL/Chart/top10

រយ មកនៅត្រឹម 2.8 ពាន់លានដុល្លារក្នុងឆ្នាំ 2020។ ទោះបីជាមានបញ្ហាប្រឈមជាបន្តបន្ទាប់សម្រាប់ថៅកែរោងចក្រ និងកម្មករនិយោជិតកាត់ដេរយ៉ាងណាក្តី វិស័យនេះបានស្ទុះងើបឡើងវិញនៅឆ្នាំ2021 ដែលភាគច្រើនដោយសារតែការបើកហាងសម្លៀកបំពាក់ឡើងវិញនៅទូទាំងទ្វីបអឺរ៉ុប និងសហរដ្ឋអាមេរិក។ ប្រាក់ចំណូលនាំចេញបានកើនឡើងដល់ 3.4 ពាន់លានដុល្លារក្នុងឆ្នាំ2021 ប៉ុន្តែទោះបីយ៉ាងណា ចំនួននេះនៅតែទាបជាងកម្រិតមុនពេលមានជំងឺរាតត្បាត។

នៅក្នុងឧស្សាហកម្មកាត់ដេរទាំងមូល ប្រាក់ឈ្នួលប្រចាំខែរបស់កម្មករនិយោជិតមានកម្រិតទាបជាងប្រាក់ឈ្នួលទ្រទ្រង់ជីវភាពយ៉ាងខ្លាំង។ ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឧស្សាហកម្មនេះត្រូវបានកំណត់ក្នុងឆ្នាំ2018 ដែលមានចំនួន 95 ដុល្លារអាមេរិកក្នុងមួយខែ (8,000 BDT) តិចជាងមួយភាគបួននៃប្រាក់ឈ្នួលទ្រទ្រង់ជីវភាពដែលត្រូវបានគណនាដោយ AFWA ដែលមានចំនួន 571 ដុល្លារអាមេរិក (48,000 BDT) ក្នុងមួយខែនៅក្នុងឆ្នាំ2020 ដែលត្រូវបានកែតម្រូវដើម្បីអំណាចទិញស្មើគ្នា។[6] រដ្ឋាភិបាលបានគ្រោងដំឡើងប្រាក់ឈ្នួលអប្បបរមានៅឆ្នាំ2021 ពី 95 ដុល្លារអាមេរិក (8,000 BDT) ដល់ 100 ដុល្លារអាមេរិក (8,400 BDT) ក្នុងមួយខែ ដែលជាតួលេខទាបជាងការទាមទាររបស់សហជីព និងស្ទើរតែគ្រប់គ្រាន់ដើម្បីស្របតាមកម្រិតអតិផរណាកើនឡើង ដែលគណនាមានចំនួន 5.5 ភាគរយនៅក្នុងខែសីហា ឆ្នាំ2021។[7] ប៉ុន្តែបញ្ហាកាន់តែអាក្រក់ នៅពេលការបញ្ចុះបញ្ចូលពីវិស័យឯកជនបានបណ្តាលឱ្យរដ្ឋាភិបាលពន្យារពេលការដំឡើងប្រាក់ឈ្នួលអប្បបរមាដែលធ្វើឱ្យកម្មករនិយោជិត ទូទាត់ថ្លៃចំណាយរស់នៅដែលកើនឡើងពីប្រាក់ឈ្នួលមិនគ្រប់គ្រាន់រួចទៅហើយ។

## ផលប៉ះពាល់នៃជំងឺ COVID-19 មកលើឧស្សាហកម្មកាត់ដេរបង់ក្លាដែស

វិបត្តិសេដ្ឋកិច្ចដែលបង្កឡើងដោយជំងឺរាតត្បាតមកលើឧស្សាហកម្មកាត់ដេររបស់ប្រទេសបង់ក្លាដែស[8] ត្រូវបានមើលឃើញថា កម្មករនិយោជិតប្រមាណមួយលាននាក់ត្រូវបានដកចេញ ឬបណ្តេញចេញពីការងារ[9] ដោយសារតែឧស្សាហកម្មនេះត្រូវបានលុបចោលបញ្ជាទិញ ការបិទរោងចក្រ និងការខកខានទូទាត់ប្រាក់របស់ម៉ាកយីហោអន្តរជាតិសម្រាប់ការបញ្ជាទិញដែលកំពុងដំណើរការរបស់ខ្លួន។ យោងតាមសមាគមផលិតករ និងអ្នកនាំចេញសម្លៀកបំពាក់បង់ក្លាដែស (BGMEA) ក្រុមហ៊ុនម៉ាកយីហោចំនួន 1,931 ត្រូវបានពន្យារពេលផ្អាក ឬលុបចោលជាឯកតោភាគីនូវបញ្ជាទិញរហូតដល់ 3.7 ពាន់លានដុល្លារអាមេរិក នៅចន្លោះខែមីនា និងខែមិថុនា ឆ្នាំ 2020។[10] បន្ទាប់ពីមានយុទ្ធនាការនានា ដូចជាយុទ្ធនាការ '#PayUp' នៃយុទ្ធនាការបោសសម្អាត

---

[6] Based on living wage framework developed by the Asia Floor Wage Alliance using a PPP conversion rate for Bangladesh of 40.4, https://asia.floorwage.org/our-work/#tab-id-3

[7] Bangladesh Bank (2021) *Inflation Indicator*, https://www.bb.org.bd/econdata/inflation.php

[8] Rabbani, Atonu et al (2021) *Impact of COVID-19 on Non-member RMG Factories in Bangladesh,* Mapped in Bangladesh, https://mappedinbangladesh.org/wp-content/uploads/2020/09/MiB-Research-Brief-on-Non-Member-RMG-Factories.pdf

[9] Anner, M (2020) *Abandoned? The Impact of Covid-19 on Workers and Businesses at the Bottom of Global Garment Supply Chains*, Penn State Centre for Global Worker Rights, http://www.workersrights.org/wp-content/uploads/2020/03/Abandoned-Penn-State-WRC-Report-March-27-2020.pdf

[10] The Daily Star (2020) *Is Foul Play the New Normal?*, June 30, https://www.thedailystar.net/business/news/you-suffer-we-survive-1920733

សម្លៀកបំពាក់ ។ ក្រុមហ៊ុនម៉ាកយីហោជាច្រើន រួមទាំងក្រុមហ៊ុនរបស់អូស្ត្រាលីផងដែរ បានប្តេជ្ញាចិត្តក្នុងការទិញបញ្ជាទិញរបស់ខ្លួន។ ទោះបីយ៉ាងណា ក្រុមហ៊ុនមួយចំនួនបានបន្តស្នើសុំការបញ្ចុះតម្លៃយ៉ាងច្រើន។[11]

ឧស្សាហកម្មកាត់ដេរត្រូវបានរងផលប៉ះពាល់បន្ថែមទៀតដោយសារការបិទខ្ទប់របស់រដ្ឋាភិបាលចាប់ពីថ្ងៃទី26 ខែមីនា ឆ្នាំ2020 ដែលបានបិទគ្រប់វិស័យទាំងអស់ លើកលែងតែសេវាសង្គ្រោះបន្ទាន់។ វិធានការរឹតបន្តឹងទាំងនេះនឹងត្រូវបន្តរយៈពេលចំនួន 7 ដង ក្នុងរយៈពេលប៉ុន្មានខែខាងមុខ និងត្រូវបន្តអនុវត្តរហូតដល់ថ្ងៃទី30 ខែឧសភា ឆ្នាំ 2020។[12] ដោយសារឧស្សាហកម្មកាត់ដេរជួបប្រទះវិបត្តិ រដ្ឋាភិបាលបង់ក្លាដែសបានផ្តល់កញ្ចប់ថវិកាសង្គ្រោះចំនួន 595 លានដុល្លារអាមេរិក (50 ពាន់លាន BDT)[13] ដើម្បីគាំទ្រដល់រោងចក្រនានាក្នុងការបន្តបើកប្រាក់បៀវត្សជូនកម្មករនិយោជិតរបស់ខ្លួន នៅពេលដែលក្រុមហ៊ុនម៉ាកយីហោនានាបានលុបចោល ឬផ្អាកបញ្ជាទិញរបស់ខ្លួន។[14] កញ្ចប់ថវិកាសង្គ្រោះនេះបានផ្តល់ជំនួយសង្គ្រោះដែលត្រូវការច្រើនសម្រាប់កម្មករនិយោជិតកាត់ដេរមួយចំនួន។ ទោះបីយ៉ាងណា ការកម្រិតសិទ្ធិទទួលបានមានន័យថា មានតែរោងចក្រដែលជាសមាជិកនៃស្ថាប័នពាណិជ្ជកម្មទាំងពីរ គឺសមាគមរោងចក្រ និងអ្នកនាំចេញសម្លៀកបំពាក់បង់ក្លាដែស (Bangladesh Garment Manufacturers) (BGMEA) និងសមាគមរោងចក្រ និងអ្នកនាំចេញសម្លៀកបំពាក់ចាក់បង់ក្លាដែស (Knitwear Manufacturers and Exporters Association) (BKMEA) តែប៉ុណ្ណោះដែលអាចទទួលបានជំនួយឧបត្ថម្ភនេះ។ កម្មករនិយោជិតកាត់ដេរទាំងអស់នៅរោងចក្រផ្សេងទៀតត្រូវបានបញ្ឈប់ពីការងារដោយគ្មានជំនួយឧបត្ថម្ភ។

ជាងនេះទៅទៀត យោងតាមរបាយការណ៍ដែលចេញផ្សាយដោយមជ្ឈមណ្ឌលសិទ្ធិកម្មករសកលនៃសាកលវិទ្យាល័យ Penn State University និងសមាគមសិទ្ធិកម្មករ (Penn State University's Centre for Global Workers' Rights and the Worker Rights Consortium (WRC)) មានកម្មករនិយោជិតកាត់ដេរចំនួនជាងមួយលាននាក់នៅក្នុងប្រទេសបង់ក្លាដែសត្រូវបានបណ្តេញចេញ ឬបញ្ឈប់ពីការងារមុនពេលកញ្ចប់ថវិកាសង្គ្រោះត្រូវបានប្រកាស។ រោងចក្រដែលបានស្ទង់មតិបានលើកឡើងថា 98 ភាគរយនៃអ្នកបញ្ជាទិញរបស់ខ្លួនបានបដិសេធមិនចូលរួមបង់ថ្លៃចំណាយលើប្រាក់ឈ្នួលមួយផ្នែកដល់កម្មករនិយោជិតដែលត្រូវកំណត់ដោយច្បាប់ឡើយ ហើយ 72 ភាគរយនៃកម្មករនិយោជិតដែលត្រូវបានបណ្តេញចេញពីការងារត្រូវបានបញ្ជូនទៅស្រុកកំណើត ដោយគ្មានប្រាក់ឈ្នួល។[15]

ប្រទេសបង់ក្លាដែសបានរងការវាយប្រហារដោយរលកទីពីរដ៏គួរឱ្យព្រួយបារម្ភនៃមេរោគបំលែងថ្មី Delta COVID-19 នៅក្នុងខែមេសា ឆ្នាំ2021។ រដ្ឋាភិបាលបានប្រកាសអំពីការបិទខ្ទប់ដ៏តឹងរ៉ឹងរយៈពេលមួយសប្តាហ៍នៅថ្ងៃទី05 ខែមេសា ហើយនៅតែមានការរឹតបន្តឹងទៅលើការប្រមូលផ្តុំសាធារណៈ និងវិស័យនានា នៅចន្លោះខែមេសា និងខែមិថុនា។ នៅខែកក្កដា សភាពធ្ងន់ធ្ងរនៃវិបត្តិសុខភាពកំពុងគំរាមកំហែងថានឹងអាចមាន

---

11 សម្រាប់ព័ត៌មានបន្ថែមសូមមើល https://cleanclothes.org/campaigns/payup

12 The Dhaka Tribune (2020) *Coronavirus: Bangladesh declares public holiday from March 26 to April 4*, 23 March, https:/ /bit.ly/2DluRia

13 The bailout package enabled factories to take out loans with private banks at subsidised interest rates, with the Bangladesh Government covering the bulk of the interest.

14 Brac Institute of Governance and Development (2020) *5000 crore novel corona financial stimulus package for export-oriented industries: RMG trade union responses*, 18 June, https://bigd.bracu.ac.bd/wp-content/uploads/2020/06/Report_Trade-Union-Responses_Financial-Stimulus-Package.pdf

15 Anner, M (2020) *Abandoned? The Impact of Covid-19 on Workers and Businesses at the Bottom of Global Garment Supply Chains*.

ភាពលើសលុបទៅលើប្រព័ន្ធសុខាភិបាលដែលកំពុងតែមានសភាពយ៉ាប់យ៉ឺនស្រាប់ហើយការបិទខ្ទប់ប្រទេសដ៏តឹងរ៉ឹងមួយទៀតត្រូវបានដាក់ឱ្យអនុវត្តចាប់ពីថ្ងៃទី01 ដល់ថ្ងៃទី14 ខែកក្កដា ហើយបន្ទាប់ពីមានការដកចេញមួយរយៈពេលខ្លី ចាប់ពីថ្ងៃទី23 ខែកក្កដា រហូតដល់ថ្ងៃទី11 ខែសីហា។[16]

កម្មករនិយោជិតកាត់ដេរបានជួបប្រទះការលំបាកយ៉ាងខ្លាំងនៅក្នុងអំឡុងពេលនេះ។ ដោយ រងសម្ពាធពីថៅកែរោងចក្រដែលកំពុងដោះស្រាយបញ្ហាលុបចោលបញ្ជាទិញ និងអលទ្ធភាពក្នុងការអនុវត្តតាមការសន្យាក្នុងអំឡុងពេលនេះ រដ្ឋាភិបាល បានអនុញ្ញាតឱ្យរោងចក្របន្តបើកដំណើរការនៅអំឡុងពេលបិទខ្ទប់។[17] ដោយសារមិនអាចទទួលបានសេវាគាំពារសង្គមគ្រប់គ្រាន់ កម្មករនិយោជិតបានបង្ខំចិត្តធ្វើការដើម្បីបំពេញតម្រូវការសេដ្ឋកិច្ច ប៉ុន្តែស្ថានភាពនេះបានមកនូវហានិភ័យសំខាន់ៗ។ ជាងនេះទៅទៀត ប្រព័ន្ធដឹកជញ្ជូនមិនដំណើរការ ហើយដោយសារគ្មានសេវាដឹកជញ្ជូនដែលផ្តល់ដោយថៅកែរោងចក្រកាត់ដេរ កម្មករនិយោជិតត្រូវដើបដើរតាំងពីព្រឹកព្រលឹមក្នុងចម្ងាយជាច្រើនគីឡូម៉ែត្រដើម្បីទៅដល់កន្លែងធ្វើការរបស់ខ្លួន ហើយបន្ទាប់មកត្រូវដើរត្រឡប់ទៅផ្ទះវិញនៅពេលយប់ បន្ទាប់ពីបញ្ចប់ការងាររបស់ខ្លួនរួចរាល់។[18]

## ទិដ្ឋភាពទូទៅនៃវិធីសាស្ត្រ

អង្គការ ActionAid បានធ្វើការជាមួយហាង Workers' Cafés ដែលបានបង្កើតឡើងនៅទូទាំងក្រុងដាកា ដើម្បីធ្វើការស្ទង់មតិជាមួយកម្មករនិយោជិតកាត់ដេរចំនួន 100 នាក់នៅទូទាំងរោងចក្រចំនួន 34 ដែលមានទីតាំងនៅក្នុងក្រុងដាកា។ កម្មករនិយោជិតចំនួនកៅសិបប្រាំបួន នាក់ក្នុងចំណោម 100 នាក់ដែលត្រូវបានស្ទង់មតិសម្រាប់ការសិក្សានេះគឺជាស្ត្រី។ ការស្ទង់មតិត្រូវបានកំណត់ត្រឹមគំរូសិក្សាតូចៗ តំណាងលើសលុបនៃចំនួនកម្មករនិយោជិតជាស្ត្រី និងវិធីសាស្ត្រជ្រើសរើសគំរូសិក្សា ដោយក្រុមគំរូសិក្សាអាស្រ័យលើអ្នកដែលចូលរួមនៅក្នុងហាង Workers' Cafés ក្នុងអំឡុងពេលដែលការស្រាវជ្រាវត្រូវបានធ្វើឡើង។

ការផ្តោតសំខាន់លើរោងចក្រដែលមានមូលដ្ឋាននៅទីក្រុងដាកា ក៏បានដាក់កម្មករនិយោជិតនៅមជ្ឈមណ្ឌលឧស្សាហកម្មផ្សេងទៀតជាច្រើន នៅក្រៅវិសាលភាពនៃការស្រាវជ្រាវនេះផងដែរ។ ជាងនេះទៅទៀត ការស្រាវជ្រាវត្រូវបានធ្វើឡើងទៅលើកម្មករនិយោជិតកាត់ដេរដែលបម្រើការងារនៅក្នុងរោងចក្រដែលជាសមាជិកសមាគមពាណិជ្ជកម្មផ្លូវការចំនួនពីរ គឺសមាគមរោងចក្រ និងអ្នកនាំចេញសម្លៀកបំពាក់បង់ក្លាដែស (Bangladesh Garment Manufacturers) និងសមាគមរោងចក្រ និងអ្នកនាំចេញសម្លៀកបំពាក់ចាក់បង់ក្លាដែស (Knitwear Manufacturers and Exporters Association) [19]ព្រមទាំងរោងចក្រមិនមែនសមាជិក ដែលនាំឱ្យមានភាពខុសគ្នា

---

16 Hindustan Times (2021) *Bangladesh to Come Out of Covid-19 lockdown*, August 11, https://www.hindustantimes.com/world-news/bangladesh-to-come-out-of-covid-19-lockdown-today-shops-malls-offices-to-open-101628645745300.html

17 The Daily Star (2021) *Lockdown After Eid: Govt mulls allowing RMG units to stay open*, July 15, https://www.thedailystar.net/health/disease/coronavirus/news/lockdown-after-eid-govt-mulls-allowing-rmg-units-stay-open-2130566

18 The Daily Star (2021) *Garment workers forced to walk, board overcrowded vehicles on 2nd day of 'lockdown'*, April 15, https://www.thedailystar.net/garment-workers-forced-walk-board-overcrowded-vehicles-2nd-day-lockdown-2077845; Dhaka Tribune (2021) *Survey: 81% RMG workers walk to their workplaces amid lockdown*, *https://www.dhakatribune.com/business/2021/04/26/survey-81-rmg-workers-walk-to-their-workplaces-amid-lockdown*

19 Only factories that are members of BGMEA or BKMEA take direct orders from foreign buyers. Non-member factories then subcontract from member factories and range in their size and compliance labour laws.

នៃលទ្ធផលស្នង់មតិ ដោយសារភាពខុសគ្នានៃបទប្បញ្ញត្តិ បទដ្ឋានប្រតិបត្តិការ និងការអនុលោមតាមច្បាប់ការងាររវាងរោងចក្រជាសមាជិក និងមិនមែនសមាជិក។

## លទ្ធផលនៃការស្រាវជ្រាវនៅប្រទេសបង់ក្លាដែស

### 1. ស្ថានភាពសេដ្ឋកិច្ចមិនច្បាស់លាស់របស់កម្មករនិយោជិតកាត់ដេរកាន់តែមានសភាពធ្ងន់ធ្ងរដោយសារការបញ្ឈប់ពីការងារក្នុងវិបត្តជំងឺ COVID-19 និងការកាត់ប្រាក់ឈ្នួល

កម្មករនិយោជិតកាត់ដេរនៅប្រទេសបង់ក្លាដែស បានទទួលប្រាក់ឈ្នួលក្រីក្ររួចទៅហើយ មុនពេលទទួលរងផលប៉ះពាល់ពីវិបត្តិជំងឺរាតត្បាត ដោយមានអ្នកឆ្លើយសម្ភាសន៍ភាគច្រើន (90 ភាគរយ) បានលើកឡើងថាខ្លួនមានប្រាក់ចំណូលទីពីរនៅក្នុងគ្រួសារ ដោយសារតែប្រាក់ឈ្នួលដែលពួកគេទទួលបានពីការងារតែមួយមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ជីវភាពខ្លួនឯង និងគ្រួសាររបស់ខ្លួនឡើយ។

- នៅក្នុងខែមករា ឆ្នាំ2020 កម្មករនិយោជិតដែលបានស្ទង់មតិ ទទួលបានប្រាក់បៀវត្សជាមធ្យមចំនួន 108 ដុល្លារអាមេរិក (9,103.50 BDT) ដែលទាបជាងប្រាក់ឈ្នួលទ្រទ្រង់ជីវភាពប្រចាំខែចំនួន 571 ដុល្លារអាមេរិក (48,000 BDT)
- កម្មករនិយោជិតភាគច្រើន រកប្រាក់បានច្រើនជាងប្រាក់ឈ្នួលអប្បបរមាមុនពេលវិបត្តិជំងឺរាតត្បាត ទោះបីយ៉ាង ចំនួន 8% បានលើកឡើងអំពីការរកប្រាក់ចំណូលបានទាបជាងប្រាក់ឈ្នួលអប្បបរមា។

នៅក្នុងវិស័យទាំងមូល ប្រាក់ឈ្នួលរបស់កម្មករនិយោជិតកាត់ដេរស្ថិតនៅក្រោមប្រាក់ឈ្នួលទ្រទ្រង់ជីវភាព (571 ដុល្លារអាមេរិក ឬ 48,000 BDT ក្នុងមួយខែ)។ ចំណុចដែលកាន់តែអាក្រក់ជាងនេះគឺ ការគណនាប្រាក់ឈ្នួលទ្រទ្រង់ជីវភាពរបស់ប្រទេសបង់ក្លាដែសមិនបានរាប់បញ្ចូលប្រាក់ចំណូលដែលរកបានតាមរយៈការងារម៉ោងបន្ថែមឡើយ ប៉ុន្តែប្រាក់បៀវត្សដែលបានរាយការណ៍ដោយកម្មករនិយោជិតបានដាក់បញ្ចូល ដែលធ្វើគម្លាតរវាងប្រាក់បៀវត្សកម្មករនិយោជិត និងប្រាក់ឈ្នួលទ្រទ្រង់ជីវភាពកាន់តែរីកធំថែមទៀត។ ជាមធ្យម កម្មករបានលើកឡើងថា ប្រាក់បៀវត្សរបស់ខ្លួនបានដាក់បញ្ចូលទឹកប្រាក់ចំនួន 13 ដុល្លារអាមេរិក (1,102.50 BDT) ក្នុងមួយខែ ជាប្រាក់ធ្វើការថែមម៉ោង ដែលស្មើនឹង 12 ភាគរយនៃប្រាក់បៀវត្សសរុប។

ចំណុចដ៏គួរឱ្យព្រួយបារម្ភនោះគឺថា កម្មករនិយោជិត 1 នាក់ ក្នុងចំណោម 12 នាក់បានលើកឡើងថា ខ្លួនទទួលបានប្រាក់ចំណូលទាបជាងប្រាក់ឈ្នួលអប្បបរមាដែលបានកំណត់ តាំងពីមុនពេលវិបត្តិជំងឺរាតត្បាតបានកើតឡើង។ ចំណុចនេះបង្ហាញអំពីភាពខុសគ្នារវាងរោងចក្រដែលជាសមាជិកនៃសមាគមពាណិជ្ជកម្មផ្លូវការទាំងពីរ និងរោងចក្រមិនមែនសមាជិកដែលដើរតួនាទីកិច្ចសន្យាបន្ត ដែលបទប្បញ្ញត្តិ និងការអនុវត្តច្បាប់ការងារមានភាពទន់ខ្សោយជាង និងមានការគាបសង្កត់ពីសហាជីពកាន់តែខ្លាំងនៅក្នុងរោងចក្រកិច្ចសន្យាបន្ត ដែលបណ្តាលឱ្យកម្មករនិយោជិតជាញឹកញាប់ទទួលបានប្រាក់បៀវត្សទាបជាងប្រាក់ឈ្នួលអប្បបរមា ឬទទួលបានការទូទាត់ទៅតាមទិន្នផលការងាររបស់ខ្លួន។




**ការបញ្ឈប់កម្មករនិយោជិតពីការងារដែលរីករាលដាលនៅក្នុងឧស្សាហកម្មកាត់ដេរបង់ក្លាដែសទាំងមូល**

កម្មករនិយោជិតកាត់ដេរបានធ្លាក់ចូលទៅក្នុងវិបត្តិ COVID-19 ដែលរស់នៅត្រដាបត្រដួសជាមួយនឹងប្រាក់ឈ្នួលតិចតួចបំផុត និងមានការគាំពារតិចតួច ដើម្បីជួយឧបត្ថម្ភនៅក្នុងគ្រាមានអាសន្ន។ ប៉ុន្តែជំងឺរាតត្បាតបានធ្វើឱ្យស្ថានការណ៍កាន់តែអាក្រក់ខ្លាំងឡើង ដោយកម្មករនិយោជិតជាច្រើនត្រូវបាត់បង់ការងារ ជួបប្រទះភាពអត់ការងារធ្វើរយៈពេលវែង បន្ទាប់ពីត្រូវបានបណ្តេញចេញពីការងារ និងការមិនទទួលបានប្រាក់បំណាច់ជាដើម។

- កម្មករនិយោជិតចំនួន 36% ដែលបានស្ទង់មតិ បានបាត់បង់ការងាររបស់ខ្លួននៅក្នុងដំណាក់កាលនៃជំងឺរាតត្បាត
- ក្នុងចំណោមនោះ 94% ត្រូវបានបញ្ឈប់ពីការងារនៅពេលដែលការបិទខ្ទប់ដំបូងត្រូវបានប្រកាសកាលពីថ្ងៃទី26 ខែមីនា ឆ្នាំ2020
- ចំនួន 27% បានចំណាយពេលពី បួន ទៅ ប្រាំពីរ ខែដើម្បីស្វែងរកការងារផ្សេងទៀត
- ចំនួន 30% បន្តអត់មានការងារធ្វើរហូតដល់រយៈពេល 16 ខែ
- មានកម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារចំនួនតែ 14% ប៉ុណ្ណោះដែលបានទទួលប្រាក់បំណាច់ការងារ

លទ្ធផលទាំងនេះបញ្ជាក់កាន់តែច្បាស់អំពីលទ្ធផលរកឃើញពីការស្រាវជ្រាវមុន ដែលបង្ហាញថា កម្មករជាច្រើនបានបាត់បង់ការងាររួចទៅហើយនៅពេលដែលកញ្ចប់ថវិកាសង្គ្រោះរបស់រដ្ឋាភិបាលត្រូវបានប្រកាសកាលពីថ្ងៃទី25 ខែមីនា ឆ្នាំ2020។[20]

កម្មករនិយោជិតក៏បានខិតខំស្វែងរកការងារថ្មីផងដែរ នៅដែលជំងឺ COVID-19 រីករាលដាលនៅទូទាំងប្រទេស ការលំបាកក្នុងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនសាធារណៈ និងការធ្វើដំណើរពីស្រុកមួយទៅស្រុកមួយ បានធ្វើឱ្យប៉ះពាល់ដល់កម្មករនិយោជិត ដែលបានបង្ខំចិត្តវិលត្រឡប់ទៅស្រុកកំណើតវិញ ដោយសារតែពួកគេពុំមានលទ្ធភាពបង់ថ្លៃឈ្នួលផ្ទះ។ ក្នុងចំណោមអ្នកដែលបាត់បង់ការងារ មានចំនួន 27 ភាគរយបានចំណាយពេលពី បួន ទៅ ប្រាំពីរ ខែដើម្បីស្វែងរកការងារថ្មី ហើយកម្មករជិតមួយ នាក់ក្នុងចំណោមបីនាក់ត្រូវចំណាយពេលរហូតដល់ 16 ខែដើម្បីស្វែងរកការងារថ្មី។ អ្នកដែលបាត់បង់ការងារក៏ត្រូវចាកចេញពីការងារដោយគ្មានជំនួយឧបត្ថម្ភពីរោងចក្រដែរ។

---

20 Anner, M (2020) *Abandoned? The Impact of Covid-19 on Workers and Businesses at the Bottom of Global Garment Supply Chains*.

កម្មករនិយោជិតដែលបាត់បង់ការងារមានការលំបាកក្នុងការទទួលបានប្រាក់បំណាច់។ មានកម្មករនិយោជិតតែម្នាក់ប៉ុណ្ណោះក្នុងចំណោមប្រាំមួយនាក់ដែលបានបាត់បង់ការងារ បានលើកឡើងថា ខ្លួនបានទទួលប្រាក់បំណាច់ ហើយគ្មានកម្មករនិយោជិតណាម្នាក់បានទទួលប្រាក់ពីការផ្អាកការងារឡើយ។ ថវិកាសង្គ្រោះរបស់រដ្ឋាភិបាលបានផ្តល់ប្រាក់បៀវត្សត្រឹមតែបីខែប៉ុណ្ណោះសម្រាប់កម្មករនិយោជិតនៅក្នុងរោងចក្រដែលជាសមាជិកនៃស្ថាប័នពាណិជ្ជកម្ម BGMEA និង BKMEA។ ទឹកប្រាក់នេះត្រូវបានផ្តល់ជូនដោយផ្ទាល់ដល់កម្មករនិយោជិតតាមរយៈក្រុមហ៊ុនផ្តល់សេវាហិរញ្ញវត្ថុចល័ត (MFS) និងបានគាំទ្រដល់អ្នកដែលមានការងារធ្វើរួចហើយក្នុងរយៈពេលបីខែដំបូងនៃជំងឺរាតត្បាត។ កម្មករនិយោជិតដែលមិនមែនជាសមាជិកមិនបានទទួលការគាំទ្រឡើយ។

*អត្ថបទបែកធ្លាយ៖ កម្មករនិយោជិតស្ថិតក្នុងស្ថានភាពបើមិនខិតខំនឹងពុំទទួលបានអ្វីទាំងអស់ គឺទាំងអ្នកដែលមានការងារធ្វើ និងអ្នកត្រូវមកធ្វើការក្នុងអំឡុងពេលបិទសេវាកម្ម បើមិនដូច្នោះនឹងត្រូវបណ្តេញចេញពីការងារ។ ដូចដែលកម្មករនិយោជិតម្នាក់បានលើកឡើងថា គាត់ត្រូវតែដើរទៅធ្វើការ បើមិនដូច្នោះនឹងត្រូវគេបណ្តេញចេញពីការងារ។*

**ប្រាក់ឈ្នួលរបស់កម្មករនិយោជិតកាត់ដេរបានធ្លាក់ចុះចំនួន 8 ដុល្លារអាមេរិកក្នុងអំឡុងពេលជំងឺរាតត្បាត**
ទន្ទឹមនឹងការបញ្ឈប់ពីការងារ និងការលំបាកក្នុងការស្វែងរកការងារផ្សេងទៀត កម្មករនិយោជិតចំនួន 46 ភាគរយបានកាត់បន្ថយម៉ោងធ្វើការ ដោយសារតែការកាត់បន្ថយប្រាក់ចំណូលពីការងារថែមម៉ោង។ ជាលទ្ធផល កម្មករនិយោជិតត្រូវបានកាត់ប្រាក់ឈ្នួល ដោយសារតែមូលហេតុជំងឺរាតត្បាត។

- នៅក្នុងខែសីហា ឆ្នាំ2021 កម្មករនិយោជិតបានឱ្យដឹងថា ខ្លួនទទួលបានប្រាក់បៀវត្សជាមធ្យម 100 ដុល្លារអាមេរិក (8,423 BDT) ក្នុងមួយខែ។
- ចំនួននេះឆ្លុះបញ្ចាំងអំពីការកាត់បន្ថយចំនួន 8 ដុល្លារអាមេរិក (680.50 BDT) ក្នុងមួយខែ លើប្រាក់បៀវត្សមុនជំងឺរាតត្បាត ដែលជាការកាត់ប្រាក់ឈ្នួល 7.5 ភាគរយ។

សម្រាប់កម្មករនិយោជិតដែលកំពុងរស់នៅ ឬស្ថិតនៅក្រោមបន្ទាត់ក្រីក្រ ការកាត់ប្រាក់ឈ្នួលនេះកាន់តែធ្វើឱ្យពួកគេធ្លាក់ទៅក្នុងភាពក្រីក្រថែមទៀត។




2. **កម្មករនិយោជិតកាត់ដេរបានជួបប្រទះបញ្ហាអសន្តិសុខស្បៀងធ្ងន់ធ្ងរ និងបំណុលកើនឡើងបន្ទាប់ពីជំងឺ COVID-19**

ភាពមិនគ្រប់គ្រាន់នៃជំនួយហិរញ្ញវត្ថុដែលមានសម្រាប់កម្មករនិយោជិតកាត់ដេរក្នុងអំឡុងពេលជំងឺរាតត្បាត បានបន្សល់ទុកនូវភាពអត់ឃ្លាន និងបំណុលដ៏ធ្ងន់ធ្ងរ ដោយសារកម្មករនិយោជិតពិបាកស្វែងរកប្រាក់ដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន។

- 85% នៃកម្មករដែលបានស្ទង់មតិ បានបង្ខំចិត្តកាត់បន្ថយការចំណាយរបស់ខ្លួនក្នុងអំឡុងពេលមានជំងឺរាតត្បាត ដោយចំនួន 15% បានលើកឡើងថា ខ្លួនបានចំណាយអស់ប្រាក់សន្សំដើម្បីបំពេញតម្រូវការប្រចាំថ្ងៃរបស់គ្រួសាររបស់ខ្លួន
- 70% ពុំមានប្រាក់គ្រប់គ្រាន់ដើម្បីទទួលទានអាហារប្រចាំថ្ងៃឱ្យបានគ្រប់គ្រាន់សម្រាប់ខ្លួនឯង និងក្រុមគ្រួសារ
- ក្នុងចំណោមនោះ 36% បានបង្ខំចិត្តអត់អាហាររៀងរាល់សប្តាហ៍ ហើយ 25% បាននិយាយថា ខ្លួនបានប្រឈមមុខនឹងវិបត្តិអាហារប្រចាំថ្ងៃ
- 42% បានលើកឡើងថា ខ្លួនត្រូវដកប្រាក់កម្ចីបន្ទាន់ដើម្បីផ្គត់ផ្គង់ខ្លួនឯងក្នុងអំឡុងពេលជំងឺរាតត្បាត

នៅពេលជំងឺរាតត្បាតចាប់ផ្តើមផ្ទុះឡើង រដ្ឋាភិបាលបានអនុវត្តកម្មវិធីចែកចាយអាហារសង្គ្រោះបន្ទាន់មួយចំនួន ដោយផ្តល់អាហាររយៈពេលមួយសប្តាហ៍ដល់គ្រួសារដែលរងផលប៉ះពាល់។ ទោះបីយ៉ាងណា មានកម្មករនិយោជិតដែលបានស្ទង់មតិចំនួនតែមួយភាគបីប៉ុណ្ណោះដែលលើកឡើងថា ខ្លួនបានទទួលការគាំទ្រតាមរូបភាពមួយចំនួនពីរដ្ឋាភិបាលក្នុងអំឡុងពេលដែលជំនួយឧបត្ថម្ភត្រូវបានផ្តល់ជូន។

*អត្ថបទសំខាន់៖ កម្មករនិយោជិតបានលើកឡើថា ខ្លួនត្រូវឈរនៅខាងក្រៅ និងរង់ចាំនៅតាមដងផ្លូវដោយសង្ឃឹមថានឹងទទួលបានជំនួយពីរដ្ឋាភិបាល ឬជំនួយស្បៀងអាហារពីអង្គការសប្បុរសធម៌ ចំណែកកម្មករនិយោជិតផ្សេងទៀតបានខ្ចីប្រាក់យ៉ាងច្រើនពីសមាជិកគ្រួសារ ឬអ្នកផ្តល់ប្រាក់កម្ចី ដើម្បីរ៉ាប់រងការចំណាយរបស់ខ្លួន។*

ក្នុងចំណោមអ្នកដែលបានជួបប្រទះអសន្តិសុខស្បៀង ចំនួនជាងពាក់កណ្តាលបាននិយាយថា ខ្លួនបានទទួលរងវិបត្តិអសន្តិសុខស្បៀងកម្រិតមធ្យមទៅធ្ងន់ធ្ងរ ដោយម្នាក់ក្នុងចំណោមបីនាក់បានអះអាងថាខ្លួនបានបង្ខំចិត្តអត់អាហាររៀងរាល់សប្តាហ៍ និងពុំមានអាហារទទួលទានជាច្រើនថ្ងៃ។ មួយភាគបួនក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ទាំងអស់បានជួបប្រទះស្ថានភាពកាន់តែអាក្រក់ទៅៗ ដោយសារពួកគេបានលើកឡើងថា ខ្លួនកំពុងប្រឈមមុខនឹងវិបត្តិជារៀងរាល់ថ្ងៃក្នុងការផ្តល់អាហារគ្រប់គ្រាន់សម្រាប់ខ្លួនឯង និងក្រុមគ្រួសារ។

កម្មករនិយោជិតក៏ជួបប្រទះបំណុលកើនឡើងនៅក្នុងអំឡុងវិបត្តិជំងឺរាតត្បាតផងដែរ ពោលគឺក្នុងចំណោមអ្នកដែលបានស្ទង់មតិ ចំនួនជិតពីរភាគបីបានលើកឡើងថា ខ្លួនពុំមានប្រាក់សម្រាប់បង់ថ្លៃឈ្នួល ដោយកម្មករនិយោជិតបានអះអាងថា ខ្លួននៅជំពាក់ថ្លៃឈ្នួលម្ចាស់ផ្ទះ ហើយទើបតែចាប់ផ្តើមសងថ្លៃឈ្នួលនេះវិញប៉ុណ្ណោះ។ ជាងនេះទៅទៀត អ្នកឆ្លើយសម្ភាសន៍ចំនួន 4 នាក់ ក្នុងចំណោម 10 នាក់បាននិយាយថា ខ្លួនត្រូវដកប្រាក់កម្ចីបន្ទាន់ដើម្បីយកមកផ្គត់ផ្គង់ខ្លួនឯង នៅក្នុងស្ថានភាពដែលមិនច្បាស់លាស់រយៈពេលជាច្រើនខែក្នុងអំឡុងពេលមានជំងឺរាតត្បាត។

### 3. សិទ្ធិកម្មករត្រូវរងការគំរាមកំហែងក្នុងពេលកើតមានជំងឺរាតត្បាត

ការបញ្ឈប់ពីការងារដោយសារការរីករាលដាលជំងឺ និងការកាត់ប្រាក់ឈ្នួលនៅក្នុងវិស័យកាត់ដេរបាននាំឱ្យមានសម្ពាធចុះក្រោមទៅលើសិទ្ធិកម្មករនិយោជិត ដោយកម្មករនិយោជិតដែលបានស្ទង់មតិបានលើកឡើងថា ការផ្លាស់ប្តូរការជ្រើសរើសបុគ្គលិក និងការអនុវត្តផលិតកម្មចាប់តាំងពីជំងឺរាតត្បាតបានចាប់ផ្តើម បានធ្វើឱ្យពួកគេមានការព្រួយបារម្ភអំពីការរក្សាការងាររបស់ខ្លួននៅក្នុងរយៈពេលវែង។

- 38% នៃអ្នកឆ្លើយសម្ភាសន៍បានអះអាងថា ខ្លួនមានការព្រួយបារម្ភកាន់តែខ្លាំងអំពីសុវត្ថិភាពការងារ

- 35% នៃកម្មករនិយោជិត គិតថាសិទ្ធិរបស់ខ្លួននៅកន្លែងធ្វើការនៅដដែលចាប់តាំងពីជំងឺរាតត្បាតបានចាប់ផ្តើម ប៉ុន្តែ 28% បានអះអាងថា សិទ្ធិរបស់ខ្លួននៅកន្លែងធ្វើការបានធ្លាក់ចុះ
- 41% នៃអ្នកឆ្លើយសម្ភាសន៍គឺ សមាជិកសហជីពដែលបានចុះបញ្ជី
- អំណាចចរចាររបស់កម្មករនិយោជិតទំនងជាមានការធ្លាក់ចុះដោយសារជំងឺរាតត្បាត ដោយលទ្ធផលនៃការស្ទង់មតិបង្ហាញពីការថយចុះនៃគម្លាតប្រាក់បៀវត្សរវាងសមាជិកសហជីព និងមិនមែនសមាជិកសហជីព

កម្មករនិយោជិតដែលបានស្ទង់មតិបានលើកឡើងពីការព្រួយបារម្ភជាច្រើនអំពីសិទ្ធិរបស់ខ្លួននៅកន្លែងធ្វើការនៅក្នុងពេលមានជំងឺរាតត្បាត។ កម្មករមួយចំនួនធំ គឺ 45 ភាគរយ បានលើកឡើងថា នៅពេលនេះប្រាក់បៀវត្សត្រូវបានថៅកែរោងចក្របើកជូនមិនទៀងទាត់។ កម្មករនិយោជិតក៏បានអះអាងផងដែរថា អ្នកគ្រប់គ្រងរោងចក្របានមើលមកកូដកម្មរបស់កម្មករនិយោជិតក្នុងរូបភាពអវិជ្ជមាន ដោយឆ្លើយតបយ៉ាងចាស់ដៃចំពោះតស៊ូដែលមានការរៀបចំប្រឆាំងនឹងការមិនគោរពច្បាប់របស់រោងចក្រ។ លទ្ធផលស្ទង់មតិក៏បានបង្ហាញផងដែរថា ការបញ្ឈប់ពីការងារនៅទូទាំងវិស័យ និងចំនួនពលកម្មលើសលុបដោយសារការធ្លាក់ចុះតម្រូវការពីក្រុមហ៊ុនម៉ាកយីហោអន្តរជាតិ បានជះឥទ្ធិពលដល់សមត្ថភាពរបស់កម្មករនិយោជិតសហជីពក្នុងការចរចាទាមទារប្រាក់ឈ្នួលខ្ពស់ជាងមុន។

*អត្ថបទសំខាន់៖ សហជីពមានសារៈសំខាន់ណាស់ដើម្បីសម្រេចបាននូវសិទ្ធិរបស់កម្មករនិយោជិតនៅទូទាំងវិស័យកាត់ដេរ នៅពេលពួកគេចូលរួមក្នុងការចរចាជាសមូហភាពក្នុងនាមកម្មករនិយោជិត និងសម្របសម្រួលការសន្ទនាជាមួយនិយោជក និងស្ថាប័នពាណិជ្ជកម្មដើម្បីកែលម្អលក្ខខណ្ឌការងារ។ សហជីពនៅប្រទេសបង់ក្លាដែសក៏ផ្តល់ការគាំទ្រជាច្រើនដល់សមាជិករបស់ខ្លួន រួមទាំងជំនួយវេជ្ជសាស្ត្រ ការគាំទ្រសម្រាប់ការបញ្ឈប់ពីការងារក្នុងលក្ខណៈបន្ទាន់ និងការធ្វើកូដកម្មសមូហភាពក្នុងករណីដែលរោងចក្រជំពាក់កម្មករនិយោជិតនូវប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗទៀត។*

មុនពេលកើតមានជំងឺរាតត្បាត កម្មករនិយោជិតសហជីពទទួលបានប្រាក់បៀវត្សជាមធ្យម 119 ដុល្លារអាមេរិកក្នុងមួយខែ (10,010 BDT) ដែលលើសពីសមភាគីមិនមែនសហជីពរបស់ខ្លួនចំនួន 18.5 ដុល្លារអាមេរិក (1,556 BDT)។ ទោះបីយ៉ាងណា គិតត្រឹមខែសីហា ឆ្នាំ2021 លទ្ធផលស្ទង់មតិបានបង្ហាញពីភាពខុសគ្នាតិចតួចនៃប្រាក់បៀវត្សរបស់កម្មករនិយោជិតសហជីព និងមិនមែនសហជីព ដែលបង្ហាញអំពីអំណាចចរចាកាន់តែខ្សោយក្នុងចំណោមកម្មករនិយោជិតសហជីព។



### ការរីករាលដាលអំពើហិង្សាផ្អែកលើយេនឌ័រនៅកន្លែងធ្វើការ

ជំងឺរាតត្បាតបានធ្វើឱ្យស្ថានភាពការងារនៅទូទាំងឧស្សាហកម្មកាត់ដេរកាន់តែមានភាពមិនច្បាស់លាស់ ដែលធ្វើឱ្យកម្មករនិយោជិតកាន់តែងាយជួបប្រទះអំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការ។ ទោះបីកម្មករនិយោជិតមានភាពស្ទាក់ស្ទើរក្នុងការចែករំលែកបទពិសោធន៍អំពីការបៀតបៀនផ្លូវភេទដោយសារភ័យខ្លាចអំពីចំណាត់ការមកលើខ្លួនវិញក៏ដោយ ប៉ុន្តែលទ្ធផលស្ទង់មតិបង្ហាញអំពីអំពើហិង្សាយេនឌ័ររីករាលដាលនៅក្នុងវិស័យកាត់ដេរបង់ក្លាដែសទាំងមូល។

- 30% នៃកម្មករនិយោជិតដែលបានស្ទង់មតិបានលើកឡើងថា ពួកគេបានប្រឈមមុខនឹងអំពើហិង្សាយេនឌ័រ (GBV) ក្នុងទម្រង់មួយចំនួន ខណៈពេលកំពុងធ្វើការ
- 41% បានអះអាងថា ពួកគេបានឃើញដោយផ្ទាល់ភ្នែក ឬស្គាល់មិត្តរួមការងារដែលទទួលរងនូវការបៀតបៀនផ្លូវភេទ
- មានត្រឹមតែ 25% ប៉ុណ្ណោះដែលបង្ហាញថាបានដាក់ពាក្យបណ្តឹងផ្លូវការ បន្ទាប់ពីឧប្បត្តិហេតុនៃការបៀតបៀនផ្លូវភេទ

កម្មករនិយោជិតបានលើកឡើងថា ករណីនៃ GBV មានរាប់ចាប់ពីការជេរប្រមាថរហូតដល់អំពើហិង្សាលើរូបរាងកាយ និងផ្លូវភេទ ហើយបង្ហាញថាឧប្បត្តិហេតុនៃការបៀតបៀនភាគច្រើនមិនត្រូវបានគេរាយការណ៍ឡើយ។ ជាងនេះទៅទៀត ករណីផ្លូវការជាច្រើនមិនបាននាំទៅរកលទ្ធផលវិជ្ជមានសម្រាប់កម្មករដែលរងផលប៉ះពាល់នោះទេ ដោយចំនួនពាក់កណ្តាលនៃករណីដែលបានរាយការណ៍ កម្មករនិយោជិតមិនពេញចិត្តនឹងវិធីដោះស្រាយករណីទាំងនេះឡើយ ប៉ុន្តែបានយល់ព្រមលើការសម្រេចចិត្តរបស់អ្នកគ្រប់គ្រងរោងចក្រដោយសារតែខ្លាចបាត់បង់ការងារ។

### 4. ជំងឺ COVID-19 ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិស្ត្រី និងសមភាពយេនឌ័រ

ក្រៅពីផលប៉ះពាល់មកលើផ្នែកសេដ្ឋកិច្ច ជំងឺរាតត្បាតក៏បានបង្កឱ្យមានបញ្ហាប្រឈមថ្មីៗសម្រាប់សិទ្ធិស្ត្រី និងសមភាពយេនឌ័រនៅទូទាំងប្រទេស។

- 42% នៃកម្មករនិយោជិតដែលបានស្ទង់មតិបានអះអាងពីការកើនឡើងនូវទំនួលខុសត្រូវការងារផ្ទះដែលមិនបានទទួលប្រាក់បៀវត្សរបស់ខ្លួន
- 32% បាននិយាយថា កង្វះប្រាក់ចំណូល និងអសន្តិសុខស្បៀងបាននាំឱ្យទំនាស់ក្នុងគ្រួសារកើនឡើង
- 23% បន្ថែមទៀតបានអះអាងថា ខ្លួនបានជួបប្រទះអំពើហិង្សាក្នុងគ្រួសារអំឡុងពេលបិទខ្ទប់

ដោយសារសមាជិកគ្រួសារត្រូវនៅផ្ទះកាន់តែច្រើនក្នុងអំឡុងពេលបិទខ្ទប់ និងសមត្ថភាពរកប្រាក់ចំណូលរបស់ស្ត្រីមានកម្រិត បន្ទុកការងារផ្ទះកាន់តែច្រើនបានធ្លាក់មកលើស្ត្រី។ កម្មករនិយោជិតជាស្ត្រីក៏បានលើកឡើងអំពីការកើនឡើងនៃជម្លោះនៅក្នុងផ្ទះ និងបទពិសោធន៍នៃអំពើហិង្សាក្នុងគ្រួសារ ដោយស្ថានភាពលំបាកទាំងនេះមានកត្តារួមចំណែកពីវិធានការរឹតបន្តឹងដោយសារជំងឺ COVID-19 ដែលមានន័យថា ស្ត្រីមួយចំនួនដែលធ្លាប់ទទួលរងអំពើហិង្សាក្នុងគ្រួសារបានបង្ខំចិត្តស្ថិតនៅតែក្នុងផ្ទះរបស់ខ្លួន។

### ផលប៉ះពាល់មកលើក្មេងស្រីបង្ហាញអំពីវិបត្តិទូទាំងប្រទេស

លទ្ធផលនៃការស្ទង់មតិបានលើកឡើងអំពីការព្រួយបារម្ភខ្លាំងពាក់ព័ន្ធនឹងផលប៉ះពាល់នៃជំងឺ COVID-19 មកលើសុខុមាលភាពរបស់កុមារ ជាពិសេសហានិភ័យពាក់ព័ន្ធនឹងក្មេងស្រី។

- ជិត 20% នៃអ្នកឆ្លើយសម្ភាសន៍ដែលមានកុមារអាយុក្រោម 18 ឆ្នាំបានអះអាងថា កូនរបស់ខ្លួនមួយចំនួននឹងមិនត្រឡប់ទៅសាលារៀនវិញឡើយនៅពេលសាលាបើកដំណើរការឡើងវិញ។
- ចំនួននេះបានកើនឡើងដល់ 30% សម្រាប់អ្នកឆ្លើយសម្ភាសន៍ដែលមានកូនស្រី។
- 13% នៃអ្នកឆ្លើយសម្ភាសន៍បានលើកឡើងថា កូនរបស់ខ្លួនបានចាប់យកការងារក្រៅប្រព័ន្ធក្នុងអំឡុងពេលជំងឺរាតត្បាត ដើម្បីជួយរកប្រាក់ចំណូលសម្រាប់គ្រួសារ។
- 25% នៃអ្នកឆ្លើយសម្ភាសន៍ដែលអះអាងពីសម្ពាធកើនឡើងក្នុងការរៀបចំអាពាហ៍ពិពាហ៍មុនអាយុសម្រាប់កូនស្រីរបស់ខ្លួន។

ប្រទេសបង់ក្លាដែសបានជួបប្រទះការបិទសាលាដោយសារជំងឺ COVID-19 ក្នុងរយៈពេលយូរបំផុតនៅលើពិភពលោក ដោយសាលារៀននៅបន្តបិទទ្វារចាប់ពីថ្ងៃទី20 ខែមីនា រហូតដល់ថ្ងៃទី16 ខែកញ្ញា ឆ្នាំ2020។ រយៈពេលនៃការបិទសាលាបានប៉ះពាល់ដល់ការសិក្សា និងធ្វើឱ្យអត្រាបោះបង់ការសិក្សាកើនឡើង។ កម្មករនិយោជិតបានលើកឡើងពីអសមត្ថភាពក្នុងការផ្គត់ផ្គង់ការសិក្សារបស់កូនថាជាមូលហេតុចម្បងបណ្តាលឱ្យបញ្ហានេះកើតឡើង ចំណែកអ្នកដទៃផ្សេងទៀតបានបញ្ជាក់ថា កូនៗរបស់ខ្លួននៅពេលនេះកំពុងធ្វើការងារដើម្បីរកប្រាក់ផ្គត់ផ្គង់គ្រួសារ។

ការកើនឡើងហានិភ័យអាពាហ៍ពិពាហ៍កុមារបង្កឱ្យមានការព្រួយបារម្ភអំពីសិទ្ធិកុមារយ៉ាងធ្ងន់ធ្ងរ ដោយមានអ្នកឆ្លើយសម្ភាសន៍មួយចំនួនតូចបានឱ្យដឹងថា ដោយសារតែស្ថានភាពសេដ្ឋកិច្ចធ្លាក់ចុះដុនដាន និងសម្ពាធពីសមាជិកគ្រួសារជាបន្តបន្ទាប់ កូនស្រីរបស់ខ្លួនបានរៀបការក្នុងអំឡុងពេលជំងឺរាតត្បាត។ បញ្ហានេះបញ្ជាក់កាន់តែច្បាស់អំពីភាពចាំបាច់ក្នុងការផ្តល់ការគាំទ្របន្ថែមជាបន្ទាន់ដល់កម្មករនិយោជិតកាត់ដេរ ដើម្បីកុំឱ្យការខាតបង់ផ្នែកសេដ្ឋកិច្ចដោយសារជំងឺរាតត្បាត បង្កផលប៉ះពាល់ទៅលើកុមារ។

**អត្រានៃការចាក់វ៉ាក់សាំងខ្ពស់ផ្តល់ការការពារពីជំងឺ COVID-19 ប៉ុន្តែនៅតែមានហានិភ័យ**

ទិដ្ឋភាពវិជ្ជមាននៃការឆ្លើយតបចំពោះជំងឺ COVID-19 របស់រដ្ឋាភិបាលបង់ក្លាដែស គឺការចាប់ផ្តើមចាក់វ៉ាក់សាំងភ្លាមៗសម្រាប់កម្មករនិយោជិតកាត់ដេរ ដែលបានកាត់បន្ថយបានយ៉ាងច្រើននូវហានិភ័យនៃការរីករាលដាលនៃជំងឺ COVID-19 តាមរយៈរោងចក្រកាត់ដេរ ដែលលក្ខខណ្ឌការងារ និងការពាក់ព័ន្ធជិតស្និទ្ធរវាងគ្នា កាន់តែធ្វើឱ្យកម្មករនិយោជិតងាយរងគ្រោះក្នុងការឆ្លង និងរីករាលដាលនៃមេរោគនេះ។

- កម្មករនិយោជិតដែលបានស្ទង់មតិទាំងអស់បានអះអាងថា ខ្លួនបានចាក់វ៉ាក់សាំងពេញលេញដើម្បីការពារជំងឺ COVID-19
- 68% នៃអ្នកឆ្លើយសម្ភាសន៍បាននិយាយថា និយោជករបស់ខ្លួនបានចាត់វិធានការមួយចំនួនដើម្បីការពារការរីករាលដាលជំងឺ COVID-19 នៅក្នុងរោងចក្រ
- ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មានតែ 45% ប៉ុណ្ណោះដែលបង្ហាញថា ម៉ាស និងទឹកអាល់កុលលាងដៃត្រូវបានផ្តល់ជូនកម្មករនិយោជិតនៅពេលចូលរោងចក្រ និងក្នុងចន្លោះពេលទៀងទាត់
- 43% បានឱ្យដឹងថា និយោជករបស់ខ្លួនបានចាត់វិធានការដើម្បីធានាការរក្សាគម្លាតសុវត្ថិភាពនៅក្នុងរោងចក្រដែលខ្លួនធ្វើការ

ការផ្តល់ម៉ាស និងទឹកអាល់កុលលាងដៃមិនត្រឹមតែមានអត្រាទាបប៉ុណ្ណោះទេ ប៉ុន្តែកម្មករនិយោជិតមួយភាគបួនបាននិយាយថា ម៉ាសត្រូវបានផ្តល់ជូនតែមួយដងប៉ុណ្ណោះ ដោយក្រោយៗមកទៀត កម្មករនិយោជិតត្រូវបានរំពឹងថា នឹងទិញម៉ាសពាក់ដោយខ្លួនឯង។ ជាងនេះទៅទៀត លទ្ធផលស្ទង់មតិបានបង្ហាញថា ថៅកែរោងចក្រមិនបានចាត់វិធានការផ្តល់មធ្យោបាយធ្វើដំណើរផ្សេងទៀត ដើម្បីធានាសុវត្ថិភាពរបស់កម្មករនិយោជិតនៅពេលធ្វើដំណើរទៅមកពីធ្វើការឡើយ។

# ប្រទេសកម្ពុជា

## ទិដ្ឋភាពទូទៅនៃឧស្សាហកម្មកាត់ដេរកម្ពុជា

វិស័យកាត់ដេររបស់ប្រទេសកម្ពុជាគឺជាវិស័យមួយនៅក្នុងចំណោមវិស័យនាំចេញដ៏ធំបំផុតរបស់ប្រទេស ហើយបានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួន។ វិស័យនេះមានកម្មករនិយោជិតជាង 800,000 នាក់នៅទូទាំង 1,100 រោងចក្រ ហើយបាននឹងកំពុងពង្រីកខ្លួនយ៉ាងឆាប់រហ័សនៅមុនកើតមានជំងឺរាតត្បាត COVID-19។ ការនាំចេញសម្លៀកបំពាក់បានកើនឡើង 11 ភាគរយនៅចន្លោះឆ្នាំ 2018 ដល់ 2019។ ទោះបីយ៉ាងណា វិស័យនេះបានរងផលប៉ះពាល់ដោយសារការធ្លាក់ចុះសេដ្ឋកិច្ចនៅក្នុងវិបត្តិជំងឺរាតត្បាត ដោយការនាំចេញបានធ្លាក់ចុះ 10.2 ភាគរយ នៅក្នុងឆ្នាំ2020 ពីជាង 8 ពាន់លានដុល្លារក្នុង ឆ្នាំ2019ទៅ7 ពាន់លានដុល្លារ។[21] ការនាំចេញបានបន្តធ្លាក់ចុះនៅដើមឆ្នាំ 2021 ប៉ុន្តែ ការបើកហាងលក់សម្លៀកបំពាក់ឡើងវិញនៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងអឺរ៉ុប នៅពេលស្ថានភាពជំងឺ COVID-19 មានភាពធូរស្រាល បានធ្វើឱ្យវិស័យនេះមានការងើបឡើងវិញកាលពីពេលថ្មីៗកន្លងទៅនេះ ដោយសារការបញ្ជាទិញ និងការនាំចេញបានកើនឡើង។[22]

កម្មករនិយោជិតកាត់ដេរនៅកម្ពុជាភាគច្រើនទទួលបានប្រាក់ចំណូលទាបជាងប្រាក់ឈ្នួលទ្រទ្រង់ជីវភាព។ ប្រាក់ឈ្នួលអប្បបរមាត្រូវបានដំឡើងដល់ 192 ដុល្លារអាមេរិកក្នុងមួយខែក្នុងឆ្នាំ2021 ដែលទាបជាងការទាមទារដំឡើងរបស់សហជីពចំនួន 12 ដុល្លារអាមេរិកក្នុងមួយខែ ស្របទៅតាមកំណើនផលិតភាព និងការកើនឡើងនូវបញ្ជាទិញពីក្រុមហ៊ុនម៉ាកយីហោអន្តរជាតិ។ ការដំឡើងប្រាក់ឈ្នួលមិនស្របតាមកម្រិតអត្រាអតិផរណាដែលមានចំនួន 2.9 ភាគរយក្នុងឆ្នាំ2020។[23] នៅឆ្នាំ2020 AFWA បានគណនាប្រាក់ឈ្នួលទ្រទ្រង់ជីវភាពរបស់កម្ពុជា 588 ដុល្លារអាមេរិក ដែលច្រើនជាងប្រាក់ឈ្នួលអប្បបរមាចំនួនបីដង។[24]

## ផលប៉ះពាល់នៃជំងឺ COVID-19

ផលប៉ះពាល់ផ្នែកសេដ្ឋកិច្ចនៃជំងឺរាតត្បាត COVID-19 មកលើឧស្សាហកម្មកាត់ដេរកម្ពុជាក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ បានកើតឡើងផ្ទួនៗគ្នា។ ដោយសារ 60 ភាគរយនៃវត្ថុធាតុដើមដែលប្រើប្រាស់ក្នុងផលិតកម្មកាត់ដេរនៅកម្ពុជាមានប្រភពមកពីប្រទេសចិន ការលេចឡើងជំងឺ COVID-19 នៅទីក្រុងវូហាន និងបញ្ហាខ្សែសង្វាក់ផ្គត់ផ្គង់ជាបន្តបន្ទាប់បានរំខានយ៉ាងខ្លាំងដល់ឧស្សាហកម្មកាត់ដេរកម្ពុជា។[25] រោងចក្របានជួបការលំបាកក្នុងការបញ្ជាទិញពីក្រុមហ៊ុនម៉ាកយីហោអន្តរជាតិ។ បន្ទាប់មកនៅពេលដែលជំងឺរាតត្បាតបានវាយ

---

[21] Open Development Cambodia (2021) *ការនាំចេញ* ថ្ងៃទី12 ខែសីហា https://opendevelopmentcambodia.net/topics/exports/

[22] Xinhua (2021) *ការនាំចេញសម្លៀកបំពាក់របស់កម្ពុជាកើនឡើង 3.3 ភាគរយក្នុងរយៈពេល 8 ខែដំបូង៖ ក្រសួងពាណិជ្ជកម្ម* ថ្ងៃទី18 ខែកញ្ញា http://www.news.cn/english/2021-09/18/c_1310196169.htm

[23] ធនាគារអភិវឌ្ឍន៍អាស៊ី (2021) *សូចនាករសេដ្ឋកិច្ចសម្រាប់កម្ពុជា*https://www.adb.org/countries/cambodia/economy

[24] ការគណនារបស់ ActionAid ដោយផ្អែកលើទិន្នន័យប្រាក់ឈ្នួលអប្បបរមាពីទិន្នន័យប្រាក់ឈ្នួលទ្រទ្រង់ជីវភាពឆ្នាំ 2021 និង 2020 ពីសម្ព័ន្ធអង្គការសិទ្ធិការងារ Asia Floor Wage Alliance។ ប្រាក់ឈ្នួលទ្រទ្រង់ជីវភាសម្រាប់តំបន់អាស៊ីឆ្នាំ2020 ត្រូវបានគណនាមានចំនួន 1,420 PPP ហើយអត្រាប្តូរប្រាក់ PPP សម្រាប់ប្រទេសកម្ពុជាគឺ 1655.54, https://asia.floorwage.org/our-work/#tab-id-3

[25] ខ្មែរថាមស៍ (ឆ្នាំ 2020) *រោងចក្រកាត់ដេរនឹងជួបប្រទះការអាក់ខានការផ្គត់ផ្គង់វត្ថុធាតុដើមពីប្រទេសចិន៖ GMAC* ថ្ងៃទី12 ខែកុម្ភៈ https://www.khmertimeskh.com/689917/garment-factories-to-experience-chinese-raw-material-disruptions-gmac/

ប្រហារទៅលើសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងអឺរ៉ុបកាលពីខែមីនា ឆ្នាំ2020 ឧស្សាហកម្មកម្ពុជាត្រូវរងឥទ្ធិពលសាជាថ្មីម្តងទៀត ដោយសារក្រុមហ៊ុនម៉ាកយីហោនានាបានលុបចោលបញ្ជាទិញ ពន្យារពេលការទូទាត់ មិនព្រមទូទាត់ប្រាក់សម្រាប់ការបញ្ជាទិញ និងមិនបានដាក់បញ្ជាទិញថ្មី។ នៅចន្លោះខែមករាដល់ខែមិថុនា ឆ្នាំ2020 ទិន្នន័យនាំចេញបង្ហាញអំពីការធ្លាក់ចុះនូវការនាំចេញសម្លៀកបំពាក់ពីកម្ពុជា 5.4 ភាគរយ ដោយសារការនាំចូលទៅសហរដ្ឋអាមេរិកបានធ្លាក់ចុះ 26 ភាគរយ និងនៅអឺរ៉ុប 25 ភាគរយ។[26] កត្តានេះជាប់ពាក់ព័ន្ធនឹងរោងចក្រកាត់ដេរ រោងចក្រស្បែកជើង និងវិស័យធ្វើដំណើរ ជាង 130 ដែលបានបង្ខំចិត្តផ្អាកប្រតិបត្តិការរបស់ខ្លួន ហើយកម្មករនិយោជិតប្រហែល 100,000 នាក់ បានបាត់បង់ការងាររបស់ខ្លួនទាំងជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍។[27] កាលពីខែធ្នូ ឆ្នាំ2020 រដ្ឋាភិបាលបានឱ្យដឹងថា រោងចក្រចំនួន 110 បានបិទទ្វារនៅក្នុងឆ្នាំ2020 ដែលបណ្តាលឱ្យកម្មករនិយោជិតជាង 55,000 នាក់គ្មានការងារធ្វើ និងគ្មានប្រាក់ចំណូលសម្រាប់ផ្គត់ផ្គង់គ្រួសាររបស់ខ្លួន។

ក្នុងខែមេសា ឆ្នាំ2020 រដ្ឋាភិបាលកម្ពុជាបានផ្តល់ជំនួយហិរញ្ញវត្ថុដល់កម្មករនិយោជិតកាត់ដេរដែលត្រូវបានព្យួរការងារដោយសារជំងឺរាតត្បាតនេះ។ ទោះបីយ៉ាងណា ការជួយឧបត្ថម្ភនេះមានចំនួនតិចជាងប្រាក់ឈ្នួលធម្មតារបស់កម្មករនិយោជិតកាត់ដេរ និងប្រាក់ឈ្នួលអប្បបរមាស្របច្បាប់របស់ប្រទេសឆ្ងាយណាស់ ដែលជំរុញឱ្យកម្មករនិយោជិតកាត់ដេរ កាន់តែធ្លាក់ចូលទៅក្នុងភាពក្រីក្រថែមទៀត។ បន្ទាប់ពីបានស្នើសុំប្រាក់ប្រចាំខែចំនួន 114 ដុល្លារអាមេរិក នៅទីបំផុត រដ្ឋាភិបាលកម្ពុជាបានយល់ព្រមផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិតកាត់ដេរចំនួន 70 ដុល្លារអាមរិកក្នុងមួយខែ ដោយរដ្ឋាភិបាលផ្តល់ 40 ដុល្លារអាមេរិក និង 30 ដុល្លារអាមេរិកត្រូវទូទាត់ដោយខាងរោងចក្រ។[28] លើសពីនេះទៅទៀត រោងចក្រមានសិទ្ធិទទួលបានជំនួយឧបត្ថម្ភពីរដ្ឋាភិបាលលុះត្រាតែពួកគេមិនបានទទួលបញ្ជាទិញពីក្រុមហ៊ុនម៉ាកយីហោអន្តរជាតិ និងបានជូនដំណឹងជាផ្លូវការដល់រដ្ឋាភិបាលអំពីតម្រូវការរបស់ខ្លួនក្នុងការចូលរួមនៅក្នុងរបបឧបត្ថម្ភនេះ។ ជាទូទៅ រោងចក្រដែលបានមៅការបន្តបញ្ជាទិញពុំមានសិទ្ធិទទួលបានជំនួយពីរដ្ឋាភិបាលឡើយ ហើយកម្មករនិយោជិតត្រូវបានផ្អាកពីការងារដោយពុំទទួលបានជំនួយឧបត្ថម្ភហិរញ្ញវត្ថុឡើយ។

ទោះបីមានភាពល្អប្រសើរជាងមុនមួយចំនួននៅចុងឆ្នាំ2020 យ៉ាងណាក្តី ស្ថានភាពសម្រាប់កម្មករនិយោជិតកាត់ដេរនៅតែមានភាពច្របូកច្របល់ ដោយសាររោងចក្រផលិតពឹងផ្អែកទៅលើតម្រូវការអន្តរជាតិដែលមានការប្រែប្រួលឡើងចុះដោយសារតែការបិទខ្ទប់ និងការរឹតបន្តឹង។ ការកើនឡើងនូវករណីជំងឺ COVID-19 នៅកម្ពុជា នៅដើមឆ្នាំ2021 បាននាំមកនូវបញ្ហាប្រឈមថ្មីៗសម្រាប់ឧស្សាហកម្មកាត់ដេរ និងហានិភ័យចំពោះសុខភាព និងសេដ្ឋកិច្ចសម្រាប់កម្មករនិយោជិតរាប់ពាន់នាក់ដែលផលិតសម្លៀកបំពាក់សម្រាប់ក្រុមហ៊ុនម៉ាកយីហោអន្តរជាតិ។ ការកើនឡើងចំនួនករណីឆ្លងបានបណ្តាលឱ្យមានការបិទខ្ទប់ទូទាំងប្រទេសកាលពីខែមេសា ដែលបានអូសបន្លាយពេលសម្រាប់តំបន់ដែលមានហានិភ័យខ្ពស់នៅក្នុងខែឧសភា ដែលធ្វើឱ្យកម្មករនិយោជិតកាត់ដេរគ្មានការងារធ្វើ និងជួបការលំបាកក្នុងការបន្តជីវិតរស់នៅរបស់ខ្លួន។

---

[26] ILO (2020) *ឥទ្ធិពលនៃខ្សែសង្វាក់ផ្គត់ផ្គង់៖ ផលប៉ះពាល់នៃជំងឺ COVID-19 មកលើកម្មករនិយោជិតកាត់ដេរ និងរោងចក្រនៅអាស៊ី និងប៉ាស៊ីហ្វិក* ខែតុលា ទំព័រ 9 https://www.ilo.org/wcmsp5/groups/public/---asia/---ro-bangkok/documents/briefingnote/wcms_758626.pdf

[27] កាសែតភ្នំពេញប៉ុស្ដិ៍ (ឆ្នាំ 2020) *រោងចក្រកាត់ដេរចំនួនជាង 110 កន្លែងបានបិទទ្វារ* ថ្ងៃទី22 ខែវិច្ឆិកា https://www.phnompenhpost.com/national/over-110-garment-factories-close

[28] កាសែតភ្នំពេញប៉ុស្ដិ៍ (ឆ្នាំ 2020) *កម្មករនិយោជិតដែលត្រូវផ្អាកការងារបណ្តោះអាសន្ននឹងទទួលបានប្រាក់ $70 ថ្ងៃទី07 ខែមេសា* https://www.phnompenhpost.com/national/temporarily-laid-workers-get-just-70

រដ្ឋាភិបាលមិនបានផ្តល់ការគាំទ្រណាមួយដល់កម្មករនិយោជិតកាត់ដេរក្នុងអំឡុងពេលបិទខ្ទប់ឡើយ។ រដ្ឋាភិបាលក៏បានជូនដំណឹងដល់រោងចក្រថា ខ្លួនមិនទទួលខុសត្រូវចំពោះការគាំទ្រកម្មករនិយោជិតឡើយ ប៉ុន្តែអាចផ្តល់ជំនួយឧបត្ថម្ភបានទៅតាមការសម្រេចចិត្តរបស់ខ្លួន។ ដូច្នេះហើយ ការគាំទ្រដល់កម្មករនិយោជិតកាត់ដេរក្នុងអំឡុងពេលបិទខ្ទប់មានលក្ខណៈខុសគ្នាខ្លាំង ដោយរោងចក្រមួយចំនួនសម្រេចបើកប្រាក់បៀវត្សរ៍ពេញលេញដល់កម្មករនិយោជិត ខ្លះផ្តល់ 20 ភាគរយ នៃប្រាក់បៀវត្សរ៍ មួយចំនួនជួយឧបត្ថម្ភប្រាក់សម្រាប់បង់ថ្លៃឈ្នួលផ្ទះ ចំណែកកម្មករនិយោជិតខ្លះទៀតមិនបានទទួលជំនួយឧបត្ថម្ភអ្វីទាំងអស់។

រោងចក្រកាត់ដេរជាច្រើនបានបើកដំណើរការឡើងវិញនៅក្នុងខែឧសភា ដែលមានន័យថាកម្មករនិយោជិតដែលមិនរស់នៅក្នុងតំបន់ក្រហមដែលមានហានិភ័យខ្ពស់ អាចត្រឡប់ទៅធ្វើការវិញបាន។ ទោះបីយ៉ាងណារោងចក្រ និងកម្មករនិយោជិតដែលមានទីតាំងនៅក្នុង "តំបន់ក្រហម" ដែលមានការរឹតបន្តឹងខ្លាំងជាងនៅតែស្ថិតនៅក្នុងការបិទខ្ទប់នៅឡើយ។ ទោះបីស្ថានភាពនេះបានធ្វើឱ្យកម្មករមួយចំនួនទទួលបានប្រាក់ចំណូលដែលកំពុងត្រូវការយ៉ាងខ្លាំងក៏ដោយ ហានិភ័យនៃការត្រឡប់ទៅធ្វើការវិញមានកម្រិតខ្ពស់។ មេរោគនេះបានបន្តរីករាលដាលពាសពេញប្រទេសកម្ពុជា ជាពិសេសនៅតាមរោងចក្រកាត់ដេរ ដែលកម្មករមិនអាចរក្សាគម្លាតសុវត្ថិភាពនៅក្នុងរោងចក្រ។ កម្មករនិយោជិតជួបបញ្ហាប្រឈម ជាពិសេសនៅអំឡុងពេលសម្រាកអាហារថ្ងៃត្រង់ ដែលកម្មករនិយោជិតរាប់រយនាក់ ឬរហូតដល់រាប់ពាន់នាក់ ត្រូវប្រជ្រៀតគ្នានៅតាមកន្លែងតូចៗ និងពុំមានការរៀបចំ ដើម្បីទិញអាហារ។ កម្មករនិយោជិតក៏ត្រូវបង្ខំចិត្តធ្វើដំណើរតាមមធ្យោបាយដឹកជញ្ជូនដែលប្រជ្រៀតគ្នាទាំងទៅ និងមកពីកន្លែងធ្វើការផងដែរ។

### ទិដ្ឋភាពទូទៅនៃវិធីសាស្រ្ត

អង្គការ ActionAid បានសហការជាមួយសម្ព័ន្ធសហជីពកម្ពុជា ដើម្បីធ្វើការស្ទង់មតិជាមួយកម្មករនិយោជិតកាត់ដេរចំនួន 118 នាក់នៅទូទាំងរោងចក្រចំនួន 6 នៅរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ ប្រហែល 86 ភាគរយនៃអ្នកដែលត្រូវស្ទង់មតិគឺជាស្ត្រី 12 ភាគរយជាបុរស និង 2% ជាអ្នកប្តូរភេទ។

កម្រិតនៃការស្ទង់មតិមានគំរូសិក្សាតូច ក៏ដូចជាតំណាងខ្ពស់នៃសមាជិកសហជីព (86.4 ភាគរយ) និងអ្នកដែលបច្ចុប្បន្នកំពុងមានការងារធ្វើ (95 ភាគរយ) ។ ការកំណត់នេះគឺដោយសារការអនុវត្តការស្ទង់មតិដោយតំណាងសហជីព និងផ្តោតទៅលើរោងចក្រដែលកំពុងដំណើរការ (បច្ចុប្បន្ន រោងចក្រចំនួនប្រាំក្នុងចំណោមប្រាំមួយ កំពុងមានដំណើរការ)។

## លទ្ធផលនៃការស្រាវជ្រាវនៅប្រទេសកម្ពុជា

**មនុស្សចំនួន 118 នាក់ត្រូវបានស្ទង់មតិ**

**រោងចក្រចំនួន 6**

**អ្នកឆ្លើយសម្ភាសន៍ 91% ជាកម្មករចំណាកស្រុក**

**90.7% នៃអ្នកឆ្លើយសម្ភាសន៍ព្រួយបារម្ភអំពីសុវត្ថិភាពការងាររបស់ខ្លួន ចាប់តាំងពីជំងឺរាតត្បាតបានវាយប្រហារ**

**អ្នកឆ្លើយសម្ភាសន៍ 13% បានបាត់បង់ការងារដោយសារជំងឺ COVID-19**

**89% នៃអ្នកឆ្លើយសម្ភាសន៍បានអស់ប្រាក់សម្រាប់ទិញអាហារនៅអំឡុងពេលជំងឺរាតត្បាត**

### 1. ប្រាក់ឈ្នួលក្រីក្រធ្វើឱ្យកម្មករនិយោជិតងាយរងគ្រោះដោយសារផលប៉ះពាល់សេដ្ឋកិច្ចបណ្តាលមកពីជំងឺ COVID-19

កម្មករនិយោជិតកាត់ដេរនៅប្រទេសកម្ពុជាបានចូលទៅក្នុងវិបត្តិនេះ ដែលទទួលបានប្រាក់ឈ្នួលក្រីក្ររួចទៅហើយ ដែលធ្វើឱ្យពួកគេងាយរងគ្រោះដោយសារផលប៉ះពាល់សេដ្ឋកិច្ចបណ្តាលមកពីជំងឺរាតត្បាត។ ប្រាក់ឈ្នួលទាបឆ្លុះបញ្ចាំងអំពីភាពមិនគ្រប់គ្រាន់នៃប្រាក់ឈ្នួលអប្បបរមានៃវិស័យនេះ ដែលទាបជាងខ្លាំងពីប្រាក់ឈ្នួលទ្រទ្រង់ជីវភាព ដោយកម្មករនិយោជិតកាត់ដេរពឹងផ្អែកទៅលើប្រាក់ធ្វើការថែមម៉ោងដើម្បីបង្គ្រប់ប្រាក់ឈ្នួលធម្មតា។

- កាលពីខែមករា ឆ្នាំ2020 មានកម្មករនិយោជិតដែលបានចូលរួមក្នុងការស្ទង់មតិនេះចំនួនតែ 2.2% ប៉ុណ្ណោះ ដែលទទួលបានប្រាក់ឈ្នួលទ្រទ្រង់ជីវិត។
- ច្រើនជាងពីរដងនៃចំនួននោះ គឺ 5.6 ភាគរយ រកប្រាក់មិនបានលើសពីប្រាក់ឈ្នួលអប្បបរមាឡើយ។

កម្មករនិយោជិតភាគច្រើនទទួលបានប្រាក់ឈ្នួលលើសពីប្រាក់ឈ្នួលអប្បបរមាបន្តិចបន្តួច នៅពេលគិតអំពីប្រាក់បៀវត្ស និងប្រាក់ថែមម៉ោង។ ជាង 3 ភាគ 4 (78 ភាគរយ) នៃកម្មករដែលបានស្ទង់មតិ ទទួលបានប្រាក់ចំណូលចន្លោះពី 200 ទៅ 300 ដុល្លារអាមេរិក ដោយ 12 ភាគរយអាចរកបានចាប់ពី 300 ទៅ 400 ដុល្លារអាមេរិក។ មានតែ 3.3 ភាគរយនៃកម្មករដែលបានស្ទង់មតិ (មនុស្ស បីនាក់) ប៉ុណ្ណោះ ដែលរកបានលើសពី 400 ដុល្លារក្នុងមួយខែ ដែលនៅតែតិចជាងកម្រិតប្រាក់ឈ្នួលទ្រទ្រង់ជីវភាពចំនួន 588 ដុល្លារ នៅឡើយ។

ការដំឡើង 2 ដុល្លារលើប្រាក់ឈ្នួលអប្បបរមានៅឆ្នាំ2021 មិនបានធ្វើឱ្យស្ថានភាពកម្មករនិយោជិតកាត់ដេរមានភាពប្រសើរឡើងឡើយ។ ដោយរៀបរាប់អំពីបញ្ហាផ្ទាល់ខ្លួន កម្មករនិយោជិតបានលើកឡើងថា ទោះបីប្រាក់ឈ្នួលត្រូវបានដំឡើងរួចហើយក្តី ក៏ពួកគេនៅតែជួបការលំបាកក្នុងការផ្គត់ផ្គង់ជីវភាពដោយសារការឡើងថ្លៃឈ្នួលកន្លែងស្នាក់នៅ អាហារ ប្រេងសាំង និងទំនិញផ្សេងៗ។ ដោយសាររដ្ឋាភិបាលមិនបានបំពេញតាមការអំពាវនាវរបស់កម្មករនិយោជិត និងសហជីពដែលទាមទារឱ្យមានការដំឡើងចំនួន 12 ដុល្លារ ទៅលើប្រាក់ឈ្នួលអប្បបរមាដល់ ធ្វើឱ្យកម្មកររោងចក្រកាត់ដេរគិតថា ការទូទាត់ប្រាក់ឈ្នួលទ្រទ្រង់ជីវភាពគឺពុំអាចទៅរួចឡើយ។




ប្រាក់បៀវត្សទាបនៅក្នុងឧស្សាហកម្មកាត់ដេរកម្ពុជាទាំងមូល គឺមានន័យថា កម្មករនិយោជិតមិនត្រឹមតែជួបការលំបាកក្នុងការចំណាយជីវភាពប្រចាំថ្ងៃរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែពួកគេពុំមានលទ្ធភាពសន្សំប្រាក់ទុក

ឡើយ ក្នុងករណីបាត់បង់ការងារ ឬកាត់បន្ថយម៉ោងធ្វើការ។ កត្តានេះបានធ្វើឱ្យកម្មករនិយោជិតកាត់ដេរងាយរងគ្រោះដោយសារជំងឺរាតត្បាត។

**2. ការបិទខ្ទប់ និងការបញ្ឈប់ការងារដោយសារជំងឺ COVID-19 ជំរុញឱ្យកម្មករកាន់តែធ្លាក់ក្នុងភាពអត់ឃ្លាន និងភាពក្រីក្រ**

រោងចក្រចំនួនប្រាំក្នុងចំណោមប្រាំមួយដែលត្រូវបានសិក្សានៅក្នុងការស្រាវជ្រាវនេះនៅតែបើកដំណើរការនៅក្នុងរយៈពេលជំងឺរាតត្បាតទាំងមូល លើកលែងតែក្នុងពេលបិទខ្ទប់។ ទោះបីយ៉ាងណា នៅរោងចក្រផ្សេងទៀតគឺ Violet Apparel កម្មករត្រូវបានផ្អាកការងារនៅក្នុងខែឧសភា ឆ្នាំ2020 មុនពេលរោងចក្រត្រូវបានបិទភ្លាមៗជារៀងរហូតនៅក្នុងខែកក្កដា ឆ្នាំ2020។[29] លទ្ធផលស្ទង់មតិបង្ហាញថា ទោះបីកម្មករទាំងអស់បានរងផលប៉ះពាល់អវិជ្ជមានដោយសារជំងឺរាតត្បាត ដោយប្រឈមនឹងការធ្លាក់ចុះប្រាក់ចំណូល និងការកើនឡើងនូវគ្រោះអត់ឃ្លាន កម្មករមកពីរោងចក្រ Violet Apparel ជួបប្រទះស្ថានភាពដែលអាក្រក់ជាងនេះ។

- 13% នៃកម្មករនិយោជិតកាត់ដេរដែលបានស្ទង់មតិ បានបាត់បង់ការងារដោយសារតែជំងឺរាតត្បាត
- ក្នុងចំណោមនេះ មាន 93% ធ្លាប់ធ្វើការនៅរោងចក្រ Violet Apparel
- មានកម្មករដែលបាត់បង់ការងារចំនួនតែ 27% ប៉ុណ្ណោះដែលទទួលបានប្រាក់បំណាច់ការងារ
- កម្មករនិយោជិតចំនួន 41.5% បន្ថែមទៀត បានបាត់បង់ប្រាក់ចំណូលរបស់ខ្លួនដោយសារតែការបិទរោងចក្រក្នុងអំឡុងពេលបិទខ្ទប់
- 40% នៃកម្មករនិយោជិតដែលបានស្ទង់មតិបាននិយាយថា ម៉ោងធ្វើការរបស់ខ្លួនត្រូវបានកាត់បន្ថយចាប់តាំងពីពេលកើតមានជំងឺរាតត្បាត

កម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារភាគច្រើន (93 ភាគរយ) បានអះអាងថា ខ្លួនបានឈប់ធ្វើការលើសពី 12 ខែ។ សម្រាប់កម្មករនិយោជិតដែលបាត់បង់ប្រាក់ចំណូលដោយសារការបិទរោងចក្រក្នុងអំឡុងពេលបិទខ្ទប់ភាគច្រើន (98 ភាគរយ) បានឱ្យដឹងថា ខ្លួនអត់ការងារធ្វើរយៈពេលពីមួយខែទៅពីរខែ។

ការបិទរោងចក្រ Violet Apparel នាំឱ្យវិវាទលើបញ្ហាប្រាក់បំណាច់ ចាប់តាំងពីខ្លួនបានបិទដំណើរការកាលពីខែកក្កដា ឆ្នាំ2020 ហើយលទ្ធផលស្ទង់មតិបង្ហាញឱ្យឃើញអំពីការអះអាងជាបន្តបន្ទាប់នៃអត្ថប្រយោជន៍ដែលមិនបានទូទាត់។ កម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារភាគច្រើន (93 ភាគរយ) បានអះអាងថាខ្លួនបានទទួលប្រាក់បៀវត្សចុងក្រោយរួចហើយ។ ទោះបីយ៉ាងណា ជាងនេះទៅទៀតទៅទៀត ការទទួលបានអត្ថប្រយោជន៍នៅមានកម្រិតតិចតួចនៅឡើយ។ កម្មករនិយោជិតតិចជាងពាក់កណ្តាល (40 ភាគរយ) បានលើកឡើងថា ខ្លួនទទួលបានអត្ថប្រយោជន៍ប្រចាំឆ្នាំ ហើយតិចជាងមួយភាគបីបានទទួលប្រាក់បំណាច់ (27 ភាគរយ) និងសំណងជូនដំណឹងជាមុន (20 ភាគរយ)។ ករណីនេះបានកើតឡើងទោះបីជាអត្ថប្រយោជន៍ទាំងនេះត្រូវបានកំណត់នៅក្នុងច្បាប់នៃប្រទេសកម្ពុជាក៏ដោយ។[30]

**ជំនួយហិរញ្ញវត្ថុ COVID-19 មិនគ្រប់គ្រាន់ ដោយសារក្រុមហ៊ុនម៉ាកយីហោអន្តរជាតិបោះបង់ចោលកម្មករនិយោជិតកាត់ដេរ**

ដោយសារក្រុមហ៊ុនម៉ាកយីហោអន្តរជាតិបានបោះបង់កម្មករនិយោជិតកាត់ដេរចំនួន 700,000 នាក់នៅក្នុងវិស័យកាត់ដេរកម្ពុជា ការឆ្លើយតបចំពោះជំងឺរាតត្បាតបានធ្លាក់ទៅលើរដ្ឋាភិបាលកម្ពុជា ដែលទីបំផុតបាន

---

[29] Nierhoff, A (2020) *កម្មកររោងចក្រកាត់ដេរកម្ពុជាទាមទារសិទ្ធិបន្ទាប់ពីត្រូវបិទទ្វារដោយសារជំងឺកូវីណា* ថ្ងៃទី16 ខែតុលា https://www.abc.net.au/news/2020-10-16/cambodia-violet-factory-workers-demand-pay -after-coronavirus/12769364

[30] ILO (2019) *ការណែនាំអំពីច្បាប់ការងារកម្ពុជាសម្រាប់ឧស្សាហកម្មកាត់ដេរ* https://betterwork.org/wp-content/uploads/2020/03/Cambodian-Labour-Law-Guide2019.pdf

យល់ព្រមផ្តល់ (70 ដុល្លារអាមេរិកក្នុងមួយខែដល់កម្មករដែលរងផលប៉ះពាល់ រួមជាមួយការទូទាត់ដែលបាន បែងចែករវាងរដ្ឋាភិបាល (40 ដុល្លារអាមេរិក) និងរោងចក្រកាត់ដេរ (30 ដុល្លារអាមេរិក)។ ទោះបីការជួយឧបត្ថម្ភនេះមិនគ្រប់គ្រាន់ដែលមានត្រឹមតែ 40 ភាគរយនៃប្រាក់ឈ្នួលអប្បបរមាដែលមានកម្រិតទាបរួចស្រេចទៅហើយក្តី ការរកឃើញជាវិជ្ជមានពីការស្ទង់មតិនេះគឺថា ការដាក់ឱ្យអនុវត្តនូវកញ្ចប់ជំនួយហិរញ្ញវត្ថុរបស់រដ្ឋាភិបាលមានភាពរឹងមាំសម្រាប់រោងចក្រដែលផ្តោតលើការនាំចេញជាផ្លូវការ។ ទោះបីយ៉ាងណា គួរកត់សម្គាល់ថា ជំនួយនេះមិនបានអនុវត្តទៅលើកម្មករនិយោជិតដែលធ្វើការនៅរោងចក្រកិច្ចសន្យាបន្តឡើយ។

- 93% នៃអ្នកឆ្លើយសម្ភាសន៍អាចទទួលបានជំនួយឧបត្ថម្ភពីរដ្ឋាភិបាលក្នុងអំឡុងពេលជំងឺរាតត្បាត។
- 75.5% នៃអ្នកឆ្លើយសម្ភាសន៍បានលើកឡើងថា ខ្លួនបានទទួលជំនួយឧបត្ថម្ភពីរដ្ឋាភិបាលក្នុងអំឡុងពេលបិទខ្ទប់។
- 22% បានទទួលជំនួយឧបត្ថម្ភនៅពេលពួកគេត្រូវបានព្យួរការងារ។

ក្រៅពីការគាំទ្រដែលកំណត់ដោយរដ្ឋាភិបាល ជំនួយផ្នែកហិរញ្ញវត្ថុដែលផ្តល់ដល់កម្មករនិយោជិតមានភាពខុសៗគ្នាទៅតាមរោងចក្រនីមួយៗ។ ដោយមិនរាប់បញ្ចូលកម្មករដែលត្រូវបានបញ្ឈប់ពីការងារ ពីរភាគបីនៃអ្នកឆ្លើយសម្ភាសន៍បានអះអាងថា ខ្លួនទទួលបានជំនួយឧបត្ថម្ភបន្ថែមមួយចំនួនពីនិយោជករបស់ខ្លួនក្នុងអំឡុងពេលជំងឺរាតត្បាត។ ទោះបីយ៉ាងណា ចំពោះអ្នកឆ្លើយសម្ភាសន៍ភាគច្រើន ការជួយឧបត្ថម្ភរបស់និយោជកត្រូវបានផ្តល់ក្នុងរូបភាពជាប្រាក់បៀវត្សចុងក្រោយរបស់កម្មករនិយោជិត (57 ភាគរយ)។ ជាងនេះទៅទៀត 32 ភាគរយនៃកម្មករនិយោជិតដែលបានស្ទង់មតិ មិនបានទទួលជំនួយឧបត្ថម្ភណាមួយពីនិយោជករបស់ខ្លួនឡើយក្នុងអំឡុងពេលជំងឺរាតត្បាតនេះ។

### ភាពអត់ឃ្លានមានការកើនឡើងនៅពេលកម្មករនិយោជិតបង្ខំចិត្តខ្ចីបុលដើម្បីរ៉ាប់រងថ្លៃចំណាយលើការរស់នៅជាមូលដ្ឋាន

ជំនួយហិរញ្ញវត្ថុមិនគ្រប់គ្រាន់សម្រាប់កម្មករនិយោជិតកាត់ដេរ មានន័យថា កម្មករនិយោជិតដែលប្រឈមមុខនឹងការព្យួរការងារ ការបញ្ឈប់ និងការកាត់បន្ថយម៉ោងធ្វើការ ត្រូវបានរុញច្រានឱ្យធ្លាក់ចូលក្នុងវិបត្តិកាន់តែធ្ងន់ធ្ងរ។

- 89% នៃកម្មករនិយោជិតបានឱ្យដឹងថា គ្រួសាររបស់ខ្លួនអស់ប្រាក់សម្រាប់ទិញអាហារចាប់តាំងពីជំងឺរាតត្បាតបានចាប់ផ្តើម
- 68% បាននិយាយថា ខ្លួនបានបង្ខំចិត្តកាត់បន្ថយការចំណាយ
- 35% បាននិយាយថា ប្រាក់ចំណូលរបស់ខ្លួនមិនគ្រប់គ្រាន់សម្រាប់ការចំណាយប្រចាំថ្ងៃឡើយ
- 47% នៃកម្មករនិយោជិតត្រូវបង្ខំចិត្តខ្ចីបុលប្រាក់បន្ថែម ដើម្បីយកមកចំណាយក្នុងគ្រួសារ

គ្រោះអត់ឃ្លានដែលមានការកើនឡើង និងញឹកញាប់ គឺជារឿងធម្មតាក្នុងចំណោមកម្មករនិយោជិតកាត់ដេរ ដោយស្ទើរតែពាក់កណ្តាលនៃកម្មករនិយោជិត (45 ភាគរយ) បានលើកឡើងថា ពេលខ្លះខ្លួនខ្វះខាតប្រាក់សម្រាប់ទិញអាហារ ហើយកម្មករ 2 នាក់ ក្នុងចំណោម 5 នាក់ (42 ភាគរយ) បានអះអាងថា ករណីនេះកើតឡើងញឹកញាប់ ឬញឹកញាប់ខ្លាំង។ កត្តានេះឆ្លុះបញ្ចាំងអំពីប្រាក់បៀវត្សរ៍ទាបនៅក្នុងឧស្សាហកម្មកាត់ដេរទាំងមូលនៅក្នុងប្រទេសកម្ពុជា ដែលនាំឱ្យកម្មករនិយោជិតជាច្រើនធ្លាក់ចូលទៅក្នុងវិបត្តិជំងឺរាតត្បាតដោយមានបន្ទុកបំណុលដ៏ធ្ងន់ធ្ងរ។ ស្ទើរតែពាក់កណ្តាលនៃកម្មករនិយោជិតដែលបានស្ទង់មតិបានលើកឡើងថា ខ្លួនបានខ្ចីបុលប្រាក់បន្ថែមក្នុងអំឡុងពេលជំងឺរាតត្បាតនេះ ដែលជាភស្តុតាងបង្ហាញថា ចំនួននេះអាចមានច្រើន ជាងនេះ។

សុវត្ថិភាពហិរញ្ញវត្ថុរបស់កម្មករនិយោជិតកាត់ដេរក៏រងផលប៉ះពាល់ផងដែរដោយសារការបាត់បង់ការងារ និងការកាត់ប្រាក់ឈ្នួលនៅក្នុងរង្វង់គ្រួសាររបស់ខ្លួន ដែលមានន័យថា សូម្បីតែក្នុងករណីដែលកម្មករដែលត្រូវ

បានស្ទង់មតិនៅបន្តមានការងារធ្វើក៏ដោយ ប៉ុន្តែសមាជិកគ្រួសារអាចប្រឈមនឹងការកាត់ប្រាក់ឈ្នួល ដែលបន្ទាប់មកប៉ះពាល់ដល់ការចំណាយក្នុងគ្រួសារ និងបណ្តាលឱ្យមានភាពអត់ឃ្លាន។

*"ក្នុងអំឡុងពេលបិទខ្ទប់ ខ្ញុំមិនបានទទួលជំនួយអាហារណាមួយពីអាជ្ញាធរមូលដ្ឋាន ឬនរណាម្នាក់ឡើយ។ ឪពុកម្តាយរបស់ខ្ញុំត្រូវលក់ជ្រូករបស់គាត់ ដើម្បីផ្ញើអាហារ និងប្រាក់មកឱ្យខ្ញុំ ដើម្បីទប់ទល់នឹងស្ថានភាពដោយសារយើងមិនអាចចេញទៅរកប្រាក់បានទេ"។*

- *ចាន់ណា កម្មករនិយោជិតកាត់ដេរ ក្នុងប្រទេសកម្ពុជា*

សម្រាប់កម្មករនិយោជិតដែលខ្ចីបុលប្រាក់បន្ថែមដើម្បីរ៉ាប់រង ការចំណាយក្នុងគ្រួសាររបស់ខ្លួន (47 ភាគរយ) ការទូទាត់សងបំណុលនោះមកវិញបានបង្កឱ្យមានភាពតានតឹងកាន់តែខ្លាំង។ ជប់មួយ ភាគរយ បានឱ្យដឹងថា ពួកគាត់ជួបការលំបាកក្នុងការសងសងបំណុលនោះទៅវិញ។ ជាងនេះទៅទៀត ជាងបីភាគបួន (81 ភាគរយ) នៃកម្មករនិយោជិតកំពុងបំពេញការងារបានសម្តែងការព្រួយបារម្ភថា ប្រសិនបើពួកគាត់បាត់បង់ការងារនោះពួកគាត់នឹងគ្មានលទ្ធភាពសងបំណុលបានទេ។

## 3. ប្រាក់ឈ្នួលមានស្ថិរភាព ប៉ុន្តែកម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារត្រូវបានកាត់ប្រាក់ចំណូលក្នុងចំនួនយ៉ាងច្រើន

ទិន្នន័យប្រាក់ឈ្នួលពីខែសីហា ឆ្នាំ2021 ផ្តល់ការបង្ហាញជាវិជ្ជមានថា សម្រាប់កម្មករដែលមិនប្រឈមមុខនឹងការបញ្ឈប់ពីការងារក្នុងអំឡុងជំងឺរាតត្បាត ប្រាក់ចំណូលបានត្រឡប់ទៅកម្រិតមុនជំងឺរាតត្បាតវិញ ដោយកម្មករនិយោជិតបានលើកឡើងច្បាស់អំពីការកើនឡើងប្រាក់ឈ្នួល។ ករណីនេះទំនងជាឆ្លុះបញ្ចាំងអំពីកត្តាមួយចំនួន ដែលរួមមានស្ថិរភាពនៃទីផ្សារសម្លៀកបំពាក់អន្តរជាតិ ដោយហាងលក់រាយនឹងបើកឡើងវិញនៅសហរដ្ឋអាមេរិក និងនៅសហភាពអឺរ៉ុប ហើយការលក់សម្លៀកបំពាក់បានស្ទុះងើបឡើងវិញបន្ទាប់ពីការបិទខ្ទប់អស់រយៈពេល ដ៏យូរ។ ទន្ទឹមនឹងនេះក៏មានកំណើនផលិតភាពផងដែរ ដោយរោងចក្រមួយចំនួនទទួលបានបញ្ជាទិញកើនឡើង ហើយកម្មករនិយោជិតទទួលបានគោលដៅផលិតកម្មខ្ពស់ និងទទួលបានការងារថែមម៉ោងកាន់តែច្រើនជាងមុន។

ទោះបីលទ្ធផលស្ទង់មតិមានភាពវិជ្ជមាន ប៉ុន្តែគួរកត់សម្គាល់ថា ទោះបីជាមានការងើបឡើងវិញបែបនេះក៏ដោយ កម្មករនិយោជិតស្ទើរតែទាំងអស់នៅតែរកប្រាក់ចំណូលបានទាបជាងប្រាក់ឈ្នួលទ្រទ្រង់ជីវភាពដដែលទេ។

- នៅខែសីហា ឆ្នាំ2021 ប្រាក់បៀវត្សរ៍រាយការណ៍ជាមធ្យមសម្រាប់កម្មករនិយោជិតដែលមិនត្រូវបានបញ្ឈប់ពីការងារមានចំនួន 276 ដុល្លារក្នុងមួយខែ បើប្រៀបធៀបជាមួយប្រាក់បៀវត្សរ៍ជាមធ្យមចំនួន 240 ដុល្លារអាមេរិក នៅមុនពេលជំងឺរាតត្បាតកើតឡើង
- កម្មករនិយោជិតស្ទើរតែទាំងអស់នៅតែបន្តរកប្រាក់ចំណូលបានទាបជាងប្រាក់ឈ្នួលទ្រទ្រង់ជីវភាពដដែល
- កម្មករនិយោជិតដែលប្រឈមនឹងការបញ្ឈប់ពីការងារ ធ្លាប់ត្រូវបានកាត់ប្រាក់បៀវត្សរ៍ជាមធ្យមចំនួន 145.90 ដុល្លារក្នុងមួយខែ




កម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារក្នុងអំឡុងពេលជំងឺរាតត្បាតនៅតែស្ថិតក្នុងស្ថានភាពធ្ងន់ធ្ងរ។ មុនពេលត្រូវបានបញ្ឈប់ពីការងារ កម្មករនិយោជិតនៅរោងចក្រ Violet Apparel ទទួលបានប្រាក់បៀវត្សជាមធ្យមប្រចាំខែចំនួន 343.90 ដុល្លារអាមេរិក ដែលជាចំនួនខ្ពស់បំផុតសម្រាប់កម្មករនិយោជិតដែលយើងបានស្ទង់មតិ។ នៅខែសីហា ឆ្នាំ2021 ប្រាក់បៀវត្សជាមធ្យមប្រចាំខែសម្រាប់កម្មករនិយោជិតមកពីរោងចក្រ Violet Apparel មានចំនួន 198 ដុល្លារ ពោលគឺការធ្លាក់ចុះប្រាក់ឈ្នួលជាមធ្យម 145.90 ដុល្លារក្នុងមួយខែ។




**4. ហានិភ័យខ្ពស់នៃការឆ្លងជំងឺ COVID-19 នៅតាមរោងចក្រកាត់ដេរ**

ការវិលត្រឡប់ចូលធ្វើការវិញបាននាំមកនូវបញ្ហាប្រឈមមួយចំនួនសម្រាប់កម្មករនិយោជិតកាត់ដេរ ជាពិសេសនៅពេលករណីជំងឺ COVID-19 មានការកើនឡើងនៅទូទាំងប្រទេសកម្ពុជានៅក្នុងឆមាសទីមួយ ឆ្នាំ2021។ កម្មករនិយោជិតដែលបានស្ទង់មតិ បានសម្តែងការព្រួយបារម្ភអំពីហានិភ័យនៃការឆ្លងជំងឺ COVID-19 នៅក្នុងរោងចក្រដែលមានមនុស្សកកកុញ សាលអាហារថ្ងៃត្រង់ដែលមានមនុស្សច្រើនចេញចូល និងនៅលើរថយន្តធ្វើដំណើររួមដែលមានមនុស្សជិះប្រជ្រៀតគ្នា។

- 51% នៃកម្មករនិយោជិតដែលបានស្ទង់មតិគិតថា ខ្លួនមានភាពប្រឈមខ្ពស់ក្នុងការឆ្លងជំងឺ COVID-19 នៅកន្លែងធ្វើការ ហើយ 28% គិតថា ខ្លួនមានហានិភ័យកម្រិតមធ្យម
- 58% បង្ហាញការអំពីព្រួយបារម្ភចំពោះករណីអាជ្ញាធរធ្វើតេស្តរកជំងឺ COVID-19 ហើយ 43% ព្រួយបារម្ភអំពីការដាក់ឱ្យធ្វើចត្តាឡីស័ក ប្រសិនបើពួកគាត់ធ្វើតេស្តវិជ្ជមាន
- អ្នកឆ្លើយសម្ភាសន៍តិចជាង 10% បាននិយាយថា និយោជកបានចាត់វិធានការដើម្បីធានាថា កម្មករនិយោជិតត្រូវបានរក្សាគម្លាតសង្គម

- មានតែ 5% ប៉ុណ្ណោះដែលនិយាយថា កន្លែងធ្វើការរបស់ខ្លួនត្រូវបានសម្អាត និងបាញ់ថ្នាំសម្លាប់មេរោគជាប្រចាំ

ស្ទើរតែទាំងអស់នៃអ្នកឆ្លើយសម្ភាសន៍ (99 ភាគរយ) បាននិយាយថា និយោជករបស់ខ្លួនបានអនុវត្តវិធានការជាក់ស្តែងដើម្បីការពារពួកគេមិនឱ្យឆ្លងជំងឺ COVID-19 តាមរយៈការផ្តល់ម៉ាស និងជែលលាងដៃ និងធ្វើការពិនិត្យសីតុណ្ហភាពនៅកន្លែងធ្វើការ។ ទោះបីយ៉ាងណា មានការលើកអំពីក្តីបារម្ភថា ពេលខ្លះប្រដាប់វាស់កម្តៅលើថ្ងាសមិនដំណើរការ ឬការពិនិត្យសីតុណ្ហភាពធ្វើឡើងតែនៅពេលព្រឹក នៅពេលដែលកម្មករចូលរោងចក្រ ហើយមិនត្រូវបានពិនិត្យម្តងទៀតនៅពេលរសៀលឡើយ។

ជាងនេះទៅទៀត មានអ្នកឆ្លើយសម្ភាសន៍តែ 2.6 ភាគរយប៉ុណ្ណោះដែលបាននិយាយថា និយោជករបស់ខ្លួនកំពុងអនុវត្តវិធានការកាត់បន្ថយហានិភ័យរបស់កម្មករក្នុងការឆ្លងជំងឺ COVID-19 នៅលើរថយន្តដឹកជញ្ជូនដែលមានមនុស្សប្រជ្រៀតគ្នានៅពេលធ្វើដំណើរទៅ និងមកពីកន្លែងធ្វើការ។ កម្មករនិយោជិតក៏បានស្នើឡើងថា ការប្តូរវេនគ្នាដើម្បីទទួលទានអាហារថ្ងៃត្រង់ និងនៅពេលចេញពីរោងចក្រអាចជួយកាត់បន្ថយចំនួនមនុស្សកកកុញ។

កម្មករនិយោជិតព្រួយបារម្ភអំពីលទ្ធភាពក្នុងការរកប្រាក់នៅពេលខ្លួនឆ្លងជំងឺ COVID-19។ អ្នកឆ្លើយសម្ភាសន៍ចំនួនជាងពាក់កណ្តាល (50.5 ភាគរយ) បាននិយាយថា ពួកគាត់ព្រួយបារម្ភខ្លាចរោងចក្រដែលខ្លួនធ្វើការត្រូវបិទទ្វារ ប្រសិនបើរកឃើញករណីជំងឺ COVID-19 ដោយសារវិធានការការពារមិនបានគ្រប់គ្រាន់សម្រាប់កម្មករនិយោជិតនៅក្នុងរោងចក្រ ដែលមានន័យថា ពួកគាត់ត្រូវបង្ខំចិត្តធ្វើការក្នុងស្ថានភាពគ្មានសុវត្ថិភាពទាំងប្រថុយប្រថាន ហើយអាចទទួលបានជំនួយហិរញ្ញវត្ថុតិចតួចបំផុត ប្រសិនបើពួកគេឆ្លងមេរោគនេះ។

**5. សិទ្ធិរបស់កម្មករនិយោជិតត្រូវរងការគំរាមកំហែង**

នៅពេលជំងឺ COVID-19 បានធ្វើឱ្យវិស័យកាត់ដេរកម្ពុជាធ្លាក់ទៅក្នុងភាពវឹកវរ សិទ្ធិរបស់កម្មករនិយោជិតមានភាពតានតឹងកាន់តែខ្លាំង។ មុនពេលមានជំងឺរាតត្បាត រោងចក្រកាត់ដេរជាច្រើនមិនបានលើកកម្ពស់សិទ្ធិការងារជាមូលដ្ឋានរបស់កម្មករនិយោជិតឡើយ ដូចជាសេរីភាពក្នុងការបង្កើតសមាគម និងការចរចាជាសមូហភាព ជាដើម។ នៅពេលនេះ កម្មករនិយោជិតលើកឡើងថា ស្ថានភាពនេះកាន់តែអាក្រក់ទៅៗ។

- កម្មករនិយោជិតដែលបានស្ទង់មតិចំនួន 90.7% បាននិយាយថា ខ្លួនមានការព្រួយបារម្ភកាន់តែខ្លាំងអំពីសុវត្ថិភាពការងារ ចាប់តាំងពីជំងឺរាតត្បាតបានវាយប្រហារ
- 56% បាននិយាយថា សិទ្ធិរបស់ខ្លួននៅកន្លែងធ្វើការកាន់តែយ៉ាប់យ៉ឺន ចាប់តាំងពីពេលកើតមានជំងឺរាតត្បាត

ការព្រួយបារម្ភជាទូទៅដែលលើកឡើងដោយកម្មករនិយោជិត រួមមានដូចជា ពួកគេមិនហ៊ានដាក់ពាក្យបណ្តឹងនៅក្នុងស្ថានភាពដូចបច្ចុប្បន្ន ដោយមានកម្មករនិយោជិតបង្ហាញអំពីផលវិបាកផ្ទាល់ខ្លួន ដូចជាត្រូវបានមេក្រុមស្រែកគំហកដាក់ ឬដាក់បន្ទុកឱ្យធ្វើការងារធ្ងន់ធ្ងរ ប្រសិនបើពួកគេលើកឡើងអំពីបញ្ហាសិទ្ធិរបស់កម្មករនិយោជិត។ អ្នកឆ្លើយសម្ភាសន៍ក៏បានលើកឡើងផងដែរថា ចាប់តាំងពីជំងឺរាតត្បាតបានចាប់ផ្តើម និយោជកមានភាពយឺតយ៉ាវក្នុងការឆ្លើយតបទៅនឹងបណ្តឹងតវ៉ា ប៉ុន្តែពួកគេមិនហ៊ានរៀបចំការតវ៉ា ដែលចាំបាច់ដើម្បីជំរុញឱ្យរោងចក្រឆ្លើយតបទៅនឹងកង្វល់ និងការទាមទាររបស់ខ្លួន។

**របាយការណ៍ដោយឡែក៖ ការរីករាលដាលករណីកម្មករនិយោជិតត្រូវបានបៀតបៀននៅកន្លែងធ្វើការ**

របាយការណ៍របស់កម្មករនិយោជិតកាត់ដេរអំពីការបៀតបៀននៅកន្លែងធ្វើការគឺជាសញ្ញាគួរឱ្យព្រួយបារម្ភ

- 45% នៃអ្នកឆ្លើយសម្ភាសន៍ជាស្ត្រី និង 21% នៃអ្នកឆ្លើយសម្ភាសន៍ជាបុរសបានអះអាងថា ខ្លួនបានជួបប្រទះអំពើហិង្សា ឬការបៀតបៀននៅកន្លែងធ្វើការ។
- 56% បាននិយាយថា ពួកគេដឹងពីបុគ្គលផ្សេងទៀតដែលបានជួបប្រទះការបៀតបៀន ឬអំពើហិង្សាយេនឌ័រនៅកន្លែងធ្វើការ។
- 63.5% នៃអ្នកឆ្លើយសម្ភាសន៍បានលើកឡើងថា ករណីនានាមិនត្រូវបានរាយការណ៍ និងដោះស្រាយឡើយ ឬពួកគេមិនបានដឹងថា តើករណីនេះត្រូវបានដោះស្រាយឬដូចម្តេចឡើយ។

ទម្រង់ទូទៅបំផុតនៃការបៀតបៀន គឺជាការរំលោភបំពានដោយពាក្យសម្តី ដោយកម្មករនិយោជិតដែលរងផលប៉ះពាល់ស្ទើរតែទាំងអស់ (98 ភាគរយ) បានអះអាងថា ខ្លួនត្រូវបានបៀតបៀនដោយពាក្យសម្តីនៅកន្លែងធ្វើការ។ 8 ភាគរយនៃអ្នកឆ្លើយសម្ភាសន៍បានបញ្ជាក់ថា ខ្លួនត្រូវបានរំលោភបំពានលើរូបរាងកាយ និង 4 ភាគរយបាននិយាយថា ពួកគេបានជួបប្រទះការរំលោភបំពានផ្លូវភេទ។ ចំពោះករណីពាក់ព័ន្ធនឹងបុគ្គលផ្សេងទៀត អ្នកឆ្លើយសម្ភាសន៍ចំនួនបីភាគបួន (77.3 ភាគរយ) បានអះអាងថា ករណីពាក់ព័ន្ធនឹងការបៀតបៀនដោយពាក្យសម្តី 13 ភាគរយពាក់ព័ន្ធនឹងការរំលោភបំពានរាងកាយ និង 9 ភាគរយពាក់ព័ន្ធនឹងការរំលោភបំពានផ្លូវភេទ។

ទោះបីជាគំរូសម្រាប់អ្នកឆ្លើយសម្ភាសន៍ជាអ្នកប្តូរភេទពុំមានចំនួនស្ថិតិច្រើនក៏ដោយ ប៉ុន្តែគួរកត់សម្គាល់ថា អ្នកឆ្លើយសម្ភាសន៍ប្តូរភេទទាំងអស់បានលើកឡើងថា ខ្លួនបានជួបប្រទះអំពើហិង្សា ឬការបៀតបៀននៅកន្លែងធ្វើការ។

ករណីភាគច្រើនមិនបានរាយការណ៍ទេ ដោយមានតែមួយភាគបីនៃអ្នកឆ្លើយសម្ភាសន៍ (32.2 ភាគរយ) ប៉ុណ្ណោះដែលបានបញ្ជាក់ថា ករណីត្រូវបានរាយការណ៍ និងមានការឆ្លើយតបពីនិយោជក ដោយលើកឡើងអំពីវប្បធម៌និទណ្ឌភាពនៅក្នុងរោងចក្រកាត់ដេរ ដែលកម្មករនិយោជិតទទួលរងការបៀតបៀន និងការរំលោភបំពានដោយមានជម្រើសដំណោះស្រាយតែមួយចំនួនតូចប៉ុណ្ណោះ។

## 4. សេចក្តីសន្និដ្ឋាន

កម្មករនិយោជិតកាត់ដេរនៅប្រទេសបង់ក្លាដែស និងកម្ពុជាបានរស់នៅដោយពឹងផ្អែកលើប្រាក់ឈ្នួលក្រោមកម្រិតអប្បបរមារួចជាស្រេច មុនពេលការផ្ទុះឡើងនៃ COVID-19 ក្នុងខែធ្នូ ឆ្នាំ 2019 ដោយប្រាក់ឈ្នួលក្រីក្រ និងលក្ខខណ្ឌការងារមិនល្អ គឺជាកត្តាចម្បងនៃឧស្សាហកម្មកាត់ដេរក្នុងពិភពលោក។ នៅពេលជំងឺរាតត្បាតបានវាយប្រហារប្រទេសទាំងពីរក្នុងខែមីនា ឆ្នាំ2020 កម្មករនិយោជិតកាត់ដេរបានធ្លាក់ចូលទៅក្នុងវិបត្តិ ដោយសារតែក្រុមហ៊ុនម៉ាកយីហោរបស់អូស្ត្រាលី និងអន្តរជាតិ បានបោះបង់កម្មករនិយោជិតដែលផលិតសម្លៀកបំពាក់របស់ពួកគេ។

រយៈពេលពីរឆ្នាំក្រោយមកទៀត វិស័យកាត់ដេរបានប្រឈមមុខនឹងការអាក់ខានខ្សែសង្វាក់ផ្គត់ផ្គង់ ការបិទហាង និងការគំរាមកំហែងដល់ខ្សែបន្ទាត់ខាងក្រោមនៃវិស័យនេះ។ ប៉ុន្តែទោះបីក្រុមហ៊ុនម៉ាកយីហោជាច្រើនបានខាតបង់ប្រាក់ចំណេញរបស់ខ្លួនយ៉ាងណាក្តី ប៉ុន្តែគឺកម្មករនិយោជិតកាត់ដេរនៅផ្នែកខាងក្រោមខ្សែច្រវាក់ផ្គត់ផ្គង់ពិភពលោកទៅវិញទេដែលបានខាតបង់ដោយសារតែវិបត្តិនេះ។ នៅពេលការងារត្រូវបាត់បង់ ប្រាក់ឈ្នួលត្រូវបានកាត់បន្ថយ ហើយសិទ្ធិនៅកន្លែងធ្វើការត្រូវរងការគំរាមកំហែង កម្មករនិយោជិតកាត់ដេរធ្លាក់ចូលកាន់តែជ្រៅទៅក្នុងភាពក្រីក្រ ភាពអត់ឃ្លាន និងបំណុល។

កម្មករនិយោជិតកាត់ដេរបានទាមទារជាយូរមកហើយឱ្យមានកំណែទម្រង់វិស័យដែលកសាងបន្ថែមទៅលើការទាញយកប្រយោជន៍ពីពួកគេ ហើយជំងឺរាតត្បាតបានធ្វើឱ្យការអំពាវនាវរបស់ពួកគេកាន់តែជួបការ

លំបាក។ ក្រុមហ៊ុនម៉ាកយីហោអន្តរជាតិ និងរដ្ឋាភិបាលត្រូវក្រោកឡើងដើម្បីដោះស្រាយបញ្ហាប្រឈមដែលបង្កឡើងដោយជំងឺ COVID-19 និងត្រូវប្តេជ្ញាការកសាងឡើងវិញឱ្យកាន់តែប្រសើរឡើងពីវិបត្តិជំងឺរាតត្បាតតាមរយៈការផ្តល់កិច្ចគាំពារសង្គមជាសកល និងការផ្តល់ប្រាក់ឈ្នួលទ្រទ្រង់ជីវិតដល់កម្មករនិយោជិតទាំងអស់នៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់សម្លៀកបំពាក់។

**ការសិក្សាករណីទី១៖ ផលប៉ះពាល់នៃវិបត្តិកូវីដ លើកម្មការនីកាត់ដេរ**




នេះគឺម៉ុម អាយុ៣៨ឆ្នាំ ខ្ញុំធ្វើការនៅរោងចក្រ ហេនសាំ ដែលផ្គត់ផ្គង់ទៅ Walmart។ ខ្ញុំធ្វើការនៅទីនេះរយៈពេល ៥ឆ្នាំ។ ខ្ញុំបានធ្វើការនៅទីនេះអស់រយៈពេល៥ឆ្នាំ។ ខ្ញុំបានចូលរួមក្នុងវិស័យកាត់ដេរអស់រយៈពេល ១៥ ឆ្នាំហើយ តាំងពីឆ្នាំ២០០៦។ ខ្ញុំមកពីខេត្តកំពង់ចាម។

**១. តើការងារជាកម្មកររោងចក្រមានន័យយ៉ាងណាចំពោះអ្នក?**

ខ្លួនខ្ញុំផ្ទាល់ យើងមិនមានជម្រើស។ យើងជាកម្មករសាមញ្ញធម្មតា គ្មានសម្ថភាពអីទៅធ្វើការងាផ្សេងក្រៅពីការងាររោងចក្រ ព្រោះការងាររោងចក្រ កម្រិតវប្បធម៌គេមិនកំណត់។ ជាទូទៅស្រុកខ្មែរយើង ពឹងផ្អែកលើការងាររោងចក្រសំខាន់ ឱកាសការងារវាទូលំទូលាយ។ខ្ញុំគិតថា បើខ្ញុំអត់ធ្វើរោងចក្រ ខ្ញុំអត់មានចំណូលប្រចាំថ្ងៃ។ នៅពេលដែលយើងត្រូវខ្ចីប្រាក់ពីធនាគារ ពួកគេក៏តម្រូវឱ្យយើងមានការងារដែលច្បាស់លាស់ ហើយជាកម្មកររោងចក្រ ការងាររបស់យើងគឺមានច្បាស់លាស់។

**២. តើជីវិតការងាររបស់អ្នកផ្លាស់ប្តូរយ៉ាងណាខ្លះ បន្ទាប់ពីកូវីដចូលមកក្នុងប្រទេសកម្ពុជា?**

វាផ្លាស់ប្តូរដែរនឹងបង ផ្លាស់ប្តូរទី១ រោងចក្រអត់សូវមានការថែមម៉ោង ឬក៏ខ្លាចមានហានិភ័យអីមួយកើតឡើង ខ្លាចរោងចក្រគេបិទអី គេអត់មានគិតប្រាក់ឈ្នួល អត់គិតប្រាក់ប្រយោជន៍អីផ្សេងៗឲ្យ ការថែមម៉ោងដូចជាមានការកាត់បន្ថយជាងមុន ហើយការងារគេរិតត្បិតជាងកាលមិនទាន់មានកូវីត ច្បាប់ការងារអីតឹងតែងជាងពី

មុន ខ្លាចក្រុមហ៊ុនខាត បិទរោងចក្រអីចឹង។ ដូចថា ពេលរោងចក្រជួបស្ថានភាពកូវីតចឹង ថៅកែគាត់អត់សូវឡើងប្រាក់ឈ្នួលឲ្យយើង ព្រោះអីគាត់លើកឡើងថាកូវីតមិនអាចឡើងប្រាក់ឈ្នួលនិងប្រាក់ប្រចាំឆ្នាំបានច្រើន និងកំណត់អីវ៉ាន់យើងដេរហួសហេតុជាងធម្មតា ប្រាក់ខែអត់សូវឡើងទេ តែរោងចក្រតំឡើងទំនិញត្រូវដេរច្រើនរហូតដល់១០%។ ធម្មតាក្នុងមួយឡាញ គេត្រូវកំណត់អាវចេញ ត្រូវដេរឱ្យបាន ៣៥០ ឥឡូវ ចំនួនឡើងដល់ ៤០០។ សុំច្បាប់អីតឹងតែង។ សម្រាប់បុគ្គលិកថ្មី ថៅកែមិនផ្តល់ប.ស.ស។ ថៅកែឆ្លៀតឱកាសដែលរោងចក្រជាច្រើនបិទដោយសារកូវីដ កម្មករជាច្រើនកំពុងស្វែងរកការងារថ្មី គេបានយកឱកាសនេះ ដោយមិនបានផ្តល់អត្ថប្រយោជន៍ដល់កម្មករថ្មី។ គេផ្តល់ប្រាក់ប្រចាំថ្ងៃ ឱ្យកម្មករ ចឹងកម្មករអត់បានអត្ថប្រយោជន៍ឈប់សម្រាកចុងសប្តាហ៍ ឬអត្ថប្រយោជន៍ផ្សេងទេ។ ប្រសិនបើគេមិនសប្បាយចិត្តនឹងយើង គេអាចបណ្តេញយើងភ្លាមៗ ហើយជ្រើសរើសកម្មករថ្មី ព្រោះមានកម្មករជាច្រើនកំពុងស្វែងរកការងារធ្វើ។ ជាទូទៅ ប្រសិនបើកម្មករថ្មីធ្វើបានល្អ រោងចក្រត្រូវផ្តល់កិច្ចសន្យាឱ្យពួកគេត្រឹមត្រូវ។ ប៉ុន្តែឥឡូវនេះ គេអត់ឱ្យទេ។

វិក្កយបត្រទឹកភ្លើងកើនឡើងជាងមុនពេលមានកូវីដទៀត។ វិក្កយបត្រភ្លើងរបស់ខ្ញុំ បានកើនឡើងពី ៥០០០ រៀល ទៅ ១០០០០ រៀល។ វិក្កយបត្រទឹក នៅធម្មតាទេ ប៉ុន្តែនៅផ្ទះជួល ពីរដ្ឋមកគេគិត មួយគូប ៦១០ តែបើតាមផ្ទះជួល គឺមួយគូប៣០០០ រៀល។ ចំពោះតម្លៃជួលវិញ នៅកន្លែងខ្ញុំនៅដដែល ប៉ុន្តែនៅផ្ទះផ្សេង គេឡើង។ ផ្ទះជួលខ្លះចង់ឡើងថ្លៃជួល ពេលឮថាប្រាក់ខែកម្មករកើនឡើង ២ ដុល្លារ។ តម្លៃអាហារឡើងថ្លៃជាងពីមុន។ ដូចជា ត្រីអីមួយគីឡូ ១៥០០០ ឬ ១២០០០ អីចឹង។ ដូចបន្លែអី ក៏ឡើងថ្លៃដែរ។ កាលពីមុន យើងអាចទិញ ៥០០ រៀលយើងអាចស្លគ្រាន់ ឥឡូវនេះយើងត្រូវទិញ ១០០០ រៀល ទៅ ២០០០ រៀល ក្នុងមួយពេល។ ថ្លៃសាំងឡើងថ្លៃពី ៣០០០រៀល ទៅ ៤០០០ រៀល។

យើងក៏មានការប្រឈមនឹង កូវីដដែរ។ នៅរោងចក្រ គេមានវិធានការពាក់ម៉ាស និងបាញ់អាលកុលប្រចាំថ្ងៃ។ ប៉ុន្តែវាប្រឈមនៅពេលជិះឡានពីខេត្តទៅកន្លែងធ្វើការ និងពេលទិញបាយញ៉ាំជុំៗគ្នា។ គេមិនបានចាត់វិធានការអីទេ។ ខ្ញុំច្រើនទៅហូបបាយផ្ទះខ្លួនឯង មួយរយៈហ្នឹង ផ្ទះដើរតែ ១៥ នាទីប៉ុណ្ណោះ។ តែអ្នកដែលធ្វើដំណើរមកពីខេត្ត គាត់មិនអាចទៅផ្ទះបានទេ។

កាលពីខែ៤ ខែ៥ ឆ្លង៥០០នាក់។ ពេលធ្វើតេស្តលើកទីមួយហើយ គេឱ្យនៅផ្ទះ១៤ថ្ងៃ។ លើកទីពីរ រកឃើញ ៣០០នាក់ផ្សេង ហើយគេបានឱ្យយើងនៅផ្ទះពីរបីថ្ងៃទៀត ហើយចូលធ្វើការវិញ។ ធ្វើតេស្តទី៣រកឃើញ១០០នាក់ជាងអីចឹង និងធ្វើតេស្តទី៤ មិនមានទេ។ ឥឡូវនេះ យើងទាំងអស់គ្នាបានចាក់វ៉ាក់សាំងហើយគ្រប់គ្នា។ ក្នុងអំឡុងពេលបិទខ្ទប់ ថៅកែបានបង់ប្រាក់ឱ្យយើងចំនួន ២០% នៃប្រាក់ឈ្នួល បូករួមទាំងលុយអត្ថប្រយោជន៍ សរុបចំនួន ៦០ដុល្លារ។ ចំពោះកម្មករដែលរកឃើញវិជ្ជមានកូវីដ គេបានទទួលការព្យាបាលពីរដ្ឋាភិបាល ហើយអត់មានបើកប្រាក់ខែឱ្យទេតែគេបានពីប.ស.ស។

**៣. តើមានការផ្លាស់ប្តូរវិជ្ជមាន ពីការរាតត្បាតជម្ងឺកូវីដ ដែរឬទេ?**

តាំងពីជួបប្រទះកូវីដមក ដូចអត់មានឃើញអីល្អផង លក្ខខណ្ឌការងារដូចកាន់តែតឹងតែង កាត់បន្ថយថ្ងៃបុណ្យថ្ងៃអីផ្សេងៗច្រើន។ ថ្ងៃឈប់ ថ្ងៃបុណ្យកាត់បន្ថយ (៦ថ្ងៃ) បើ ចំថ្ងៃអាទិត្យ អត់លើកទេ។ គោលដៅកាន់តែកើនឡើងខ្ពស់ ទំនិញទីផ្សារកាន់តែឡើងថ្លៃ ជីវភាពរបស់ពួកយើងធ្លាក់ចុះ។ ដូចច្នេះ មិនមានការរីកចម្រើន គ្មានភាពវិជ្ជមានណាកើតឡើងឡើយចាប់តាំងពីកូវីដមក។

**៤. តើអ្នកដែលលើកកង្វល់ ឬបញ្ហាប្រឈម មកនិយាយជាមួយថៅកែ ដែឬទេ? តើថៅកែរបស់អ្នកបានធ្វើអ្វីខ្លះ ដើម្បីដោះស្រាយបញ្ហាប្រឈម ឬកង្វល់របស់អ្នក?**

ទីមួយខ្ញុំបានលើឡើងពីចំនួនកំណត់ហួសហេតុពេក និងជ្រើសកម្មករដែលអត់ឱ្យពេញសិទ្ធិ ហើយថៅកែគេបានលើកឡើងថាបច្ចុប្បន្នហ្នឹងកូវីដចឹង ហើយគេដេរខោអាវខាត ហើយអីវ៉ាន់ច្រើនខកជើងដោយសារកូវីដ ចឹងក្រុមហ៊ុនគេខាតច្រើន ដោយសារដេរអត់ទាន់ឱ្យគេ ហើយរោងចក្រត្រូវបានពិន័យ។

## ៥. តើសហជីពរបស់អ្នកបានជួយអ្វីខ្លះ ក្នុងបញ្ហានេះ?

ខ្ញុំជាសមាជិករបស់សហជីពកម្ពុជា ហៅកាត់ CATU។ ខ្ញុំមាននាទីជាហិរញ្ញិក។ ដំបូងឡើយ ខ្ញុំមិនគិតចង់ចូលសហជីពដែរ តែពេលខ្ញុំធ្វើការទៅខ្ញុំឃើញការគៀបសង្កត់ពីប្រធានក្រុម ដេរកូនក្រុម បំពានសិទ្ធិ។ ដូចថាគ្នាដេរចំនួនបានហើយដេរគ្នាទៀត ពេលដែលកម្មករឈឺ សុំចេញនៅម៉ោង ៤ រសៀល គេអត់ឱ្យចេញ ហើយតម្រូវពួកគេឱ្យធ្វើការបន្ថែមម៉ោង។ នៅពេលខ្ញុំឃើញរឿងអស់ហ្នឹង ខ្ញុំមានអារម្មណ៍ថាវាខុស ដល់ពេលចឹងខ្ញុំក៏គិតថាបើសិនជាខ្ញុំតវ៉ាក្នុងនាមខ្ញុំជាកម្មករធម្មតាគឺខ្ញុំអត់ឈ្នះគេទេ យើងអត់មានសិទ្ធិទៅតវ៉ា ឬក៏ជជែកជាមួយថៅកែ។ ចឹង ខ្ញុំសម្រេចចិត្តចូលសហជីពដើម្បីចងគ្នាជាក្រុម ដើម្បីការពារសិទ្ធិកម្មករ។

ក្នុងអំឡុងពេលកូវីដ សហជីពជួយសម្រួលច្បាប់ ជួយការពារសិទ្ធិ ជួយទាមទាររដ្ឋាភិបាល និងថៅកែក្រុមហ៊ុន ឱ្យជួយផ្តល់ជំនួយហិរញ្ញវត្ថុដល់កម្មករក្នុងអំឡុងពេលបិទខ្ទប់ក្នុងខែបួន រយៈពេល ២១ថ្ងៃដែលស្ថិតនៅក្នុងតំបន់លឿងទុំ។ រហូតដល់ខែ ៥ ពួកខ្ញុំត្រូវបានគេយកសំណាក មានអ្នកពាក់ព័ន្ធច្រើន ផ្អាកមួយរយៈពេលដែរ។ កម្មករទទួលបាន ៤០ដុល្លារពីរដ្ឋាភិបាល អត់បានពីក្រុមហ៊ុនទេ។ បន្ទាប់មកក្នុងអំឡុងពេលចត្តាឡីស័ករយៈពេល ២០ ថ្ងៃ ក្នុងខែឧសភា សហជីព ធ្វើសំណើទៅកាន់ថៅកែ ហើយស្នើទៅក្រសួង ក្រោយមកក្រសួងបានឆ្លើយតបថា គ្មានច្បាប់តម្រូវឱ្យថៅកែធ្វើដូច្នេះទេ នេះត្រូវពឹងលើភាពសប្បុរសរបស់ថៅកែ។ រោងចក្រផ្សេង គេមានមនោសញ្ចេតនាជាមួយកម្មករគឺគេឲ្យ ១០០% ដូចជារោងចក្របីរី និងរោងចក្រផ្សេងទៀត។ សម្រាប់រោងចក្រ Handsome សហជីពដាក់សំណើសុំឲ្យថៅកែបើកប្រាក់ឈ្នួលឲ្យកម្មករ ១០០%។ ជាការឆ្លើយតបទៅនឹងសំណើរបស់ CATU ថៅកែបានឱ្យយើងចំនួន $៦០ (ដែលរួមបញ្ចូល ២០% នៃប្រាក់ខែ និងអត្ថប្រយោជន៍មួយចំនួនផ្សេងទៀត)។ បើសហជីពមិនតវ៉ារឿងនេះទេ យើងនឹងមិនទទួលបានអ្វីទេ ព្រោះរដ្ឋាភិបាលមិនបានចាត់វិធានការទេ។

ក្រៅពីនេះ សហជីពបានជួយទាមទារច្បាប់ឈឺ ច្បាប់ឈប់សម្រាក បានជួយសម្រួលការជេរប្រមាថអីផ្សេងៗ ហើយបើមានការគេហៅកម្មករទៅព្រមាន សហជីពអាចជួយដោះស្រាយបានតាមនឹង។ ជាឧទាហរណ៍ បើយើងដេរអត់បានដូចចំនួនដែលគេកំណត់ ដូចមួយម៉ោងត្រូវបាន ១២០ គឺត្រូវតែបាន១២០ បើខ្វះតែ២០ ពីបីម៉ោងក្រោយគេដឹងតែតេហៅទៅព្រមាន។ ខ្ញុំធ្លាប់ជួបការព្រមានដែរកាលពីមុន កាលពីខ្ញុំមិនទាន់ធ្វើជាសមាជិកសហជីព ពេលនឹងខ្ញុំធ្វើបានសម្រេចគោលដៅហើយ តែគេព្រមានខ្ញុំដោយសារម៉ាស៊ីនខូច។ ខ្ញុំបានតបទៅពួកគេវិញ ខ្ញុំសួរថា ចឹងថៅកែរកតែឱកាសបណ្តេញកម្មករ និងមិនការពារផលប្រយោជន៍កម្មករទេ? បន្ទាប់មក គេក៏ឈប់ថាអី។

អំពីគោលដៅនេះ ថៅកែថា នៅក្នុងប្រទេសផ្សេងទៀត កម្មករអាចផលិតបានគោលដៅខ្ពស់ជាងនេះទៅទៀត ហើយខ្ញុំក៏ថា ចំនួនយើងអាចប្រៀបធៀបបាន ហេតុអ្វីប្រាក់ខែប្រៀបធៀបមិនបាន ថៅកែអត់មាត់ គាត់បែរជាលើកឡើងថាប្រទេសយើងចឹង ខុសគ្នាពីប្រទេសផ្សេង។ គេថា បើយើងបន្តទាមទារ ថ្ងៃណាមួយរោងចក្រនឹងត្រូវបិទ ហើយកម្មករនឹងបាត់បង់ការងារ។

## ៦. តើជំនួយអ្វីខ្លះ អ្នកគិតថានិយោជករបស់អ្នកគួរមាន ដើម្បីជួយអ្នកឱ្យកាន់តែប្រសើរឡើងក្នុងអំឡុងពេលដ៏លំបាកនេះ?

ថៅកែគួរតែជួយសម្រួលការងារកម្មករ កុំកំណត់គោលដៅខ្ពស់ហួសហេតុពេក ពួកគេគួរតែគិតពីសុខភាពរបស់កម្មករ ទឹកក្តៅទឹកត្រជាក់ ឲ្យគាត់ហូបនៅពេលសម័យកូវីត កុំឲ្យគាត់ចំនាយថវិការទៅទិញទឹកខាងក្រៅ ប្រាក់ខែតិចហើយ ចំណាយលុយច្រើនទៀត។ ថៅកែគួរតែមានទឹកស្អាតនិងមានសុវត្ថិភាពដាក់នៅក្នុងរោងចក្រ។ ជាពិសេសបសស ឲ្យគាត់បានទូលំទូលាយជាងមុន ហើយនិងសុវត្ថិភាពការងារ រៀបចំរបៀបរបបកន្លែងការងារឲ្យពួកគាត់ឲ្យមានភាពល្អប្រសើរ។ សុំឲ្យថៅកែពេលដែលគ្នាធ្វើការ ចេះដេរហើយ កុំឲ្យគ្នាដេរស៊ីថ្ងៃ គិតជាខែឲ្យពួកគាត់ទៅព្រោះគាត់ត្រូវចិញ្ចឹមគ្រួសារគាត់ កុំដកគាត់ចេញតាមតែចិត្ត ការធ្វើបែបនេះគឺវាអត់ត្រូវ ចង់ដកក៏ដក ចឹងទៅវាអត់មានសិទ្ធិពេញលេញ។ គួរតែផ្តល់កិច្ចសន្យារយៈពេលវែងជាមួយនឹងសិទ្ធិទទួលបានអត្ថប្រយោជន៍ពេញលេញដល់កម្មករ។

## ៧. តើជំនួយអ្វីខ្លះ ដែលអ្នកគិតថារដ្ឋាភិបាលគួរមាន ដើម្បីជួយអ្នកឱ្យកាន់តែប្រសើរ ក្នុងអំឡុងពេលដ៏លំបាកនេះ?

រដ្ឋាភិបាលមិនគួរកាត់បន្ថយអត្ថប្រយោជន៍កម្មករពេក ហើយនិងជួយសម្រួលទំនិញទីផ្សារកុំឲ្យឡើងខ្ពស់ពេក ព្រោះអីប្រាក់ខែយើងតិចហើយ បើទំនិញខ្ពស់ពេក យើងអត់មានសមត្ថភាពទៅទិញរបស់ល្អហូប ដើម្បីចិញ្ចឹមសុខភាពយើងឲ្យល្អ ដើម្បីបម្រើការងារប្រចាំថ្ងៃ។ ទី២ ប្រឈមនឹងកម្មករជំពាក់បំណុលគេ ទំនិញទីផ្សារថ្លៃហើយប្រាក់ខែទាប ចឹងយើងប្រឈមនឹងការជំពាក់បំណុលគេរហូត។

សុំឲ្យរដ្ឋាភិបាលនៅពេលដែលក្រុមហ៊ុនមកវិនិយោគក្នុងស្រុក គួរតែពន្យល់ថៅកែក្រុមហ៊ុនកុំឱ្យរំលោភសិទ្ធិកម្មករពេក ឲ្យផ្តល់សិទ្ធិឲ្យកម្មករ ឲ្យដឹងពីតម្លៃរបស់សិទ្ធិមនុស្ស និងច្បាប់ការងារដែលក្រសួងគេបានចែងមក។ ព្រោះអីថៅកែក្រុមហ៊ុនមួយចំនួនគាត់គេងប្រវ័ញ្ចកម្លាំងញើសឈាមកម្មករច្រើន ដូចថាគាត់សុំដាក់ច្បាប់គាត់មិនឲ្យដាក់ ផ្តាច់ការ មិនអនុគ្រោះពេលឈឺល្មមៗ មិនសូវយកចិត្តទុកដាក់សុខភាពកម្មករ។

រដ្ឋាភិបាល គួរតែបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ប័ណ្ណប.ស.ស.។ មន្ត្រីសុខាភិបាលមិនគួរព្រងើយកន្តើយ ឬរើសអើងកម្មករនៅពេលពួកគេប្រើប្រាស់ប័ណ្ណប.ស.ស.ឡើយ។

រដ្ឋាភិបាលគួរតែតម្រូវឱ្យថៅកែរោងចក្រផ្តល់ជំនួយហិរញ្ញវត្ថុ ដល់កម្មករដែលមានជាប់ពាក់ព័ន្ធនឹងកូវីដ។ កម្មករបានបម្រើរោងចក្រជាច្រើនឆ្នាំមកហើយ ហើយពួកគេសមនឹងទទួលបានការថែទាំ និងការគាំទ្រ នៅពេលដែលពួកគេប្រឈមមុខនឹងបញ្ហា។

រដ្ឋាភិបាលគួរដំឡើងប្រាក់ឈ្នួលអប្បបរមា ដើម្បីឲ្យកម្មករមានជីវភាពធូរធារ និងកាន់តែប្រសើរ។ ខ្ញុំមិនប្រាកដថាតើប្រាក់ឈ្នួលអប្បបរមាគួរប៉ុន្មានទេ ព្រោះបើខ្ញុំសុំ ៥០០ ដុល្លារ ហើយតម្លៃទំនិញទីផ្សារឡើងថ្លៃ យើងនឹងនៅតែលំបាកជាមួយ នឹងស្ថានភាពរស់នៅរបស់យើង។

## ៨. តើម្ចាស់ផ្លាកយីហោអន្តរជាតិ គួរធ្វើអ្វីខ្លះ ដើម្បីឱ្យអ្នកឱ្យកាន់តែប្រសើរឡើងក្នុងអំឡុងពេលដ៏លំបាកនេះ?

ខ្ញុំចង់ឲ្យម្ចាស់ផ្លាកយីហោជួយសម្រួលឲ្យម្ចាស់ក្រុមហ៊ុនគោរពសិទ្ធិកម្មករ និងកុំកំណត់គោលដៅខ្ពស់ពេក ឲ្យគាត់គោរពសិទ្ធិកម្មករផង ព្រោះអីជាពិសេស Walmart អត់សូវគោរពសិទ្ធិកម្មករទេ ។ ខ្ញុំអត់ដឹងថាម្ចាស់ផ្លាកគាត់គិតអីដែរ ពេលដែលទាមទារអីឬក៏ក្រុមហ៊ុនគាត់ធ្វើអ្វីមួយរំលោភសិទ្ធិកម្មករ ហើយពេលយើងទៅទាមទារអីទៅគឺពួកគាត់អត់សូវអើពើ ពួកគេមិនអើពើនឹងពាក្យបណ្តឹងរបស់កម្មករ នេះបើតាមខ្ញុំលឺពីសហជីព។ ព្រោះអីនាយកក្រុមហ៊ុន គាត់អត់ផ្តល់សិទ្ធិឲ្យពួកខ្ញុំ រើសអើងសហជីព ហើយនិងប្រធានផ្នែក ប្រធានក្រុម គាត់ជេរកូនក្រុម ពេលចឹងពួកយើងទៅប្តឹងខាងនាយកឲ្យធ្វើការណែនាំ តែពួកគាត់អត់សូវធ្វើតាម។

ខ្ញុំចង់ឲ្យម្ចាស់ផ្លាកយីហោ នៅក្នុងកំឡុងពេលកូវីត ជួយសម្រួលប្រាក់ខែឲ្យកម្មករខ្លះៗក្នុងពេលបិទខ្ទប់ កុំឲ្យផ្តាច់អត់ឲ្យគ្នាសោះ ព្រោះអីយើងប្រឈមខ្លាំង ទីមួយយើងអត់អាចចេញទៅរកស៊ីអីបាន ជួនកាលគាត់មានគ្រួសារចញ្ចឹមកូនពីរបី ចឹងពេលអត់គាត់ម្នាក់ទៅ កូនគាត់អត់មានអី អត់បានទៅរៀនទៅសូត្រ។

ក្នុងអំឡុងពេលបិទខ្ទប់ ហើយអត់មានប្រាក់ខែ ក្នុងខែមេសាហ្នឹង ខ្ញុំបានខ្ចីលុយគេ ២០០ ដុល្លារ រដើម្បីដោះទាល់ថ្លៃបង់ផ្ទះជួល។ ខ្ញុំមិនទាន់បានសងគេវិញទេ ព្រោះអីប្រាក់ខែតិចដែរ ចាយអត់គ្រាន់។ រាល់ថ្ងៃខ្ញុំអាចបង់ការប្រាក់ឲ្យគេ ៤០ ដុល្លារ ក្នុងមួយខែ ចាប់តាំងពីខែឧសភា។ ការប្រាក់ ២០ ដុល្លារ សម្រាប់លុយខ្ចី ១០០ ដុល្លារ ។ ខ្ញុំសង្ឃឹមថាខែខ្លះពេលមានការងារថែមម៉ោងច្រើន ខ្ញុំអាចរកប្រាក់បន្ថែម ដើម្បីបង់ឱ្យគេ។

ខ្ញុំក៏ត្រូវជួយឪពុកម្តាយសងប្រាក់កម្ចីរបស់ពួកគាត់ដែរ។ ឪពុកម្តាយខ្ញុំបានខ្ចីប្រាក់ ៨០០០ ដុល្លារ ពីធនាគារយកទៅរំលស់ដីស្រែពីព្រោះនៅពេលបងប្អូនខ្ញុំមានបញ្ហា ឪពុកម្តាយខ្ញុំបានយកប័ណ្ណកម្មសិទ្ធិដី យកទៅខ្ចីលុយដើម្បីដោះស្រាយបញ្ហា ដំពេលចឹងខ្ញុំខ្ចីលុយហ្នឹងទៅលស់ដីស្រែមកវិញ។ យើងត្រូវសងគេវិញសរុបចំនួន ២៥០ដុល្លារ ក្នុងមួយខែទាំងដើមទាំងការ សម្រាប់រយៈពេល ៤ ឆ្នាំ។ យើងទើបតែបង់ប្រាក់ឱ្យធនាគារបានមួយឆ្នាំទេ។ ក្នុងអំឡុងពេលកូវីដ ពួកគេបានពន្យារពេល ការសងប្រាក់រយៈពេលប្រាំមួយខែតាំងពីខែបិទខ្ទប់ ហើយនៅខែវិច្ឆិកានេះ ខ្ញុំនឹងត្រូវចាប់ផ្តើមបង់ប្រាក់ឱ្យគេវិញ។ ប្រាក់ខែរបស់ខ្ញុំបាន ២២០ ដុល្លារ ទៅ ២៣០ ដុល្លារ ក្នុងមួយខែបើគិតទាំងការងារថែមម៉ោង។ ខ្ញុំជួយឪពុកម្តាយ ១៥០ ដុល្លារ ហើយបងប្អូនខ្ញុំធានាជួយ ១០០ ដុល្លារ។ ខ្ញុំជាអ្នកចេញមុខសងលុយឲ្យធនាគារ។
បន្ទាប់ពីបានបង់ប្រាក់កម្ចីទាំងអស់នេះ បង់ថ្លៃជួល ទឹកភ្លើងរួច និយាយទៅរឿងហូបចុក ខ្ញុំអត់សូវហូបទេ ព្រោះខ្ញុំអត់មានលុយ ខ្ញុំហូបបាយ កញ្ចប់អស់ ១៥០០ រៀល (០.៤០ ដុល្លារ) មានបាយ១កញ្ចប់ សម្លមួយចង់តូច។ ខ្ញុំចំណាយប្រហែល ៥០០០រៀល (១.២៥ ដុល្លារ) ក្នុងមួយថ្ងៃសម្រាប់ការញ៉ាំ។ ខ្ញុំពឹងផ្អែកលើប្រាក់រង្វាន់សម្រាប់ការចំណាយប្រចាំថ្ងៃ ដែលខ្ញុំអាចទទួលបានចន្លោះពី ៥ ទៅ ៧ ដុល្លារ ក្នុងមួយសប្តាហ៍សម្រាប់ការសម្រេចគោលដៅ។

ការគណនាប្រាក់កម្ចី និងការទូទាត់សងរបស់មុំះ

| | **គ្រោងការណ៍សំណង** | **ចំនួនដែលបានសងរួច** | **អត្រាការប្រាក់** |
|---|---|---|---|
| ប្រាក់កម្ចី ១ : ៨,០០០ ដុល្លារ | ២៥០ ដុល្លារ ក្នុង ១ខែ x ៤ ឆ្នាំ = ១២,០០០ ដុល្លារ | ទើបសងរួចបាន១ឆ្នាំ ៣០០០ ដុល្លារ | ទឹកប្រាក់សរុបដែលត្រូវសង ១២,០០០ ដុល្លារ - កម្ចីដើម ៨,០០០ ដុល្លារ= ៤,០០០ ដុល្លារ (មានន័យថាអត្រាការប្រាក់៣៣%) |
| ប្រាក់កម្ចី ២ : ២០០ ដុល្លារ | អាត្រាការប្រាក់ ២០% ក្នុង ១ខែ | បង់ការប្រាក់ ៤០ ដុល្លារ ពីខែឧសភា ដល់តុលា ៤០ ដុល្លារ x ៦= ២៤០ ដុល្លារ (ការប្រាក់សុទ្ធ មិនទាន់មានសងដើមទេ) | អត្រាការប្រាក់ពិតប្រាកដគឺខ្ពស់ជាង ២០% នៅពេលដែលកម្មករមិនអាចមានលទ្ធភាពសងប្រាក់កម្ចីពិតប្រាកដ។ ក្នុងរយៈពេលប្រាំមួយខែកន្លងមកនេះ មុំបានបង់ការប្រាក់រហូតដល់ ១២០% នៃប្រាក់កម្ចីជាក់ស្តែង។ |

ការគណនាចំណូល និងចំណាយប្រចាំខែរបស់មុំ៖

| **ចំណូល** | | **ចំណាយ** | |
|---|---|---|---|
| ប្រាក់ខែ រួមបញ្ចូលនឹងការងារថែមម៉ោង | ២៣០ដុល្លារ | ប្រាក់កម្ចី ១ | ១៥០ ដុល្លារ |
| ប្រាក់រង្វាន់ | ៥x៤ សប្តាហ៍ = ២០ដុល្លារ | ប្រាក់កម្ចី ២ | ៤០ ដុល្លារ |
| | | ផ្ទះជួល | ៤០ ដុល្លារ |
| | | វិក័យប័ត្រទឹកភ្លើង | ៥ ដុល្លារ |
| | | អាហារ | ១.៥x៣១ថ្ងៃ=៣៨.៧៥ |
| | | ការធ្វើដំណើរ ឬថ្លៃសាំង | ១០ ដុល្លារ |
| | | កាតទូរស័ព្ទ | ៥ ដុល្លារ |
| | | ផ្សេងៗ | ??? |
| **ចំណូលសរុប** | **២៥០ ដុល្លារ** | **ចំណាយ សរុប** | **យ៉ាងហោចណាស់ ២៨៨,៧៥ ដុល្លារ** |

ខ្ញុំមានកូនស្រីម្នាក់ អាយុ ១៥ឆ្នាំ កំពុងរៀនថ្នាក់ទី៩។ ក្នុងអំឡុងពេល កូវីដ១៩ កូនខ្ញុំមិនអាចរៀនបានសូត្រទេ សូម្បីតែអនឡាញៗ។ កូនខ្ញុំទើបតែបានទៅសាលារៀនវិញ បានប្រហែល២សប្តាហ៍នេះ ពេលគាត់បានរៀនបានសូត្រវិញចឹង ខ្ញុំសប្បាយចិត្ត ព្រោះអីកុំឲ្យគាត់ទំនេរ ឲ្យបានរៀនបានសូត្រវិញ។ ខ្ញុំនៅម្នាក់ឯងនៅភ្នំពេញ ខ្ញុំបែកគ្នាជាមួយប្តី តែកូនគាត់នៅឯខេត្តរស់នៅជាមួយម៉ែនៅស្តន់ ចាប់តាំងពីខ្ញុំចាប់ផ្តើមធ្វើការរោងចក្រ។ ខ្ញុំទៅលេងកូនម្តង ពីរដងក្នុងមួយខែតាមពេលទំនេរ។ តាំងពីកូវីតអត់សូវហ៊ានទៅលេងទេ ទើបតែទៅមួយខែពីរខែចុងក្រោយនេះដែរ កាលមុនខានទៅលេងជិតមួយឆ្នាំ ដោយសារកូវីតផ្ទុះ ពេលចឹងទៅខ្លាចពាក់ព័ន្ធអីក៏អត់ទៅ។ ពេលទៅលេងកូន ខ្ញុំខ្ចីម៉ូតូពីប្អូនស្រីខ្ញុំ ដែលនៅជិតនេះដែរ ប៉ុន្តែពីមុនកូវីដខ្ញុំជិះឡានឈ្នួល ។ បន្ទាប់ពីធ្វើការនៅថ្ងៃសៅរ៍ ពេលល្ងាចខ្ញុំឡើងឡានទៅលេងគាត់ ហើយត្រឡប់មកវិញនៅថ្ងៃអាទិត្យ។

ឪពុកម្តាយខ្ញុំ ធ្វើស្រែនៅខេត្ត និងលក់គុយទាវ និងបបរនៅក្នុងភូមិ។ ខ្ញុំមានបងប្អូន៦នាក់ផ្សេងទៀត បងប្រុសធំខ្ញុំបួសជាលោក ប្អូនប្រុសម្នាក់ទៀតជាអ្នកបើកឡានឱ្យក្រុមហ៊ុន និងប្អូនពៅនិងប្អូនម្នាក់ទៀតនៅរៀន។ បងស្រីពីរនាក់ផ្សេងទៀត ពួកគេធ្វើការនៅក្នុងរោងចក្រកាត់ដេរ។

៩. តើអ្នកមានអារម្មណ៍យ៉ាងណា ចំពោះជីវិតរបស់អ្នក?

ពេលខ្លះ ខ្ញុំហត់នឿយខ្លាំង។ ហត់នឿយនឹងរកលុយសងបំណុលគេអត់ទាន់។ ធម្មតាពេលបើកលុយមក យកទៅឲ្យគេអស់វិញ ខ្ញុំមានអារម្មណ៍ថាស្តាយនិងហត់ អត់ឃើញលុយនៅនឹងដៃ ចឹងទៅអស់កម្លាំង។ ខ្ញុំអត់ដែលមានពេលធ្វើអ្វីមួយសម្រាប់ខ្លួនឯងសោះ ចូលក្នុងរោងចក្រ ខ្ញុំដោះស្រាយបញ្ហាក្នុងរោងចក្រ ចេញទៅផ្ទះ ខ្ញុំដោះស្រាយបញ្ហាគ្រួសារ។

**១០. តើអ្នកមានក្តីស្រមៃដែរ ឬទេ? តើវាជាអ្វី?**

ខ្ញុំមានក្តីស្រមៃ ក្តីស្រមៃរបស់ខ្ញុំ គឺចង់មានលុយយកទៅសងគេឲ្យអស់ និងធ្វើការងារដែលខ្ញុំចង់ធ្វើ។ ឧទាហរណ៍ថា ចង់ធ្វើការជាមួយសហជីព ឬបើកតូបតូចមួយរកស៊ី។ ខ្ញុំចង់រៀបចំជីវិតខ្លួនឯង ទៅថ្ងៃមុខ។ ខ្ញុំមិនទាន់មានលុយ សម្រាប់អនាគតរបស់ខ្ញុំនៅឡើយទេ ហើយខ្ញុំក៏ត្រូវការលុយសម្រាប់ការសិក្សារបស់កូន ឱ្យកូនរៀនឱ្យបានខ្ពស់ និយាយទៅអត់ទាន់បានធ្វើអីសម្រាប់ខ្លួនឯងសោះ។ ខ្ញុំរវល់តែដោះស្រាយបញ្ហាគ្រួសារ ហើយគ្មានពេលគិតអំពីផែនការផ្ទាល់ខ្លួនខ្ញុំទេ។ ខ្ញុំមិនដឹងថាពេលណាខ្ញុំអាចដោះស្រាយជាមួយប្រាក់កម្ចីទាំងអស់នេះបានទេ ព្រោះថាប្រាក់ខែតិច មិនដឹងពេលណាសងគេអស់។ ខ្ញុំមិនមានសង្ឃឹមទេ។ វាហាក់ដូច

ជាគ្មានផ្លូវចេញ។ ខ្ញុំខ្លាចថានៅពេលអនាគត គ្រួសារខ្ញុំអាចជួបប្រទះនឹងបញ្ហាអីផ្សេងទៀត ហើយត្រូវការយកលុយគេតទៀត នោះខ្ញុំនឹងមិនអាចបញ្ចប់ដោយការសងត្រលប់វិញបានទេ។

**១១. តើអ្វីជាសារចុងក្រោយរបស់អ្នក ទៅកាន់ម្ចាស់ស្លាកយីហោ?**

សាររបស់ខ្ញុំទៅកាន់ម្ចាស់ស្លាកយីហោគឺថា ប្រសិនបើម្ចាស់ស្លាកគាត់បានអួតថាគាត់បានគោរពសិទ្ធិកម្មករ សូមឲ្យគាត់ធ្វើតាមអ្វីដែលបាននិយាយអួតអាង កុំឲ្យគាត់ចេះតែនិយាយ។ ការពិតជីវិតកម្មករកាត់ដេរនៅកម្ពុជាកំពុងរងទុក្ខវេទនាខ្លាំង ហើយវាកាន់តែធ្ងន់ធ្ងរក្នុងអំឡុងពេលកូវីដរាតត្បាតទៀត។ យើងតស៊ូដើម្បីផ្គត់ផ្គង់គ្រួសាររបស់យើង ហើយយើងត្រូវការប្រាក់កម្ចីបន្ថែមទៀត។




**ការសិក្សាករណីទី២៖ ការបាត់បង់ការងារ កំឡុងពេលជួបវិបត្តិកូវីដ១៩**

**១. តើការងាររបស់អ្នកនៅ Violet Apparel មានន័យយ៉ាងណាខ្លះសម្រាប់អ្នក?**

ខ្ញុំឈ្មោះ ចាន់ណា អាយុ ៣៣ ឆ្នាំ ធ្វើការនៅរោងចក្រ Violet Apparel ជាង ១៣ ឆ្នាំហើយ ចាប់ពីឆ្នាំ ២០០៧ រហូតដល់រោងចក្របិទនៅខែមិថុនា ឆ្នាំ ២០២០។ ការងារនៅ Violet Apparel មានន័យខ្លាំងណាស់សម្រាប់ខ្ញុំ។ ទីមួយយើងមានអ្នកគ្រប់គ្រងល្អដែលយកចិត្តទុកដាក់លើបុគ្គលិក គាត់ធ្វើអីមួយគិតឲ្យកូនចៅទទួលបានផលប្រយោជន៍ បើទោះបីជាគាត់ឆេវឆៅ ហើយពេលខ្លះគាត់ខឹងបន្តិចមែន គាត់តែងតែធ្វើអ្វីដែលអាចឲ្យយើងបានទទួលប្រយោជន៍ ហើយប្រធាននៅនឹងក៏មានចិត្តល្អ។ ខ្ញុំមានមិត្តរួមការងារល្អៗ ហើយធ្វើជាមួយគ្នាជាច្រើនឆ្នាំ។ អីវ៉ាន់វិញគឺសុទ្ធតែផលិតម៉ាកល្បីៗដូចជា Matalan និង Nike។ ហើយយើងធ្វើនៅនឹង មិនមែនធ្វើមួយខែពីរខែអីឈប់ទេ យើងធ្វើរហូត ហើយប្រាក់ខែយើងក្នុងមួយខែយើងស៊ីបុង។ រៀងរាល់ពីរសប្ដាហ៍ខ្ញុំបើកម្ដង ចឹងបាន 200 ដុល្លារជាងដែរ ព្រោះអីខាងវេចខ្ចប់ខ្ញុំគឺបានប្រាក់ខែច្រើន ព្រោះយើងគិតតាមតម្លៃបុង

ចឹងវាបានច្រើន។ ដូចចឹង ប្រាក់ខែក្នុងមួយខែអាចរកបាន 500 ដុល្លារជាង វាស៊ីសងនឹងកម្លាំងយើង សំខាន់ យើងធ្វើការលឿន រហ័ស ល្អ។ យើងប្រឹង យើងហត់មែនតែយើងបានផលមកវិញគាប់ចិត្ត។

**២. តើជីវិតរបស់អ្នកបានផ្លាស់ប្តូរយ៉ាងណា នៅពេលដែលអ្នកបាត់បង់ការងារនៅ Violet Apparel?**

នៅខែកុម្ភៈ ឆ្នាំ ២០២០ ខ្ញុំបានធ្វើការរហូតដល់ថ្ងៃទី ០៩ ហើយបន្ទាប់មក ខ្ញុំបានឈប់សំរាកសម្រាលកូន។ អំឡុងពេលសម្រាកប៉ុន្មានខែហ្នឹង ខ្ញុំសួរមិត្តភក្តិនៅកន្លែងធ្វើការ ហើយពួកគេថា រោងចក្រដំណើរការដូចធម្មតា។ ខ្ញុំត្រូវត្រឡប់ទៅធ្វើការវិញនៅថ្ងៃទី ០១ ខែឧសភា ប៉ុន្តែគេថាឲ្យខ្ញុំរង់ចាំ ហើយលឺថាព្យួរការងារទៀត។ ពេលនោះខ្ញុំមានអារម្មណ៍ភ័យ និងតក់ស្លុតណាស់។ ពេលដែលខ្ញុំផ្តាច់ដោះកូន ការងារត្រូវបានគេព្យួរ ពេលចឹងទៅភ័យពិបាកចិត្ត។ ទី១ អត់ដឹងថាទៅរកការងារនៅណាធ្វើ ប្តីក៏អត់ទាន់មានការងារធ្វើ ព្រោះអីប្តីខ្ញុំឈឺ ពេលចឹងខ្ញុំពិបាកចិត្តណាស់។ ពេលហ្នុងគេថា គេនឹងសម្រួល គិតលុយគិតអីឱ្យ ដំបូងខាងរោងចក្រថាគេគិតលុយឲ្យយើងពេញ ៥ចំណុចដែលយើងអាចទទួលបាន ព្រោះអីយើងយក៥% មួយលើកហើយ ចុះកុងត្រាតាំងពី ២០១៤ ហើយគេនិយាយថាអ្នកដែលយកបាន៥% នៅពេលដែលរោងចក្របិទ ម្នាក់ក៏អាចបាន២០០០ ដុល្លារ ទៅ៣០០០ ដុល្លារដែរ ទៅតាមប្រាក់ខែតិចឬច្រើន។ ខ្ញុំទទួលបានដំណឹងហ្នឹង ខ្ញុំអរ ខ្ញុំសប្បាយចិត្តដែរ បើទោះបីរោងចក្របិទក៏ខ្ញុំបានលុយច្រើនល្មម ពេលយើងចង់រកស៊ីអ្វីមួយ តែពេលលទ្ធផលវិញគឺវាអត់បានដូចដែលគេនិយាយ។

ខ្ញុំមានអារម្មណ៍ពិបាកចិត្ត។ ខ្ញុំបានរកការងារថ្មីធ្វើនៅ Olive តែគេមិនយកខ្ញុំទេ ព្រោះគេថាឯកសារខ្ញុំលុប (អត្តសញ្ញាណប័ណ្ណ) មិនច្បាស់ ត្រូវឲ្យភូមិឃុំបោះត្រាឡើងវិញ តែពេលហ្នុងខ្ញុំក៏អត់ទាន់បានធ្វើឯកសារត្រឹមត្រូវតាមនឹងដែរ។ ខ្ញុំទៅធ្វើនៅរោងចក្រផ្សេង រោងចក្រតូចៗ ហើយពេលហ្នឹងខ្ញុំធ្វើបានជិតមួយឆ្នាំដែរ ដល់ពេលរោងចក្រនឹងវារញ៉េរញ៉ៃពេក គេគាបសង្កត់កម្មករពេក ហើយចិននៅនឹងគាត់អត់សួរគិតពីកម្មករ ពួកគេកេងប្រវ័ញ្ចកម្មករ។ ប្រាក់ខែវិញ ក៏បានតិចដែរ តែយើងធ្វើម៉េច បើយើងអត់មានការងារធ្វើមានតែទ្រាំធ្វើសិន ព្រោះអីកូនបៅម្សៅទឹកដោះផង ប្តីក៏ឈឺមិនទាន់រកលុយបាន។ ពេលហ្នុងលំបាកណាស់ ខ្ញុំខ្ចីលុយគេក៏ខ្ចី ជំពាក់គេក៏ជំពាក់ ប៉ុន្តែអត់ដឹងធ្វើម៉េចមានតែបណ្តោយតាមនឹងសិន។ ខ្ញុំមានការងារធ្វើ ប៉ុន្តែខ្ញុំត្រូវឈប់ពីមួយទៅមួយ។ ខ្ញុំឈប់ ព្រោះគេគាបសង្កត់ និងកេងប្រវ័ញ្ចកម្មករពេក។ ពេលខ្ញុំធ្វើការជាមួយរោងចក្រតូចៗនោះ ទើបខ្ញុំដឹងថារោងចក្រផ្សេងមិនបានមួយចំណិតរោងចក្រ Violet ទេ។ ខ្ញុំមានអារម្មណ៍ថាខ្លោចចិត្ត ពិបាកចិត្តខ្លាំងណាស់ ដែលខ្ញុំបាត់បង់ការងារនៅក្រុមហ៊ុន Violet ។ ពេលខ្ញុំឈប់ពីធ្វើការពីរោងចក្រតូចៗទាំងនោះ ខ្ញុំនៅផ្ទះពីរខែដើម្បីមើលថែកូនឈឺ។ ប្តីខ្ញុំបានធ្វើការដឹកអីវ៉ាន់ ចឹងទៅរកប្រាក់បានខ្លះ។ បន្ទាប់មកខ្ញុំដើររកការងារថ្មី តាមរោងចក្រផ្សេងៗ។ ហើយខ្ញុំចេះដេរតិចៗគេអត់យកទេ ព្រោះអីមិនទាន់ចេះដេរស្ទាត់ ចឹងគេមិនសូវពេញចិត្តយើងទេ។ បន្ទាប់មកខ្ញុំបានរកឃើញការងារមួយ ដែលគេផ្តល់ប្រាក់ខែឱ្យខ្ញុំប្រចាំសប្តាហ៍។ មួយសប្តាហ៍ខ្ញុំអាចរកចំណូលបាន ៧៥ ដុល្លារ ឬច្រើនជាងនេះ ប៉ុន្តែបញ្ហាគឺថា ខ្ញុំមិនបានទទួលការងារទៀងទាត់។ តាំងពីបុណ្យភ្ជុំបិណ្ឌដើមខែតុលា រហូតដល់ឥឡូវនេះ គេអត់មានការងារឲ្យខ្ញុំធ្វើទេ។ ម្សិលមិញខ្ញុំទើបដាក់ពាក្យជាប់នៅកន្លែងថ្មី ហើយគេឲ្យចាប់ផ្តើមធ្វើការនៅថ្ងៃស្អែក។ គេឲ្យខ្ញុំ ១៨០ ដុល្លារក្នុងមួយខែ ហើយប៉ុន្មានខែទៀត គេនឹងឲ្យខ្ញុំ ១៩០ ដុល្លារ។

នៅ Violet ខ្ញុំមានកាត ប.ស.ស ប៉ុន្តែខ្ញុំមិនដែលប្រើវាទេ។ ពេលឈឺ ខ្ញុំបានទៅព្យាបាលនៅគ្លីនិកឯកជន ដោយសារតែប្រើប័ណ្ណ ប.ស.ស នៅមន្ទីរពេទ្យរដ្ឋ សេវាមិនបានល្អ និងមិនរហ័ស។ នៅតាមរោងចក្រតូចៗ ទាំងនោះ ពួកគេមិនផ្តល់អត្ថប្រយោជន៍ដល់បុគ្គលិកដែលមាន ប.ស.ស ទេ។ កម្មករខ្លះអាចធ្វើការនៅទីនោះ រយៈពេលប្រាំឆ្នាំ។ សម្រាប់ខ្ញុំ គឺខ្ញុំទ្រាំធ្វើមិនបានទេ ព្រោះអីចិននៅទីនោះមិនឲ្យតម្លៃយើងទេ គាត់ប្រើយើងហួសពីកម្លាំងហើយ ប្រាក់ខែបានតិចទៀត តែខ្ញុំទ្រាំបាននៅនឹងបានមួយឆ្នាំ ព្រោះតែកូនខ្ញុំព្រោះគាត់មិនមែន

នៅបៅដោះទៀតទេ គឺកូនខ្ញុំត្រូវបៅទឹកដោះគោ។ ខ្ញុំត្រូវទុកកូនចោលនៅស្រុកជាមួយឪពុកម្តាយខ្ញុំ។ ខ្ញុំត្រូវចំណាយគ្រប់មុខ ថ្លៃផ្ទះផង និងថ្លៃចំណាយផ្សេងៗទៀត ពេលចឹងពិបាក។

បើរាល់ថ្ងៃនេះ បើសិនរោងចក្រ Violet នៅបើកវិញខ្ញុំមិនដឹងជាសប្បាយចិត្តម៉េចទេ។ តាមពិតខ្ញុំត្រូវបានលុយឧបត្ថម្ភពេលសម្រាលកូនរួច ឥឡូវអត់បានអីទាំងអស់ព្រោះរោងចក្រគេបិទ។ ខ្ញុំត្រូវសម្រាកពីរម៉ោង ដើម្បីបំបៅដោះកូន។ ខ្ញុំបានឈប់សម្រាកសម្រាលកូនបានរយៈពេលបីខែ ហើយមុនពេលខ្ញុំឈប់សម្រាក គេបានបើកប្រាក់ឱ្យខ្ញុំពាក់កណ្តាល ក្នុងនោះគេគិតទាំងលុយសម្រាប់ពេលខ្ញុំសម្រាលកូន និងប្រាក់ខែដែលខ្ញុំបានធ្វើការឲ្យគេចុងក្រោយ បើគិតទៅប្រហែល $1100 (រួមទាំងប្រាក់ខែចុងក្រោយរបស់ខ្ញុំ)។ ចឹងសម្រាប់លុយ ប.ស.ស ពេលខ្ញុំសម្រាលហើយ ខ្ញុំទទួលបានចំនួន $550។ បើទោះបីនៅ Violet មានលក្ខខណ្ឌការងារល្អ តែនៅតែមានបញ្ហាខ្លះចឹង ពេលខ្លះអ្នកគ្រប់គ្រងជនជាតិចិនបានស្រែកដាក់ពួកយើង។ បន្ទាប់ពីស្រែក គេក៏មកនិយាយជាមួយយើងដូចធម្មតា ពេលចឹងទៅយើងថាខឹងគាត់ ហើយធ្វើឲ្យយើងមានអារម្មណ៍ល្អប្រសើរវិញចឹងទៅ។

**៣. តើអ្នកដឹងពីចំនួនទឹកប្រាក់ ដែលអ្នកមានសិទ្ធិទទួលបានទេ? តើចំនួន ដែលអ្នកបានទទួលជាចំនួនត្រឹមត្រូវ ឬទេ? បើមិនដូច្នោះទេ តើចំនួនពិតប្រាកដដែលអ្នកគួរទទួលបានគឺប៉ុន្មាន?**
ខ្ញុំមិនប្រាកដដែរពីរបៀបទូទាត់លុយឲ្យខ្ញុំនៅពេលរោងចក្របិទ ខ្ញុំគ្រាន់តែបានលឺពីមេរបស់ខ្ញុំថា គេគិតទៅលើប្រាំចំណុច ហើយសរុបទៅខ្ញុំបានប្រហែលជិត ៣ ពាន់ដុល្លារ ព្រោះអីគេគិតតាមប្រាក់ខែរបស់យើង។ តែកម្មករទាំងអស់រួមទាំងខ្ញុំអត់ទទួលបានប្រាក់នោះទេ មិត្តរួមការងារខ្ញុំ និងសហជីព (CATU) បានធ្វើការតវ៉ា។ ខ្ញុំមិនបានចូលរួមជាមួយពួកគាត់ទេ ពេលនឹងខ្ញុំនៅមើលកូននៅឯផ្ទះនៅខេត្ត។ ខ្ញុំបានមើលការឡាយផ្ទាល់នៅពេលឃើញ មិត្តរួមការងាររបស់ខ្ញុំកំពុងឈរហាលភ្លៀង ហាលខ្យល់ ខ្ញុំមានអារម្មណ៍តក់ស្លុត រន្ធត់ចិត្តណាស់ ហើយទឹកភ្នែក ខ្ញុំហូរមកដោយអត់ដឹងខ្លួន។ ខ្ញុំមានអារម្មណ៍ថាខ្ញុំមិនចង់ឲ្យមានរឿងនេះ កើតឡើងទេ។ រោងចក្រមិនគួរបិទទេ។ ព្រោះអីមុនពេលបិទ ប្អូនស្រីខ្ញុំក៏ធ្វើការនៅទីនោះដែរ ហើយខ្ញុំបាននិយាយជាមួយប្អូនមុនពេលរោងចក្របិទ ប្អូនខ្ញុំថា គេមានឥវ៉ាន់អីធ្វើដូចធម្មតា។ បន្ទាប់ពីព្យួរការងាររយៈពេលពីរខែក៏គេថាបិទដោយអត់មានផ្តល់ដំណឹងមុនទេ គឺថាផ្តល់ដំណឹងភ្លាមៗ គេថាដោយសារតែកូវីត។

ខ្ញុំបានសម្រេចចិត្តទទួលយកការទូទាត់ចុងក្រោយពីរោងចក្រ ទោះបីជាវាមិនពេញក៏ដោយ ព្រោះអីខ្ញុំអត់លុយ។ ខ្ញុំត្រូវការលុយសម្រាប់ដោះស្រាយបញ្ហាក្នុងគ្រួសារ សម្រាប់បង់ថ្លៃជួលផ្ទះ ទឹកដោះគោកូន និងថ្លៃចាយវាយប្រចាំថ្ងៃ។ ពេលហ្នុងខ្ញុំបាន ប្រហែលជិត ៧០០ ដុល្លារ រួមបញ្ចូលទាំងសំណងជូនដំណឹងជាមុន (១៥ថ្ងៃ) ប្រាក់បំណាច់អតីតភាពការងារសម្រាប់រយៈពេល ១ឆ្នាំកន្លះតែប៉ុណ្ណោះ (ចាប់ពីពេលដែលកិច្ចសន្យាការងារត្រូវបានប្តូរទៅជាកិច្ចសន្យាការងារគ្មានដែនកំណត់ (UDC) ០១/០១/២០១៩ – ៣០/០៦/២០២០) និងការឈប់សម្រាកប្រចាំឆ្នាំដែលមិនបានប្រើ។

**៤. តើការងារនោះបាត់បង់នោះ ជះឥទ្ធិពលយ៉ាងណាមកលើគ្រួសាររបស់អ្នក? តើអ្នកបានធ្វើអ្វីដើម្បីទប់ទល់នឹងស្ថានភាពនេះ?**
ពេលខ្ញុំគ្មានការងារធ្វើ ខ្ញុំឆេវឆាវដែរព្រោះគ្មានលុយ ពេលខ្លះខ្ញុំឆាប់ខឹងរករឿងប្តី។ ខ្ញុំមានអារម្មណ៍អត់ល្អមួម៉ៅដាក់ប្តីខ្ញុំ ដែលគាត់រកលុយបានតិច យើងខ្វះខាតច្រើន ហើយយើងអត់មានលុយ។ ហើយឥឡូវនេះខ្ញុំក៏បាត់បង់ការងារដែរ។ សម្រាប់ខ្ញុំអត់អីអត់ចុះ តែខ្ញុំមិនចង់ឲ្យកូនខ្ញុំរស់ក្នុងស្ថានភាពលំបាកដូចខ្ញុំទេ។ ល្អហើយដែលប្តីខ្ញុំគាត់មានចរឹកចាស់ទុំ។ គាត់មិនប្រកាន់ជាមួយចរឹកឆេវឆាវរបស់ខ្ញុំ។ ប្តីខ្ញុំតែងតែយោគយល់ គាំទ្រ និងលើកទឹកចិត្តខ្ញុំឱ្យស៊ូទ្រាំនឹងបញ្ហាលំបាកជាមួយគ្នា។ ខ្ញុំក៏សម្រេចចិត្តខ្ចីលុយគេ ១០០០ដុល្លារ ព្រោះអីពេលនឹងប្តីខ្ញុំឈឺ ហើយខ្ញុំអត់ទាន់មានការងារធ្វើ ហើយកូនត្រូវការទឹកដោះគោ។ តែលុយនឹងគ្មានបានចាយអី

ម៉ានទេ ទុកគ្រាន់ដោះស្រាយប្តីឈឺ។ ខ្ញុំត្រូវបញ្ជូនគាត់ទៅបន្ទប់សង្គ្រោះបន្ទាន់ ICU ។ ដោយសារប្តីខ្ញុំធ្វើការនៅក្រុមហ៊ុនដឹកជញ្ជូន គាត់អត់មានប័ណ្ណប.ស.ស. ហើយប័ណ្ណប.ស.ស.ខ្ញុំប្រើបានតែខ្ញុំទេ។ ខ្ញុំត្រូវសងលុយគេវិញក្នុងមួយខែ ១០០ ដុល្លារ រយៈពេល ១៣ខែ។ ខ្ញុំបានលក់ខ្សែដៃ ខ្សែកសម្រាប់ទប់បញ្ហាជីវភាពរបស់ខ្ញុំដូចជាបង់ថ្លៃផ្ទះ (៤៥ ដុល្លារក្នុងមួយខែ)។ ខ្ញុំក៏ត្រូវទិញទឹកដោះគោសម្រាប់កូនខ្ញុំដែរ ព្រោះអីពេលខ្ញុំទៅធ្វើការ កូនខ្ញុំត្រូវបៅទឹកដោះគោ ហើយកូនខ្ញុំផ្ញើនៅឪពុកម្តាយនៅឯស្រុកនៅខេត្តព្រៃវែង ហើយខ្ញុំតែង ទៅលេងគាត់នៅរៀងរាល់ចុងសប្តាហ៍។

**៥. តើកូវីដមានឥទ្ធិពលអ្វីខ្លះចំពោះអ្នក និងគ្រួសាររបស់អ្នក? តើអ្នកអាចចាក់វ៉ាក់សាំងបានហើយឬនៅ? តើអ្នកធ្លាប់បានឆ្លងកាត់ឬក៏បារម្ភពីការឆ្លងកូវីដដែរទេ?**

និយាយទៅជិតមួយឆ្នាំហើយ ខ្ញុំមិនដែលបានជួបកូនទេ តាំងពីគេបិទខ្ទប់ក្នុងខែមេសាមក បានតែតេតាមទូរស័ព្ទ រហូតដល់បានចាក់វ៉ាក់សាំងហើយទើបខ្ញុំបានទៅស្រុក ទើបបានទៅជួបកូន។ ពេលរយៈពេលបិទខ្ទប់ហ្នឹងគឺពិបាកណាស់ នៅកន្លែងខ្ញុំគឺមិនមានអ្នកណាមកសួរនាំអីទេជិតកន្លះខែដែរ។ និយាយទៅពិបាកច្រើនពេលបិទខ្ទប់នឹង គឺអត់មានជំនួយពីខាងណាទេ មានតែជំនួយពីឪពុកម្តាយខ្ញុំ ពួកគាត់លក់ជ្រូកយកលុយទិញអង្ករ ទិញម្ហូប របស់របរផ្ញើតាមឡានមកឲ្យហូប។

**៦. តើអ្នកចង់និយាយអ្វីទៅកាន់និយោជក ក៏ដូចជាម្ចាស់ស្លាកយីហោរ?**

**ជូនចំពោះថៅកែ Violet៖**

ខ្ញុំមិនចង់ទាមទារឲ្យគាត់ទូទាត់ប្រាក់ចុងក្រោយទេ។ ខ្ញុំចង់ឲ្យខាងរោងចក្របើកដំណើរការឡើងវិញហើយយកកម្មករមុនៗ មកធ្វើការវិញ ព្រោះអីធ្វើការនៅកន្លែងផ្សេងពិបាកណាស់។ បើមិនចឹងទេ ចង់ឲ្យគាត់ទូទាត់លុយដែលពួកខ្ញុំមានសិទ្ធិទទួលបាន ព្រោះកម្មករទាំងអស់ ដែលបាត់បង់ការងារ គាត់ពិបាកណាស់។

**ទៅម្ចាស់ស្លាកយីហោ៖**

ចង់ឲ្យគាត់គិតលុយឲ្យពួកយើងឲ្យបានត្រឹមត្រូវ តាមអីដែលយើងមានសិទ្ធិនឹងទទួលបាន និងសុំឱ្យគាត់បើករោងចក្រវិញក៏បានដែរ ព្រោះក្រុមហ៊ុនផ្សេងទៀតដែលជាក្រុមគ្រួសារជាមួយគ្នា រួមមាន Olive, Apple និង Berry នៅតែដំណើរការដដែល។

**៧. តើអ្នកចង់និយាយអ្វីទៅកាន់រដ្ឋាភិបាល?**

ខ្ញុំជឿថា នៅពេលដែលមានគេមកវិនិយោគនៅស្រុកខ្មែរ ខាងរដ្ឋាភិបាលយើងបានចុះកិច្ចព្រមព្រៀងនិងនិយាយគ្នារួចហើយ មុនពេលបើកដំណើរការរោងចក្រនីមួយៗ គាត់ក៏ដឹងថាអ្វីត្រូវគិតឲ្យកម្មករឲ្យបានសមរម្យ ព្រោះអីកម្មករនៅស្រុកខ្មែរពេលអត់រោងចក្រទៅគឺពួកគេពិបាកណាស់ អ្នកខ្លះគ្មានការងារធ្វើ អត់មានលុយ។ ខ្ញុំចង់ឲ្យគាត់ជួយមើលកម្មករផង។ ចង់ឲ្យរដ្ឋាភិបាលជួយពន្លឿនលុយដែលក្រុមហ៊ុនថានឹងទូទាត់ឲ្យកម្មករឲ្យបានលឿនផង។